# ទស្សនាវដ្តី កសិកម្ម

# THE AGRICULTURE MAGAZINE



ឆ្នាំទី ២០ ត្រីមាសទី ១ (មករា-មីនា) ឆ្នាំ ២០២១ លេខ ៧៧

អាសយដ្ឋានលេខៈ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (០២៣) ២១១ ៣៥១ ទូរសារលេខ : (៨៥៥)២៣ ២១៧ ៣២០
គេហទំព័រ : http://www.maff.gov.kh
e-mail : info@maff.gov.kh

## មាតិកា ទំព័រ


- លិខិតថ្លែងអំណរគុណ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ០១
- លិខិត **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ០២
- លិខិតថ្លែងអំណរគុណ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ផ្ញើជូន ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ........ ០៣
- សុន្ទរកថា ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ក្នុងកម្មវិធីបើកអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២........ ០៤
- សុន្ទរកថាឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ក្នុងកម្មវិធីបិទអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២........ ០៨
- សុន្ទរកថា ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១........ ១២
- បច្ចេកទេសដាំដំណាំកៅស៊ូជាលក្ខណៈគ្រួសារ (បន្តពីទស្សនាវដ្តីកសិកម្មលេខ៧៦)........ ១៨
- ចំណេះដឹងស្តីអំពីសុខភាពសត្វ(បន្តពីទស្សនាវដ្តីកសិកម្ម លេខ៧៦) ........ ២៣
- បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមបង្កងរបស់កសិករ ព្រំ វ៉ាត........ ៣២
- បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមទាកសិករ សូត សុផល........ ៣៦
- វិធីសាស្រ្តក្នុងការយករួចខ្លួនពីការដេញប្រហារពីសត្វសាហាវទាំង១២ ដែលគួរតែចងចាំ........ ៤០
- របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំត្រីមាសទី១ ឆ្នាំ២០២១និងទិសដៅអនុវត្តបន្ត........ ៤៦
- សេចក្តីណែនាំស្តីពីការចាត់វិធានការណ៍បង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺ COVID 19 ........ ៦០
- សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ........ ៦១






ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតថ្លែងអំណរគុណ

**ជូនចំពោះ**
**ឯកឧត្តម វេង សាខុន**
**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

ខ្ញុំមានសេចក្ដីរីករាយដែល**ឯកឧត្តមរដ្ឋមន្ត្រី** បានផ្ញើលិខិតជូនពរចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ក្នុងឱកាសខួបកំណើតខ្ញុំ គម្រប់ ៧៦ ឈានចូល ៧៧ ឆ្នាំ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**ឯកឧត្តមរដ្ឋមន្ត្រី** ដែលបានជូនពរខ្ញុំប្រកបដោយមនោសញ្ចេតនាយ៉ាងកក់ក្ដៅបំផុត ហើយក្នុងឱកាសនេះខ្ញុំក៏សូមជូនពរ**ឯកឧត្តមរដ្ឋមន្ត្រី** ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទវិញ សូមទទួលបាននូវជោគជ័យថ្មីៗថែមទៀត ក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ និងសូមបានជួបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម**ឯកឧត្តមរដ្ឋមន្ត្រី** ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ ពីខ្ញុំ។

ថ្ងៃ សុក្រ ៨ រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០២១
**ប្រធានព្រឹទ្ធសភា**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្ដម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ: (855 23) 211 435

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# ផ្ញើជូន

ឯកឧត្តម **វេង សាខុន**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

តាមរយៈលិខិត ៨៨៣៦ កសក ចុះថ្ងៃចន្ទ ៣រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំ និងភរិយា បានទទួលរួចហើយនូវអាហារូបករណ៍ ថ្នាក់បរិញ្ញាបត្រ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ចំនួន ៥០កន្លែង សម្រាប់ឆ្នាំសិក្សាថ្មី២០២០-២០២១ នេះ។

ការចូលរួមរបស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជាសាកលវិទ្យាល័យភូមិន្ទកសិកម្ម គឺបានបង្ហាញនូវសកម្មភាពយ៉ាងសកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងចំណេះធ្វើ ប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ សម្រាប់បន្តវេនក្នុងការកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ។

សូម ឯកឧត្តមរដ្ឋមន្ត្រី និង គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យ និស្សិត នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម បានជួបប្រទះនឹងពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០២១

**ហ៊ុន សែន**

**សម្ដេចក្រឡាហោម ស ខេង**
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**លិខិតថ្លែងអំណរគុណ**

**ជូនចំពោះ**

**ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

***ឯកឧត្តម ជាទីរាប់អាន!***

ខ្ញុំមានសេចក្ដីសោមនស្សរីករាយ និងសូមថ្លែងអំណរគុណចំពោះសមានចិត្តស្រលាញ់រាប់អានដ៏ជ្រាលជ្រៅរបស់ **ឯកឧត្តម** រួមជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ ដែលបានផ្ញើលិខិតជូនពររូបខ្ញុំក្នុងឱកាសចម្រើនជន្មាយុ ៧០ឆ្នាំ ឈានចូល ៧១ឆ្នាំ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១ កន្លងទៅនេះ ។

តបចំពោះសមានចិត្តដ៏ប្រពៃនេះ នាឱកាសឆ្នាំថ្មី២០២១ ខ្ញុំសូមជូនពរ **ឯកឧត្តម និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ និងសហការី** សូមមានសុខភាពល្អបរិបូរណ៍ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងបានប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

សូម **ឯកឧត្តម** ទទួលនូវសេចក្ដីរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ៕

ថ្ងៃ សុក្រ ៩កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មករា ឆ្នាំ២០២១

**ស ខេង**

# សុន្ទរកថា
## ឯកឧត្តម វេង សាខុន
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារ អន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងកម្មវិធីបើកអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២

ថ្ងៃពុធ ១៤កើត ខែមាឃ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ខេត្តសៀមរាប ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២១

**សូមគោរព ៖**

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ
- សមាជិក សមាជិកានៃអង្គវេទិកាជាតិទីមេត្រី




*ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារ អន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ថ្លែងក្នុងកម្មវិធីបើកអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២*

ថ្ងៃនេះ ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេក និងសូមសម្តែងនូវបដិសណ្ឋារកិច្ចចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសទាំងអស់ដែលបានឆ្លៀតឱកាសចូលរួមក្នុង អង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២ ដ៏មានអត្ថន័យនេះ។ ជាមួយនេះដែរ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រុមការងារអន្តរក្រសួងក្រោមការសម្របសម្រួលរបស់ក្រសួងទេសចរណ៍ ដែលបានសហការយ៉ាងល្អប្រសើរជាមួយរដ្ឋបាលខេត្តសៀមរាប ព្រមទាំងអង្គការជាតិ-អន្តរជាតិ និងដៃគូពាក់ព័ន្ធទាំងអស់ក្នុងការរៀបចំវេទិកាជាតិអេកូទេសចរណ៍លើកទី២នេះ ឱ្យប្រព្រឹត្តទៅក្នុងបរិយាកាសមួយប្រកបដោយភាពទាក់ទាញ ពោរពេញដោយអត្ថន័យយ៉ាងជ្រាលជ្រៅនៅខេត្តសៀមរាបទឹកដីទេសចរណ៍ដ៏ស្រស់បំព្រងនៃមាតុភូមិអង្គរដ៏បវរនេះ។

លើសពីនេះទៀត ខ្ញុំសូមសម្តែងនូវមូលវិចារណ៍ និងវាយតម្លៃខ្ពស់ចំពោះ ចំណាប់អារម្មណ៍ដ៏មានអត្ថន័យរបស់ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប ដែលបានជម្រាបជូនអំពីស្ថានភាពនៃដំណើរការអភិវឌ្ឍប្រកបដោយផ្លែផ្កា ពិសេសសក្តានុពលនៃវិស័យទេសចរណ៍ និងវិស័យសំខាន់ៗផ្សេងៗទៀត ដែលក្នុងនោះក៏មានវិស័យកសិកម្មផងដែរ រួមទាំងការរៀបចំផែនការមេ អភិវឌ្ឍន៍វិស័យទេសចរណ៍ និងផែនការសកម្មភាពអភិវឌ្ឍន៍ខេត្តសៀមរាប ឆ្នាំ២០២០-២០២៥ ដែលពិតជាបានឆ្លុះបញ្ចាំងឱ្យឃើញអំពីការខិតខំប្រឹងប្រែងក្នុងការរួមចំណែកលើកកម្ពស់សេដ្ឋកិច្ចជាតិប្រកបដោយផ្លែផ្កា ពិសេសក្នុងកាលៈទេសៈដែលប្រទេសជាតិយើងទទួលរងនូវហានិភ័យពីជំងឺរាតត្បាតបណ្តាលមកពីកូវីដ-១៩នេះ ក៏ដូចជាគ្រោះទឹកជំនន់នាពេលកន្លងមកនេះផងដែរ។

**អង្គពិធីទាំងមូលជាទីមេត្រី!**

យើងទាំងអស់គ្នាបានជ្រាបយ៉ាងច្បាស់ហើយថា រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាចិត្តខ្ពស់ក្នុងការធានានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលមានភាពអនុគ្រោះសម្រាប់សកម្មភាពផុសផុលនៃការវិនិយោគ និងធុរកិច្ចក្នុងគ្រប់វិស័យ។ ឈរលើមូលដ្ឋាននេះ កម្ពុជា



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងកម្មវិធីបើកអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី៧ នៅសណ្ឋាគារសុខា ខេត្តសៀមរាប

បានឆ្លងកាត់ពីឋានៈជាប្រទេសមានចំណូលទាប មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប កាលពីឆ្នាំ២០១៥ កន្លងទៅ ហើយប្រាក់ចំណូលប្រជាជននឹងកើនឡើងដល់១ ៩០០ដុល្លារអាមេរិកក្នុងមួយឆ្នាំ សម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០២០នេះ។ រីឯអត្រានៃភាពក្រីក្រនៅកម្ពុជាក៏បានបន្តធ្លាក់ចុះជាលំដាប់ពីជាង៥៣% ក្នុងឆ្នាំ២០០៤ រហូតមកដល់ក្រោម១០% នាពេលបច្ចុប្បន្ននេះ។ ជាលទ្ធផល សេដ្ឋកិច្ចជាតិយើងបានរីកធំធាត់យ៉ាងឆាប់រហ័ស ហើយរចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏កំពុងផ្លាស់ប្តូរពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្មទៅជាប្រទេសដែលពឹងផ្អែកជាសំខាន់លើវិស័យឧស្សាហកម្ម និងសេវាកម្មវិញ ក្នុងបរិបទនៃបដិវត្តន៍ឧស្សាហកម្មទី៤។ ជាចក្ខុវិស័យ និងទិស



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងកម្មវិធីបើកអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី៧ នៅសណ្ឋាគារសុខា ខេត្តសៀមរាប

ដៅគោលនយោបាយវែងឆ្ងាយរបស់រាជរដ្ឋាភិបាលគឺ ប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ (ចន្លោះពី ៤ ៨០០ដុល្លារអាមេរិកទៅ ១២ ០០០ដុល្លារអាមេរិក សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ) និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ (ចាប់ពី ១២ ០០០ដុល្លារអាមេរិកឡើងទៅ)។

ជារួមសន្ទុះនៃកំណើនសេដ្ឋកិច្ចកម្ពុជា ប្រកបដោយសុទិដ្ឋិនិយមនេះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីការរីកចម្រើននៃវិស័យនានា ដែលជាសមាសធាតុដ៏សំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ជាពិសេសវិស័យកសិកម្ម ឧស្សាហកម្ម ទេសចរណ៍ កាត់ដេរ និងសំណង់ជាដើម។ ក្នុងនោះ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យកសិកម្មជាវិស័យអាទិភាពមួយនាគ្រប់កាលៈទេសៈ ហើយវិស័យទេសចរណ៍គឺជា មាសបៃតង ដែលមានការរីកចម្រើនយ៉ាងខ្លាំង និងប្រកបដោយសក្តានុពល។ ដោយឡែក របៀបវារៈនៃអង្គវេទិកានាពេលនេះ គឺពិតជាបានឆ្លើយតបយ៉ាងសមស្របទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលលើការប្តេជ្ញាចិត្តក្នុងការបន្តអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាថាជា “ទេសចរណ៍វប្បធម៌ និងធម្មជាតិ” ផងដែរ ជាពិសេសគោលនយោបាយជាតិ អេកូទេសចរណ៍២០១៩-២០៣០។

ជាអកុសល រលកព្យុះនៃវិបត្តិជំងឺឆ្លងកូវីដ-១៩ បាននឹងកំពុងបោកបក់មកលើសេដ្ឋកិច្ច និងសង្គម នៅក្នុងបណ្តាប្រទេសស្ទើរតែទាំងអស់នៅទូទាំងពិភពលោក រួមទាំងកម្ពុជាយើងផងដែរ។ ការរីករាលដាលនៃជំងឺកូវីដ-១៩ និងវិបត្តិសេដ្ឋកិច្ចនេះបានបង្កការគំរាមកំហែងយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍដែលកម្ពុជាសម្រេចបានដោយជោគជ័យក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះនៃប្រវត្តិសាស្ត្ររបស់ខ្លួន។ ក្នុងបរិការណ៍នេះធនាគារពិភពលោក និងស្ថាប័នអន្តរជាតិធំៗបានព្យាករណ៍ថា នៅឆ្នាំ២០២០នេះ សេដ្ឋកិច្ចកម្ពុជាអាចធ្លាក់ចុះក្នុងរង្វង់ -២,០%។ ប៉ុន្តែមកដល់ពេលនេះ សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែបង្ហាញសញ្ញាវិជ្ជមានចំពោះវិស័យមួយចំនួន ហើយវិស័យខ្លះទៀតនៅតែបន្តជួបការលំបាក ជាពិសេសវិស័យទេសចរណ៍ដែលកំពុងជួបនឹងបញ្ហានៃការធ្លាក់ចុះចំនួនភ្ញៀវទេសចរបរទេសយ៉ាងគំហុកក្នុងរយៈពេលមួយឆ្នាំនេះ។ ទោះជាយ៉ាងណា យើងសង្ឃឹមថា កំណើនសេដ្ឋកិច្ចកម្ពុជានឹងស្ទុះងើបឡើងវិញ នៅក្នុងឆ្នាំ២០២១នេះ ដោយសារកម្លាំងជំរុញនៃគោលនយោបាយគាំទ្ររបស់រាជរដ្ឋាភិបាលជួយដល់ជនក្រីក្រ ភាពល្អប្រសើរជាងមុននៃផលិតកម្មវិស័យកសិកម្ម ការកើនឡើងនៃការនាំចេញផលិតផលសម្លៀកបំពាក់ ការគាំទ្រផ្នែកហិរញ្ញប្បទាន



*សកម្មភាពទស្សនាពិព័រណ៍ក្នុងកម្មវិធីបើកវេទិកាជាតិ អេកូទេសចរណ៍លើកទី៧ នៅសណ្ឋាគារសុខា ខេត្តសៀមរាប*

ដល់សហគ្រាសធុនតូច និងមធ្យមជាដើម។ ជាមួយគ្នានេះ ទេសចរណ៍ក្នុងស្រុកក៏បានជួយមួយផ្នែកក្នុងការធ្វើឱ្យឧស្សាហកម្មទេសចរណ៍ និងការធ្វើដំណើរកម្សាន្តកក្រើកឡើងវិញផងដែរ។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលកម្ពុជា បានខិតខំតស៊ូយ៉ាងប្តូរផ្តាច់ និងយកអស់កម្លាំងកាយចិត្ត បញ្ញាញាណ និងធនធាន ដើម្បីការពារសុខុមាលភាពប្រជាពលរដ្ឋប្រកបដោយភាពកក់ក្តៅ ព្រមទាំងបាន និងកំពុងជំរុញកំណើនសេដ្ឋកិច្ច ដោយអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ស៊ីជម្រៅ និងការអភិវឌ្ឍលើគ្រប់វិស័យ ជាពិសេសវិស័យកសិកម្មដែលកំពុងតែដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ការរក្សាបាននូវសន្តិសុខស្បៀងអាហារជូនប្រជាជនកម្ពុជាចំនួនប្រមាណជាង១៦លាននាក់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនយើង ក្នុងសមរភូមិសង្គ្រាមប្រយុទ្ធប្រឆាំងនឹងជំងឺ COVID-១៩នេះ។

ម្យ៉ាងទៀតក្នុង កាលៈទេសៈដែលយើងកំពុងទទួលរងនូវបញ្ហាប្រឈមពីវិបត្តិនៃជំងឺកូវីដ-១៩នេះ សម្រាប់វិស័យកសិកម្ម ខ្ញុំយល់ថា យើងទាំងអស់គ្នាត្រូវគាំទ្រ និងចូលរួម "ប្រែក្លាយកសិកម្មកម្ពុជា ជាកសិកម្មទំនើបមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តរភាពដើម្បីបង្កើនប្រាក់ចំណូលគ្រួសារកសិករ លុបបំបាត់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងអាហារូបត្ថម្ភ និងជំរុញការអភិវឌ្ឍកសិកម្មដោយនិរន្តរភាព" ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាពតាមអភិក្រម និងវិសាលភាពថ្មីដើម្បីប្រែក្លាយវិស័យនេះ ពីដំណាក់កាលនៃការអភិវឌ្ឍតាមបែបយថាផល ឈានទៅរកដំណាក់កាលថ្មីដែលផ្តោតលើប្រពលវប្បកម្ម ព្រមទាំងលើកកម្ពស់ពិពិធភាវូបនីយកម្មដំណាំដែលមានសក្តានុពល និងមានតម្រូវការទីផ្សាររួមទាំងការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈពាណិជ្ជកម្ម ដែលយើងទាំងអស់គ្នាត្រូវចូលរួមឱ្យបានសកម្មថែមទៀត ព្រមទាំងការអនុវត្តគោលនយោបាយពិពិធកម្មវិស័យទេសចរណ៍ដើម្បីកែប្រែជីវភាពរបស់បងប្អូនដែលប្រកបមុខរបរកសិកម្មឱ្យទៅជា "កសិ-ពាណិជ្ជករ" និងទទួលបានតម្លៃបន្ថែមក្នុងជីវភាពរស់នៅរបស់ខ្លួន។ ជាពិសេស ការធានាបាននូវអាហារូបត្ថម្ភប្រកបដោយគុណភាពសម្រាប់ប្រជាជនកម្ពុជាទាំងមូល និងមានអតិរេកសម្រាប់ការនាំចេញ ដោយមិនត្រូវមើលរំលងអំពីការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ និងជលផល ដើម្បីនិរន្តរភាពនៃភពផែនដី ប្រកបដោយភាតរបរិស្ថាន និងភាពទាក់ទាញពីភ្ញៀវទេសចរផងដែរ។

សូមជម្រាបជូនថា បច្ចុប្បន្ននេះសហគមន៍នេសាទចំនួន ១៣១សហគមន៍ក្នុងចំណោមសហគមន៍នេសាទទាំងអស់៥១៦ នៅកម្ពុជា គឺមានសក្តានុពលភាពអាចបង្កើតជាសហគមន៍ទេសចរណ៍ធម្មជាតិ ដើម្បីរួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចគ្រួសារ ក៏ដូចជាសេដ្ឋកិច្ចជាតិជាចម្បង។ បច្ចុប្បន្ន មានសហគមន៍នេសាទចំនួន ២៧សហគមន៍ បាននិងកំពុងដំណើរការទេសចរណ៍ធម្មជាតិនៅតំបន់មាត់សមុទ្រ និងតំបន់បឹងទន្លេសាបនៅក្នុង ៩ខេត្ត រួមមានខេត្តក្រចេះ ស្ទឹងត្រែង តាកែវ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង បន្ទាយមានជ័យ កំពត ព្រះសីហនុ កែប និងខេត្តកោះកុង។ ដោយឡែក គិតមកទល់ពេលនេះ យើងបង្កើតសហគមន៍ព្រៃឈើនៅទូទាំងប្រទេសសរុបចំនួន ៦៣៨សហគមន៍ ក្នុងនោះបានធ្វើផែនការគ្រប់គ្រងចំនួន ១០៣សហគមន៍ ព្រមទាំងមានតំបន់ព្រៃឈើតាមបណ្តោយដងស្ទឹង ព្រែក បឹង ក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ចម្ការឈើដាំ ស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ចម្ការកសិរុក្ខកម្ម ចម្ការរុក្ខទិវាថ្នាក់ជាតិ និងក្រោមជាតិ ដែលអាចអភិវឌ្ឍទៅជាគោលដៅទេសចរណ៍ធម្មជាតិ កសិ-ទេសចរណ៍ និងតំបន់លំហែកម្សាន្តផងដែរ។ លើសពីនេះទៀត យើងបង្កើតសហគមន៍កសិកម្មបានចំនួន ១ ១៩០ សហគមន៍ និងសហភាពសហគមន៍កសិកម្មចំនួន ១១ ត្រូវបានបង្កើតឡើងដោយសហគមន៍កសិកម្មដែលមានសមាជិកសហគមន៍កសិកម្មសរុបទាំងអស់ចំនួន ១៥១ជាសមាជិក។ គិតមក



ទល់ពេលនេះគឺពុំទាន់មានសហគមន៍កសិកម្មណាមួយដែលបានបង្កើតមុខរបរពាក់ព័ន្ធនឹងទេសចរណ៍ទេ។

ជាការកត់សម្គាល់ទោះបីមានសក្ដានុពលភាពទេសចរណ៍ក្ដីក៏ការបង្កើតទេសចរណ៍ធម្មជាតិបានជួបបញ្ហាប្រឈមមួយចំនួនមានជាអាទិ៍៖

១. ហេដ្ឋារចនាសម្ព័ន្ធ និងសមត្ថភាពដឹកជញ្ជូន មិនទាន់បង្កភាពងាយស្រួលដល់ភ្ញៀវទេសចរ។

២. សមត្ថភាពបដិសណ្ឋារកិច្ច ដូចជាភាសា កន្លែងស្នាក់នៅ ម្ហូបអាហារ បន្ទប់អនាមម័យ ទឹកស្អាត ការផ្សព្វផ្សាយអំពីទេសចរណ៍ឱ្យបានទូលលំទូលាយនៅមានកម្រិត។

៣. សហគមន៍ពឹងផ្អែកលើភ្នាក់ងារទេសចរណ៍ ហើយភ្នាក់ទេសចរណ៍មួយចំនួនមិនទាន់មានតម្លាភាព ក្នុងការបែងចែកផលប្រយោជន៍ជូនសហគមន៍ ដូចជាសហគមន៍នេសាទដែលជាអ្នកចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជួយថែរក្សាសម្បត្តិធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវទេសចរ។

៤. សហគមន៍មិនទាន់មានទុនគ្រប់គ្រាន់ និងជំនាញក្នុងការពង្រីកសកម្មភាពទេសចរណ៍ដែលមានការទាក់ទាញដោយបច្ចុប្បន្ន កន្លែងកម្សាន្តតាមសហគន៍នេសាទនៅពឹងផ្អែកតែលើធនធានធម្មជាតិដែលមាន ដោយបានខិតខំប្រឹងប្រែងថែរក្សា និងអភិរក្សដើម្បីទាក់ទាញភ្ញៀវទេសចរ ហើយជួនកាលក៏ទទួលរងនូវប្រធានស័ក្ដិ និងសម្ពាធពីការប្រែប្រួលអាកាសធាតុផងដែរ។ ម៉្យាងទៀត ចំណូលដែលសហគមន៍ទទួលបានពីទេសចរណ៍ធម្មជាតិនេះគឺនៅមានកម្រិត ពោលគឺសហគមន៍នៅតែពឹងផ្អែកលើថវិកាជំនួយឧបត្ថម្ភពីខាងក្រៅតែប៉ុណ្ណោះ។

៥. តំបន់ខ្លះមានដែនសមត្ថកិច្ចជាន់គ្នា មានជម្លោះរវាងសហគមន៍ និងសហគមន៍ សមត្ថកិច្ច និងសមត្ថកិច្ច ប្រជាជន សមត្ថកិច្ច និងក្រុមហ៊ុនជាដើម ដែលទាមទារឱ្យមានការដោះស្រាយ សម្របសម្រួលគ្នាជាចាំបាច់។

៦. សេវាកម្មភាគច្រើនផ្ដល់តែវិលល្ងាច និងមិនទាន់មានកន្លែងដែលអាចឱ្យភ្ញៀវស្នាក់នៅបានយូរប្រកបដោយការជឿទុកចិត្ត និងភាពកក់ក្ដៅ។

៧. មិនទាន់មានគោលការណ៍រួមជាផ្លូវការក្នុងការណែនាំស្ដីពីការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ និងតម្លាភាព។

## អគ្គពិធីទាំខម្ងូលជាទីមេត្រី

នៅក្នុងបរិការណ៍នៃការប្រយុទ្ធប្រឆាំងនឹងវិបត្តិនៃជំងឺកូវីដ-១៩ គិតមកទល់ពេលនេះរាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការចំនួន៦ជុំរួចមកហើយ ដែលក្នុងនោះក៏មានកញ្ចប់វិធានការក្នុងការលើកលែងការបង់ថ្លៃអាជ្ញាបណ្ណទេសចរណ៍គ្រប់ប្រភេទ និងការមិនធ្វើសវនកម្មពន្ធដារពេញលេញចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍រួមទាំងកញ្ចប់ថវិកាផ្នែកជំនួយសង្គមក្នុងវិស័យទេសចរណ៍ផងដែរ។ លើសពីនេះទៀត កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលក៏បានបញ្ចេញនូវថវិកាសន្សំប្រមាណ១៥០លានដុល្លារអាមេរិកទៀតសម្រាប់បម្រើឱ្យការវិនិយោគសាងសង់ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធផ្លូវមួយចំនួនក្នុងទីរួមខេត្តសៀមរាប ដើម្បីជួយធ្វើឱ្យទីក្រុងទេសចរណ៍ដ៏ល្បីល្បាញរបស់កម្ពុជានេះ កាន់តែមានភាពទាក់ទាញចំពោះភ្ញៀវទេសចរមកពីគ្រប់ទិសទីនៃពិភពលោក នៅក្រោយពេលវិបត្តិជំងឺកូវីដ-១៩ស្រាកស្រាន្តទៅវិញ។

ជាថ្មីម្ដងទៀត ខ្ញុំសង្ឃឹមថា ការរៀបចំអង្គវេទិកាជាតិដ៏មានសារៈសំខាន់នេះ គឺជាឱកាសមួយសម្រាប់យើងជួបជុំគ្នាដើម្បីពិនិត្យតាមដានអំពីវឌ្ឍនភាព កាលានុវត្តភាព បញ្ហាប្រឈមព្រមទាំងរួមគ្នារិះរកវិធានការដោះស្រាយប្រកបដោយគំនិតច្នៃប្រឌិត និងការបំពេញភារកិច្ចតាមគន្លងថ្មី ដើម្បីបញ្ចៀសការឆ្លងជំងឺដ៏កាចសាហាវកូវីដ-១៩ និងដើរទាន់ការវិវត្តនៃបច្ចេកវិទ្យាឌីជីថលនៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ នាពេលបច្ចុប្បន្នក្នុងបុព្វហេតុផ្ដល់ជាផលប្រយោជន៍រួម ដើម្បីជាពុទ្ធិក្នុងការចូលរួមចំណែកលើការងារគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងវិស័យកសិទេសចរណ៍ជារួម ដែលមានតួនាទីដ៏សំខាន់ក្នុងការជំរុញកិច្ចអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ និងការធានានូវចីរភាពបរិស្ថានសម្រាប់កូនចៅជំនាន់ក្រោយៗទៀត។

*សូមអរគុណ!*

# សុន្ទរកថា
## ឯកឧត្ដម វេង សាខុន
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារ អន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ក្នុងកម្មវិធីបិទអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**សូមគោរព ៖**

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ
- សមាជិក សមាជិកានៃអង្គវេទិកាជាទីមេត្រី



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាអនុប្រធានក្រុមការងារអន្តរក្រសួងគ្រប់គ្រង និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ក្នុងកម្មវិធីអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២*

បន្ទាប់ពីបានស្តាប់នូវរបាយការណ៍ស្តីពីលទ្ធផលនៃវេទិកាជាតិលើកទី១ និងរបាយការណ៍បូកសរុបវេទិកា និងសេចក្តីថ្លែងការណ៍លើកទី២ ស្តីពីការជំរុញការអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ថ្លែងដោយលោក ជុក ជំនោរ ប្រធានលេខាធិការដ្ឋាន( ក.គ.អ.អ ) និងលទ្ធផលនៃកិច្ចពិភាក្សាដែលអង្គវេទិកាបានរៀបរាប់ និងបកស្រាយយ៉ាងក្បោះក្បាយ ជាពិសេស ចំណាប់អារម្មណ៍ដ៏មានអត្ថន័យរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានក្រុមការងារ ក.គ.អ.អ រួចមក ខ្ញុំសូមសម្តែងនូវមូលវិចារណ៍ជាវិជ្ជមាន និងសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមផ្តល់នូវទស្សនវិស័យដ៏មានតម្លៃក្នុងន័យស្ថាបនាពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់ ក្នុងកិច្ចដំណើរការអភិវឌ្ឍវិស័យទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយភាពទាក់ទាញ ព្រមទាំងការរួមចំណែកអភិវឌ្ឍវិស័យកសិកម្ម និងការអភិរក្សធនធានធម្មជាតិប្រកបដោយភាតរបរិស្ថានផងដែរ។ នៅក្នុងស្មារតីនេះ ខ្ញុំសូមគូសបញ្ជាក់ជាថ្មីម្តងទៀត អំពីការប្តេជ្ញា និងសុឆន្ទៈរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងការបន្តកិច្ចសហការឱ្យកាន់តែជិតស្និទ្ធថែមទៀតតាមអភិក្រម “រដ្ឋ-ឯកជន-ដៃគូអភិ-វឌ្ឍន៍ និងសហគមន៍” ដើម្បីពង្រឹងភាពជាដៃគូ និងបង្កើតឡើងនូវបរិស្ថានអនុគ្រោះសម្រាប់កិច្ចការវិនិយោគវិស័យទេសចរណ៍អេកូទេសចរណ៍ ឆ្លើយតបទៅនឹងវិធានសុវត្ថិភាពទេសចរណ៍ ដោយមិនមើលរំលងគោលការណ៍ប្រឡងប្រណាំង “ទីក្រុងស្អាត រមនីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ” រួមទាំងវិស័យកសិកម្មផងដែរ ដើម្បីលើកកម្ពស់សេដ្ឋកិច្ចជាតិយើង ជីវភាពរស់នៅរបស់ប្រជាកសិករ បងប្អូននៅក្នុងសហគមន៍ដែលប្រកបមុខរបរកសិកម្មជាចម្បង ក្នុងបរិបទដែលប្រទេសជាតិយើងកំពុងទទួលរងនូវហានិភ័យពីវិបត្តិនៃការរាតត្បាតដោយជំងឺឆ្លងកូវីដ-១៩ និងចក្ខុវិស័យក្រោយវិបត្តិកូវីដ-១៩។

ពិតណាស់ថា ទោះបីការខិតខំស្រាវជ្រាវរកវ៉ាក់សាំង និងថ្នាំសម្រាប់ការពារ និងព្យាបាលជំងឺនេះកំពុងមានវឌ្ឍនភាពល្អគួរជាទីសង្ឃឹមក្តី តែគ្មាននរណាដឹងថា វិបត្តិជំងឺកូវីដ-១៩នេះនឹងបញ្ចប់នៅពេលណាពិតប្រាកដនោះឡើយ ហើយក៏គ្មាន



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងកម្មវិធីអង្គវេទិកាជាតិអេកូទេសចរណ៍លើកទី២ នៅសណ្ឋាគារសុខា ខេត្តសៀមរាប

នរណាអាចទស្សន៍ទាយ និងវាយតម្លៃអំពីផលប៉ះពាល់មកលើគ្រប់ទិដ្ឋភាពនៃជីវភាពរស់នៅរបស់សង្គមជាតិនីមួយៗបានជាក់ច្បាស់នោះដែរ។ ជាបច្ច័យ ស្ថានភាពនៃកំណើនសេដ្ឋកិច្ចពិភពលោកនៅក្នុងឆ្នាំ២០២០នេះ ត្រូវបានព្យាករណ៍ថា មានភាពថមថយដល់កម្រិតទាបបំផុតគិតចាប់តាំងពីសង្គ្រាមលោកលើកទី២មក។ ជាមួយគ្នានេះ ការប្រែប្រួលអាកាសធាតុ ក៏នៅតែជាបញ្ហាប្រឈមរបស់មនុស្សជាតិ និងប្រទេសនីមួយៗ ហើយក្នុងករណីខ្លះ ការប្រែប្រួលនៃអាកាសធាតុក៏បានបង្កើតជាជំងឺផ្សេងៗឥតឈប់ឈរដល់សត្តនិករយើងផងដែរ។

ដូចខ្ញុំបានជម្រាបជូនរួចហើយ នៅក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺយើងមានសហគមន៍នេសាទ សហគមន៍ព្រៃឈើ និងសហគមន៍កសិកម្ម។ នាពេលអនាគត សហគមន៍កសិកម្មមួយចំនួនអាចនឹងបង្កើតមុខរបរថ្មីមួយដែលហៅថា កសិទេសចរណ៍ សម្រាប់ផ្តល់ឱកាសដល់អ្នកទេសចរណ៍ក្នុងស្រុក និងបរទេសបានទៅទស្សនាកសិ-ដ្ឋានរបស់ប្រជាកសិករជាសមាជិកសហគមន៍កសិកម្ម។ កសិ-ដ្ឋាន ដែលសហគមន៍កសកិកម្មអាចផ្តល់ជាកន្លែងឱ្យអ្នកទេសចរណ៍ទៅទស្សនានោះរួមមាន កសិកដ្ឋានដំណាំស្រូវ កសិដ្ឋានដំណាំម្រេច កសិដ្ឋានដំណាំបន្លែ កសិដ្ឋានដំណាំស្វាយកែវរមៀត កសិដ្ឋានដំណាំស្វាយចន្ទី កសិដ្ឋានដំណាំមៀនប៉ៃលិន កសិដ្ឋានដំណាំកៅស៊ូ។ល។ ហេតុដូច្នេះ សហគមន៍កសិកម្មមួយចំនួន អាចក្លាយជា សហគមន៍កសិកម្មកសិទេសចរណ៍ នៅពេលអនាគត ប្រសិនបើសហគមន៍កសិកម្មចង់បង្កើតមុខរបរថ្មីស្តីពីកសិ-ទេសចរណ៍ នៅក្នុងសហគមន៍កសិកម្មរបស់ខ្លួនរួមទាំងសហគមន៍នេសាទ និងសហគមន៍ព្រៃឈើផងដែរ។

ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យទេសចរណ៍ឱ្យកាន់តែមានសន្ទុះរីកចម្រើនបន្ថែមទៀត ពិសេសក្នុងរលកថ្មីនៃការងើបឡើងវិញនៃការរីករាលដាលជំងឺកូវីដប្រភេទថ្មីនៅតាមបណ្តាប្រទេសមួយចំនួននៅលើពិភពលោក ដែលជាកត្តាធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចពិភពលោកស្ថិតក្នុងស្ថានភាពមិនច្បាស់លាស់តទៅទៀតនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមផ្តល់នូវចំណុចគន្លឹះមួយចំនួនដើម្បីជាមូលដ្ឋានជូនអង្គវេទិកាធ្វើការពិចារណាដូចតទៅៈ

ទី១- ត្រូវកសាង និងបណ្តុះបណ្តាលសមត្ថភាពបម្រើវិស័យទេសចរណ៍ដល់មន្ត្រី សហគមន៍ និងអ្នកពាក់ព័ន្ធដោយមិនមើលរំលងអំពីការបញ្ជ្រាបបច្ចេកវិទ្យាទំនើបប្រកបដោយភាពវៃឆ្លាត។ ទន្ទឹមនឹងនេះ ត្រូវកំណត់គោលការណ៍ណែនាំផ្លូវការស្តីពីការបែងចែកផលប្រយោជន៍ ឬផលលាភរវាងអ្នកពាក់ព័ន្ធ ដោយខិតខំកៀរគរដៃគូជួយអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសម្រាប់បម្រើវិស័យទេសចរណ៍ រួមទាំងកន្លែងកម្សាន្តរបស់សហគមន៍។ ត្រូវបង្កើតប្រភពហិរញ្ញប្បទាន ជាពិសេស បង្កើត mini -trust fund សម្រាប់សហគមន៍ ព្រមទាំងបន្តពង្រឹងសមត្ថភាពសហគន៍នេសាទដើម្បីគាំពារដល់ចីរភាពធនធានសម្រាប់បម្រើដល់វិស័យទេសចរណ៍ និងលើកទឹកចិត្តសហគមន៍ឱ្យទទួលបានមូលនិធិពីកម្មវិធីការបម្រែបម្រួលអាកាសធាតុ តាមរយៈការប្រឹងប្រែងការ-ពារព្រៃឈើ ព្រៃលិចទឹក ព្រៃកោងកាង និងគ្រប់គ្រងទឹកបម្រើដល់ការរស់រានមានជីវិតនៃទីជម្រកជីវៈចម្រុះនៅរដូវប្រាំង និងប្រធានស័ក្តិនានា ដូចជាករណីភ្លើងឆេះព្រៃជាដើម។

ទី២- ត្រូវគាំពារផ្តល់លទ្ធភាព និងសមត្ថភាពជំរុញសកម្មភាពកសិ-ទេសចរណ៍ ឬវិវឌ្ឍកម្មបម្រើទេសចរណ៍ក៏ដូចជាសកម្មភាពកសិកម្មផ្សេងទៀតដូចជា ផលិតកម្មបន្លែធម្មជាតិ បសុសត្វ សួនរុក្ខលម្អ(សួនផ្កាធំៗ) ជាដើម។ ដោយឡែក តំណាងអ្នកប្រើប្រាស់បន្លែសុវត្ថិភាព មានជាអាទិ៍ សហព័ន្ធទេសចរណ៍កម្ពុជា សមាគមភោជ-នីយដ្ឋានកម្ពុជា សមាគមចុងភៅកម្ពុជា និងសមាគមសណ្ឋាគារកម្ពុជា ត្រូវជួយគាំទ្រ និងផ្សព្វផ្សាយការបរិភោគបន្លែសុវត្ថិភាពកម្ពុជា ដើម្បីកាត់បន្ថយការ



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងកម្មវិធីវេទិកាជាតិ អេកូទេសចរណ៍លើកទី៧ នៅសណ្ឋាគារសុខា ខេត្តសៀមរាប

ប៉ះពាល់សុខភាព លើកកម្ពស់បន្លែកម្ពុជា និងជួយលើកស្ទួយផលិតផលរបស់កសិករកម្ពុជាប្រកបដោយគុណភាព។

ទី៣- ដើម្បីជំរុញ និងអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងកសិ-ទេសចរណ៍ តើអន្តរស្ថាប័នពាក់ព័ន្ធ និងអង្គភាពជំនាញត្រូវគិតគូរទៅលើសកម្មភាពអ្វីខ្លះជាចម្បង? ខ្ញុំយល់ថាត្រូវធ្វើការសិក្សាវិភាគពីកាលានុវត្តភាពថ្មីក្នុងដំណើរការរៀបចំផែនការសម្រាប់កម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ [សហគមន៍ទេសចរណ៍ (Community-based -CBT) សហគមន៍បានទទួលប្រយោជន៍ពីទេសចរណ៍ (Community Benefit through Tourism-CBT) និងទេសចរណ៍ធម្មជាតិ (Nature-based Tourism)] នៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ជាពិសេសនៅតាមតំបន់សហគមន៍ព្រៃឈើ សហគមន៍នេសាទនានា រួមទាំងការបំផុសស្មារតីឱ្យបងប្អូនចូលរួមថែរក្សាធនធានធម្មជាតិ ការប្រើប្រាស់ដីកសិកម្មប្រកបដោយភាពវៃឆ្លាតដើម្បីកាត់បន្ថយការបំផ្លាញព្រៃឈើ ព្រៃលិចទឹក និងការដាំដើមឈើឱ្យបានផុសផុលផងដែរ ក្នុងគោលដៅកាត់បន្ថយឱ្យបានពាក់កណ្ដាលនៃការបំផ្លាញព្រៃឈើនៅឆ្នាំ ២០៣០ ស្របទៅនឹងយុទ្ធសាស្ត្រ រ៉េដបូក (REDD+)។ ទន្ទឹមនឹងនេះ ក៏មិនត្រូវមើលរំលងអំពីកិច្ចសហការគ្នា ក្នុងការអភិរក្សត្រី សត្វស្លាប និងជីវៈចម្រុះដ៏សម្បូរបែបក្នុងតំបន់ការពារធម្មជាតិ ដើម្បីប្រែក្លាយតំបន់ទាំងនោះឱ្យទៅជាតំបន់បេតិកភណ្ឌទេស-ចរណ៍ធម្មជាតិប្រកបដោយភាពទាក់ទាញ។

ទី៤- គួរមានការរៀបចំគោលនយោបាយផ្ដល់ភាពអនុគ្រោះ និងលើកទឹកចិត្តក្នុងការកែច្នៃ និងកែលម្អធនធានធម្ម-ជាតិ នៅក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ ជាពិសេសនៅតាមតំបន់សហគមន៍ព្រៃឈើនានា ដែលជាប្រភពធនធានដ៏សំខាន់ និងមានសក្ដានុពលខ្ពស់សម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ធម្មជាតិ នៅកម្ពុជាតាមរយៈការវិនិយោគរបៀបសម្បទានចម្រុះ ជាមួយគ្រប់តួអង្គពាក់ព័ន្ធទាំងអស់។ ត្រូវលើកកម្ពស់ការកសាង និងបង្កើនសមត្ថភាពដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមផ្ដល់សេវាដោយផ្ទាល់ និងដោយប្រយោលក្នុងវិស័យទេសចរណ៍ធម្មជាតិ និងកសិ-ទេសចរណ៍ប្រកបដោយគុណភាព និងមានអនុស្សាវរីយ៍ទាក់ទាញឆ្លើយតបនឹងទ្រឹស្តី "ទូកទៅ កំពង់នៅ" ។

ទី៥- យើងទាំងអស់គ្នាត្រូវមានឆន្ទៈចូលរួមសហការរៀបចំកម្មវិធីកែលម្អការគ្រប់គ្រងសហគមន៍ បរិស្ថានស្អាត ដើម្បីផ្ដល់ឱកាសថែមទៀតដល់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ឱ្យចូលរួមគ្រប់គ្រងថែរក្សាបរិស្ថានស្អាតនៅតាមមូលដ្ឋានរបស់ខ្លួនប្រកបដោយភាពរស់រវើក ដើម្បី ទាក់ទាញភ្ញៀវទេសចរណ៍ធម្មជាតិ ទៅតាមលក្ខណៈពិសេស និងសក្ដានុពលក្នុងតំបន់រៀងៗខ្លួន ដោយផ្អែកលើវប្បធម៌ ប្រវត្តិសាស្ត្រ ធនធានធម្មជាតិ ស្ថាបត្យកម្ម។ល។ ដើម្បីប្រែក្លាយមូលដ្ឋានរបស់យើងទៅជាគោលដៅលេចធ្លោ ប្រកបដោយភាពទាក់ទាញ



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងកម្មវិធីវេទិកាជាតិ អេកូទេសចរណ៍លើកទី៧ នៅសណ្ឋាគារសុខា ខេត្តសៀមរាប




*សកម្មភាពទស្សនាពិព័រណ៍ក្នុងកម្មវិធីអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២ នៅសណ្ឋាគារសុខា ខេត្តសៀមរាប*

មានឧត្តមភាពប្រកួតប្រជែង និងផ្ដល់នូវភាពកក់ក្ដៅដល់ភ្ញៀវទេសចរណ៍គ្រប់ជាតិសាសន៍។

**អង្គពិធីឆាំងមូលជានីមេត្រី**

ខ្ញុំជឿជាក់ថា អង្គវេទិកាជាតិនាពេលនេះ ពុំត្រឹមតែជួយលើកកម្ពស់ការប្រាស្រ័យទាក់ទង និងកិច្ចសហប្រតិបត្តិការក្នុងចំណោមស្ថាប័នរបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធប៉ុណ្ណោះទេ ថែមទាំងផ្ដល់ឱកាសដល់យើងទាំងអស់គ្នាពិភាក្សាផ្លាស់ប្ដូរទស្សនៈដើម្បីស្វែងរកវិធីដោះស្រាយបញ្ហាប្រឈមនានាសំដៅឆ្ពោះទៅសម្រេចគោលដៅនៃការគ្រប់គ្រងអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍ប្រកបដោយចីរភាពតាមអភិក្រម រដ្ឋ-ឯកជន-ដៃគូអភិវឌ្ឍន៍ និងសហគមន៍ ដោយផ្សារភ្ជាប់ជាមួយក្រុមការងាររាជរដ្ឋាភិបាលដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលនីតិកាលទី៦ នៃរដ្ឋសភា ប្រកបដោយភាពម្ចាស់ការទទួលខុសត្រូវក្នុងបុព្វហេតុចូលរួមចំណែកយ៉ាងសកម្មក្នុងការបង្កើនល្បឿនដល់កំណើនសេដ្ឋកិច្ចជាតិ អភិវឌ្ឍន៍តំបន់ជនបទ ការបង្កើនសក្ដានុពលទេសចរណ៍ធម្មជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនឆ្លើយតបទៅនឹងគោលនយោបាយជាតិអេកូទេសចរណ៍២០១៩-២០៣០។ ទន្ទឹមនឹងនេះ អន្តរស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវជួយពិនិត្យ និងផ្ដល់យោបល់បន្ថែមទៀតឱ្យបានគ្រប់ជ្រុងជ្រោយ តើយើងត្រូវមានទស្សនវិស័យ យុទ្ធសាស្ត្រ និងផែនការយ៉ាងណាដើម្បីបង្កើនសក្ដានុពលវិស័យអេកូទេសចរណ៍ដើម្បីទាក់ទាញប្រជាពលរដ្ឋក្នុងប្រទេសដើរកម្សាន្តដោយរីករាយ ក្នុងដំណាក់កាលដែលប្រទេសជាតិយើងកំពុងទទួលរងវិបត្តិ និងក្រោយវិបត្តិកូវីដ-១៩ ឆ្លើយតបទៅនឹងទិសដៅដែលរាជរដ្ឋាភិបាលបានកំណត់ជាយូរមកហើយ អំពីការអភិវឌ្ឍវិស័យទេសចរណ៍កម្ពុជាថាជា “ទេសចរណ៍វប្បធម៌ និងធម្មជាតិ”។

ជាថ្មីម្ដងទៀត ខ្ញុំសង្ឃឹមថាការពិភាក្សាផ្លាស់ប្ដូរយោបល់នាពេលនេះប្រាកដជានឹងទទួលបាននូវធាតុចូលថ្មីៗថែមទៀតដើម្បីផលប្រយោជន៍សម្រាប់ប្រទេសជាតិ ប្រកបដោយបរិយា-ប័ន្នសម្រាប់យើងទាំងអស់គ្នា ពិសេសផលប្រយោជន៍រួមដល់ការអភិវឌ្ឍវិស័យកសិ-ទេសចរណ៍ និងវប្បធម៌ ដែលនឹងរួមចំណែកសំខាន់ដល់ការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ និងសហគមន៍មូលដ្ឋានជារួម។ ជាមួយនេះដែរ ក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ សូមស្វាគមន៍ក្នុងកិច្ចសហការជំរុញការគ្រប់គ្រង និងអភិវឌ្ឍរមនីយដ្ឋានទេសចរណ៍ធម្មជាតិនេះដោយក្ដីរីករាយ និងសូមជូនពរឱ្យអង្គអង្គវេទិកាជាតិ ប្រព្រឹត្តទៅដោយជោគជ័យ និងទទួលបាននូវលទ្ធផលជាផ្លែផ្កា ដោយផ្អែកលើទស្សនទាន “ប្រទេសច្រើន គោលដៅទេសចរណ៍តែមួយ” ដើម្បីបង្កើនសក្ដានុពលទីផ្សារទេសចរណ៍ក្នុងប្រទេសយើងឱ្យបានទូលំទូលាយប្រកបដោយភាតរបរិស្ថាន។

ជាទីបញ្ចប់ ជាមួយនឹងការអបអរសាទរនូវសមិទ្ធផលដែលអង្គវេទិកាជាតិ អេកូទេសចរណ៍លើកទី២ សម្រេចបានជាផ្លែផ្កាប្រកបដោយមោទនភាពនេះ ខ្ញុំសូមជូនពរបវរប្រសើរចំពោះគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ភ្ញៀវកិត្តិយសទាំងអស់ សូមប្រកបដោយដោយសិរីសួស្ដី ជ័យមង្គល វិបុលសុខ គ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។ **សូមអរគុណ!**

# សុន្ទរកថា
## ឯកឧត្តម វេង សាខុន
## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១

ថ្ងៃសុក្រ ៨រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
ទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១

- គណៈអធិបតី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា
- ភ្ញៀវកិត្តិយសជាតិ-អន្តរជាតិ សមាជិក-សមាជិកា នៃអង្គពិធីទាំងមូលជាទីមេត្រី!



ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ ២០២០ និងទិសដៅវិធានការឆ្នាំ២០២១

ថ្ងៃនេះ ខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមក្នុងពិធីបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១ នាពេលនេះ និង សូមថ្លែងអំណរគុណចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានឆ្លៀតឱកាសអញ្ជើញចូលរួមក្នុងពិធីបិទកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។ ជាមួយនេះដែរ ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយស្មារតីយកចិត្តទុកដាក់ មិនខ្លាចនឿយហត់ និងការលះបង់ខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលជលផល ដែលបានបំពេញភារកិច្ចរបស់ខ្លួនបានល្អប្រសើរក្នុងរយៈពេល ១ឆ្នាំកន្លងមកនេះ ដែលជាសក្ខីភាពមួយ បង្ហាញឱ្យឃើញ នូវការចូលរួមចំណែកក្នុងបុព្វហេតុនៃការលើកកម្ពស់វិស័យជលផលនៅកម្ពុជាឱ្យមានការរីកចម្រើនជាលំដាប់ប្រកបដោយមោទនភាព។

ប្រាកដណាស់ថា កិច្ចប្រជុំដែលបានប្រព្រឹត្តទៅអស់រយៈពេល២ថ្ងៃមកនេះ មិនត្រឹមតែជាឱកាសមួយសម្រាប់យើងទាំងអស់គ្នាចូលរួមពិភាក្សាចែករំលែកទស្សនៈនិងផ្តល់នូវធាតុចូលជាគំនិតថ្មីៗលើលទ្ធផលការងារ កាលានុវត្តភាព និងបញ្ហាប្រឈមផ្សេងៗដែលយើងបានជួបប្រទះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាឱកាស សម្រាប់យើងទាំងអស់គ្នាបូកសរុប និងវាយតម្លៃលើសមិទ្ធផល ដែលយើងសម្រេចបាន ក្នុងឆ្នាំកន្លងមក ព្រមទាំងរិះរកគ្រប់មធ្យោបាយដើម្បីកំណត់បណ្តាសកម្មភាពជាអាទិភាព ឈានឆ្ពោះទៅរក ការអភិវឌ្ឍវិស័យជលផលមួយឱ្យមានការរីកចម្រើនឆាប់រហ័សនិងប្រកបដោយចីរភាព។ ជាពិសេសនៅក្នុងបរិការណ៍មួយដែលប្រទេសជាតិយើងកំពុងខិតខំប្រឹងប្រែង ស្តារសេដ្ឋកិច្ច របស់ខ្លួនឡើងវិញក្រោយពីវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩។

**អង្គពិធីទាំងមូល ជាទីមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមរំឭកជូនថា ដោយសារប្រទេសជាតិយើងមានសុខសន្តិភាព និងស្ថិរភាពនយោបាយក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាន



*ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ថ្លែងក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសកម្មភាពការងារវិស័យជលផលប្រចាំឆ្នាំ ២០២០ និងទិសដៅវិធានការឆ្នាំ២០២១*

បង្កើតឱកាសមាសដែលពុំធ្លាប់មានដល់កម្ពុជា ក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ចជាតិ ឱ្យសម្រេចបានសមិទ្ធផល យ៉ាងធំធេងគួរជាទីមោទនៈ ក្នុងរយៈពេល ជាង២ទសវត្សរ៍ចុងក្រោយនេះ។ ដូច្នេះ សារៈសំខាន់របស់វិស័យកសិកម្មត្រូវបានស្តែងឱ្យឃើញ តាមរយៈក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាច្រើន ជាពិសេសយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដែលសុទ្ធតែឆ្លុះបញ្ចាំងឱ្យឃើញអំពីការជំរុញ និងការលើកស្ទួយវិស័យកសិកម្ម តាមរយៈការអនុវត្តកម្មវិធីអាទិភាពសំខាន់ៗទាំង៥ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលក្នុងនោះក៏មានកំណែទម្រង់ដីធ្លី ជលផល ព្រៃឈើ និងធនធានធម្មជាតិផងដែរ ដែលជាកត្តាគន្លឹះ សម្រាប់ការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការរួមចំណែកក្នុងការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនផលិតផលសរុបក្នុងស្រុក ឆ្លើយតបទៅនឹងគោលនយោបាយកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល។

គោលបំណងអភិវឌ្ឍន៍វិស័យជលផល គឺត្រូវបង្កើនការគ្រប់គ្រងធនធានជលផលឱ្យមានប្រសិទ្ធភាព និងនិរន្តរភាព ដោយពង្រឹងការអនុវត្តច្បាប់ស្តីពីជលផល បង្កើនផលវារីវប្បកម្មយ៉ាងតិច២០%ក្នុងមួយឆ្នាំ និងធ្វើឱ្យសហគមន៍នេសាទមានកម្រិតជីវភាពកាន់តែប្រសើរឡើង។ ម្យ៉ាងទៀត ក្នុងបរិបទវិបត្តិនៃការរីករាលដាលជំងឺកូវីដ-១៩ វិស័យធំៗ ដែលជាចលករជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដូចជាវិស័យឧស្សាហកម្ម និងសេវាកម្មមានការធ្លាក់ចុះ ប៉ុន្តែវិស័យកសិកម្មនៅតែជាវិស័យមួយដែលមានភាពបន្សាំទៅនឹងវិបត្តិនេះ និងនៅមានសក្តានុពលធំធេង សម្រាប់ការអភិវឌ្ឍ សេដ្ឋកិច្ចកសិកម្មនៅជនបទ។ ក្នុងន័យនេះ កម្ពុជាត្រូវច្បាមយកកាលានុភាពនៃវិស័យកសិកម្ម ដើម្បីរួមចំណែកដល់ការស្តារសេដ្ឋកិច្ចជាតិឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩។ ជាសក្ខីភាពផលិតផលក្នុងស្រុកសរុបរបស់វិស័យជលផលបានកើនឡើងប្រមាណ៤,១% ធៀបនឹងឆ្នាំមុន ពោលគឺបានកើនពី៥ ៥៣៧ ប៊ីលានរៀល នៅឆ្នាំ២០១៩ ដល់ ៥ ៧៦៣ ប៊ីលានរៀល នៅឆ្នាំ២០២០។

ដោយឡែក តាមរយៈរបាយការណ៍របស់ ឯកឧត្តម **ពុំ សុថា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល បានបង្ហាញឱ្យឃើញយ៉ាងច្បាស់ពីការងារដ៏លំបាកស្មុគស្មាញរបស់វិស័យជលផល និងការខិតខំប្រឹងប្រែងរបស់ឯកឧត្តម លោក លោកស្រី នាងកញ្ញា ទាំងអស់ក្នុងការជម្នះឧបសគ្គ នានា ដើម្បីសម្រេចបានលទ្ធផលដ៏ធំធេងនៅក្នុងឆ្នាំ២០២០នេះ ហើយសង្ឃឹមថាក្នុងឆ្នាំ២០២១ នឹងទទួលបានលទ្ធផលកាន់តែល្អប្រសើរថែមទៀត។ ម្យ៉ាងវិញទៀត ខ្ញុំអាចសន្និដ្ឋានជារួមបានថា ការគ្រប់គ្រងធនធានធម្មជាតិឱ្យមាននិរន្តរភាព គឺជាកិច្ចការមួយដែលមានលក្ខណៈលំបាកស្មុគស្មាញ មិនថាតែវិស័យជលផលទេ សូម្បីតែវិស័យព្រៃឈើក៏ដូចគ្នាដែរ។ បច្ចុប្បន្ននេះ យើងជ្រាបហើយថា បរិស្ថានធម្មជាតិតែងតែមានការប្រែប្រួល ចំនួនប្រជាជនក៏មានការកើនឡើងឥតឈប់ឈរពីមួយថ្ងៃទៅមួយថ្ងៃ សកម្មភាពបណ្តាលមកពីកត្តាមនុស្សរួមផ្សំផងនោះ ពិតជាបានដាក់សម្ពាធយ៉ាងខ្លាំងទៅលើធនធានធម្មជាតិ។ ទន្ទឹមនឹងនេះ យើងក៏ទទួលស្គាល់ថា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកផ្សេងៗទៀត ក៏បានជះឥទ្ធិពលជាអវិជ្ជមានមួយចំនួនដល់លំនឹងប្រព័ន្ធអេកូឡូស៊ីជលផលធម្មជាតិផងដែរ។

ឆ្លៀតក្នុងឱកាសនេះ ជាមួយនឹងការប្រកាសចូលកាន់តំណែងរបស់ឯកឧត្តម **ពុំ សុថា** ជាប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ខ្ញុំសូមផ្តល់នូវមតិណែនាំ និងផ្តាំផ្ញើមួយចំនួន ដើម្បីជាធាតុចូលសម្រាប់ដោះស្រាយនូវបញ្ហាប្រឈមដែលអង្គប្រជុំបានលើកឡើងដើម្បីជាមូលដ្ឋានជូនថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់អនុវត្តបន្តដូចតទៅ៖

ទី១. ត្រូវបន្តសិក្សាពីវិធីសាស្ត្របង្កើនផលវារីវប្បកម្ម



*ភ្ញៀវកិត្តិយសរអញ្ជើញចូលរួមក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១*

ឱ្យបានសកម្មថែមទៀតនៅក្នុងទូទាំងប្រទេសស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានលើកឡើងកាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ និងក្នុងឱកាសជួបសំណេះសំណាលជាមួយបងប្អូនវារីវប្បករនៅក្រោម «ដើមឈើចងចាំ» នៃមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជត្រីទឹកសាបបាទី និងការក្រើនរំឭកឱ្យយើងទាំងអស់គ្នាចងចាំអំពី «ការប្រែក្លាយខេត្តព្រៃវែងទៅជាអធិរាជត្រីអណ្តែង» កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ កន្លងមកនេះ។ ដូច្នេះត្រូវបង្កើនសមត្ថភាពបច្ចេកទេសវារីវប្បកម្មដល់មន្ត្រីជលផល និងប្រជាពលរដ្ឋទូទៅឱ្យបានកាន់តែប្រសើរឡើងថែមទៀត។ ទន្ទឹមនឹងនេះ ត្រូវលើកទឹកចិត្តដល់ផ្នែកឯកជនក្នុងការវិនិយោគ បង្កើតស្ថានីយ៍ ភ្ញាស់កូនត្រីពូជ កសិដ្ឋានចិញ្ចឹមត្រី រោងចក្រផលិតចំណីត្រី រោងចក្រកែច្នៃផល ផលិតផលជលផលដើម្បីកាត់បន្ថយការនាំចូល ព្រមទាំងការផ្សព្វផ្សាយបច្ចេកទេសវារីវប្បកម្ម ដល់វារីវប្បករឱ្យបានទូលំទូលាយក្នុងទូទាំងប្រទេស សម្របសម្រួលក្នុងការបង្កើតបណ្តុំកសិករតាមប្រភេទត្រីនៅតាមបណ្តាខេត្តនីមួយៗ និងត្រូវជំរុញការស្រាវជ្រាវវារីវប្បកម្មទឹកសាប សមុទ្រ និងអភិវឌ្ឍន៍វារីវប្បកម្មខ្នាតតូច មធ្យម និងធំ ដោយមិនត្រូវមើលរំលងអំពីការប្រមូលស្ថិតិវារីវប្បកម្មក្នុងប្រទេសប្រកបដោយសុក្រឹតភាពតាមអភិក្រម «រដ្ឋ-ឯកជន-ដៃគូអភិ-វឌ្ឍន៍ និងសហគមន៍» ។

ទី២. ត្រូវពង្រឹងការទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលឱ្យបានហ្មត់ចត់ និងខិតខំស្វែងរកដៃគូអភិវឌ្ឍន៍ក្នុងការជួយជាមធ្យោបាយ ការងារបច្ចេកទេស ការសិក្សាស្រាវជ្រាវ និងការឧបត្ថម្ភសម្ភារ ឬថវិកាបន្ថែមលើថវិកាជាតិដែលនៅមានកម្រិត។ ចំពោះការនេសាទសមុទ្រ ទូកនេសាទទាំងអស់ត្រូវជំរុញការចុះបញ្ជី និងត្រូវមានលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម។ ទន្ទឹមនឹងនេះ ត្រូវពង្រឹងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ ដោយត្រូវសហការជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងស្ថាប័នតុលាការ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល ដែលកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានោះដែរ ត្រូវផ្សព្វផ្សាយអំពីលិខិតគតិយុត្តពាក់ព័ន្ធនានា ដល់ប្រជាពលរដ្ឋឱ្យបានយល់ច្បាស់អំពីផលអវិជ្ជមាននៃការនេសាទល្មើសច្បាប់ និងត្រូវពង្រឹងវិន័យដល់មន្ត្រីឱ្យជៀសវាងការឃុបឃិតជាមួយជនល្មើស ទោះជាក្នុងរូបភាពណាក៏ដោយ។ ត្រូវបន្តជំរុញការកែសម្រួលច្បាប់ស្តីពីជលផល និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ ក្នុងបរិបទនៃតំបន់ភាវូបនីយកម្ម ដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់ ទន្ទឹមនឹងការគ្រប់គ្រង និងត្រួតពិនិត្យជលផលទឹកសាប និងសមុទ្រឱ្យមាននិរន្តរភាព។

ទី៣. ត្រូវខិតខំសហការជាមួយគណៈបញ្ជាការឯកភាពខេត្ត និងស្រុក ជួយទប់ស្កាត់ និងបង្ក្រាបការកាប់រាន ការដុត ការឈូសឆាយ និងការហ៊ុមព័ទ្ធទន្រ្ទានព្រៃលិចទឹក និងព្រៃកោងកាងធ្វើជាកម្មសិទ្ធិក្នុងស្មារតីទទួលខុសត្រូវ។ ជាងនេះទៀត តំបន់ព្រៃលិចទឹក និងព្រៃកោងកាងទាំងនោះ ត្រូវរៀបចំផែនទី និងបន្តបោះបង្គោលព្រំប្រទល់ឱ្យបានច្បាស់លាស់ ហើយបន្តខិតខំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃព្រៃលិចទឹក និងព្រៃកោងកាង និងការប្រើប្រាស់ប្រភេទឧបករណ៍នេសាទគ្រួសារក្នុងតំបន់ដែននេសាទទឹកសាប និងសមុទ្រឱ្យបានត្រឹមត្រូវតាមបច្ចេកទេស។ ម្យ៉ាងវិញទៀត ត្រូវជំរុញការចុះបញ្ជីទូកនេសាទសមុទ្រដែលប្រើប្រាស់ឧបករណ៍នេសាទសិប្បកម្ម ដើម្បីធ្វើការប្រមូលថ្លៃឈ្នួលជូនរដ្ឋ។

ទី៤. ត្រូវបន្តខិតខំពង្រឹងសមត្ថភាពរបស់សហគមន៍នេសាទ ឱ្យក្លាយជាសហគមន៍នេសាទ មានភាពម្ចាស់ការដំណើរការល្អ រឹងមាំ សកម្មក្នុងការគ្រប់គ្រង អភិរក្សធនធានជលផលប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងមានមុខរបរចម្រុះចិញ្ចឹមជីវិតដើម្បីប្រែក្លាយជា «សហគមន៍នេសាទគំរូ និងគ្មានបទល្មើសជលផល» តាមរយៈការជំរុញកិច្ចសហការ



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១

ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការគ្រប់គ្រង អភិវឌ្ឍន៍ និងអភិរក្សធនធានជលផលនៅថ្នាក់ក្រោមជាតិ ដោយគាំទ្រ និងផ្ដល់ឱកាសឱ្យសហគមន៍នេសាទមានប្រភពថវិកាសម្រាប់ដំណើរការសហគមន៍ប្រកបដោយនិរន្តរភាពតាមរយៈការធ្វើវារីវប្បកម្មចម្រុះក្នុងកន្លែងនេសាទសហគមន៍ ស្រាវជ្រាវស្ថានភាពសេដ្ឋកិច្ចសង្គម ដើម្បីកំណត់សក្ដានុពលភាពមុខរបរចិញ្ចឹមជីវិត ព្រមទាំងសម្របសម្រួលរៀបចំ និងជំរុញការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដោយត្រូវចុះបញ្ជីសហគមន៍នេសាទ ឱ្យបានត្រឹមត្រូវដើម្បីប្រែក្លាយសហគមន៍ទាំងនោះឱ្យទៅជាតំបន់ទេសចរណ៍ធម្មជាតិដ៏ស្រស់ត្រកាល ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជានេសាទនៅតាមសហគមន៍នេសាទមូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង។

ទី៥. ត្រូវយកចិត្តទុកដាក់ការពារកន្លែងអភិរក្សជលផលឱ្យបានគង់វង្សល្អ ដោយបន្តបោះបង្គោលព្រំប្រទល់កន្លែងអភិរក្សជលផល សាងសង់ស្លាក់ការល្បាត ទម្លាក់ប្រអប់បេតុងដើម្បីបង្កើនជម្រកត្រី រៀបចំក្រុមយាមការពារកន្លែងអភិរក្ស និងទប់ស្កាត់បទល្មើសដោយត្រូវសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ព្រមទាំងបន្តផ្សព្វផ្សាយពីផលប៉ះពាល់ដែលបណ្ដាលមកពីការប្រើប្រាស់ជី និងថ្នាំកសិកម្មផ្សេងៗ ដែលមិនសមស្របតាមបច្ចេកទេសនាំឱ្យវិនាសហិនហោចដល់ធនធានជលផល និងត្រូវរៀបចំកន្លែងអភិរក្សឱ្យបានច្រើនកន្លែងថែមទៀតទាំងទឹកសាប និងសមុទ្រ ព្រមទាំងដាក់វិធានការមុតស្រួចក្នុងទប់ស្កាត់ភ្លើងឆេះព្រៃលិចទឹកផងដែរ។ ជាមួយនេះ ត្រូវយកចិត្តទុកដាក់ជំរុញការដាំព្រៃលិចទឹក និងព្រៃកោងកាងឱ្យបានផុសផុលបន្ថែមទៀត ដើម្បីប្រែក្លាយកន្លែងដែលបាត់បង់ព្រៃទៅជាជម្រកវារីសត្វគ្រប់ប្រភេទដ៏ល្អស្រស់បំព្រង។ ម្យ៉ាងទៀត ត្រូវបន្តការសិក្សាតំបន់កោះ ឬតំបន់ផ្កាថ្ម ស្មៅសមុទ្រ ដែលមានសក្ដានុពលខ្ពស់ ដើម្បីបង្កើតជាតំបន់គ្រប់គ្រងជលផលសមុទ្រ ក្នុងន័យការពារបរិស្ថានជលផលសមុទ្រឱ្យបានគង់វង្សល្អ និងទាក់ទាញភ្ញៀវទេសចរណ៍បរទេសមកទស្សនាសមុទ្ររបស់យើងផងដែរ។ ត្រូវមានវិធានការតឹងរ៉ឹងបំផុតរាល់ការធ្វើពាណិជ្ជកម្ម ប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់ ដោយអនុវត្តយុទ្ធសាស្ត្រ អភិរក្ស និងបង្កើនផលស្តុកឡើងវិញជាជំហានៗ។

ទី៦. ត្រូវបន្តជំរុញការអភិវឌ្ឍខ្សែច្រវាក់តម្លៃជលផលឱ្យកាន់តែល្អប្រសើរបន្ថែមទៀត និងពង្រឹងសមត្ថភាព អង្គភាពជំនាញក្នុងការតាមដាន ត្រួតពិនិត្យគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល តាមរយៈការខិតខំកសាងបទដ្ឋានគតិយុត្ត និងហេដ្ឋារចនាសម្ព័ន្ធដែលចាំបាច់ ពិសេសការយកចិត្តទុកដាក់លើការកសាងសមត្ថភាពរបស់មន្ត្រីជំនាញ ដើម្បីអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងការទប់ស្កាត់រាល់ការធ្វើពាណិជ្ជកម្មលើផល ផលិតផលជលផលដែលមិនស្របច្បាប់ ខូចគុណភាព ឬមិនមានសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ ព្រមទាំងយកចិត្តទុកដាក់ពង្រឹងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនានាក្នុងវិស័យឯកជនឱ្យកាន់តែយល់ច្បាស់ពីសារៈសំខាន់នៃការអនុវត្តតាមគោលការណ៍បច្ចេកទេសស្ដីពីការអនុវត្តអនាម័យល្អ (GHP) ការអនុវត្តផលិតកម្មល្អ (GMP) និងការអនុវត្តវារីវប្បកម្មល្អ (GAP) ក្នុងទិសដៅលើកកម្ពស់ផលិតកម្មក្នុងស្រុកប្រកបដោយស្តង់ដារគុណភាព សុវត្ថិភាព ដើម្បីចូលរួមចំណែកការពារសុខភាពសាធារណៈ និងជំរុញការនាំចេញផល ផលិតផលជលផលកម្ពុជាទៅកាន់ទីផ្សារអន្តរជាតិកាន់តែទូលំទូលាយ និងកាត់បន្ថយការនាំចូល។ ទន្ទឹមនឹងនេះ រដ្ឋបាលជលផលត្រូវសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធ ដើម្បីដោះស្រាយនូវសំណូមពរដែលបានលើកឡើង។

## អនុពិធីផ្ទាំងមូលជាទីមេត្រី

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំចង់ទាញអារម្មណ៍ពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាជ្រាបថា ការតែងតាំង និងការផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការគឺជាដំណើរការប្រព្រឹត្តជាធម្មតា នៃការគ្រប់គ្រងនិងដឹកនាំរបស់



ភ្ញៀវកិត្តិយសអញ្ជើញចូលរួមក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១

ក្រសួងស្ថាប័ន ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល ស្របតាមតម្រូវការចាំបាច់ នៃកំណែទម្រង់ស្ថាប័ន ការរីកចម្រើននៃសមត្ថភាពមន្ត្រីរាជការបន្តវេន និងការរីកចម្រើននៃសេដ្ឋកិច្ចទៅតាមដំណាក់នីមួយៗ។ ការប្រកាសចូលកាន់តំណែងថ្នាក់ដឹកនាំនាពេលនេះ ពិតជាស្តែងចេញនូវការខិតខំប្រឹងប្រែង និងស្នាដៃ ដែលយើងទាំងអស់គ្នាបានចំណាយទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ កន្លងមកផងដែរ។ បន្ថែមពីលើអនុសាសន៍ដែលបានរៀបរាប់ខាងលើ ខ្ញុំសូមលើកនូវការណែនាំមួយចំនួនទៀតជូនអង្គពិធីក៏ដូចជាអង្គភាពជំនាញក្រោមឱវាទទាំងអស់ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យបានសកម្មនូវចំណុចគន្លឹះដូចតទៅ៖

ទី១-ត្រូវប្រកាន់ខ្ជាប់នូវស្មារតីសាមគ្គីភាពឯកភាពផ្ទៃក្នុងខ្ពស់ក្នុងការបំពេញភារកិច្ចព្រមទាំងប្រគល់ការងារតាមសមត្ថភាព និងទប់ស្កាត់រាល់សកម្មភាពបំបែកបំបាក់ផ្ទៃក្នុង ក៏ដូចជាការគ្រប់គ្រងលើមន្ត្រីរាជការប្រកបដោយសមធម៌ និងយុត្តិធម៌។ ទន្ទឹមនឹងនេះត្រូវអនុវត្តឱ្យបានជាប្រចាំ និងប្រកបដោយប្រសិទ្ធភាព នូវក្រមសីលធម៌មន្ត្រីរាជការ លើការគ្រប់គ្រងដឹកនាំក្នុងការបំពេញភារកិច្ច ដូចមានចែងក្នុងជំពូកទី៥ មាត្រា៣៣ ដល់មាត្រា៣៨ ក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។ ជាមួយគ្នានេះគឺមិនត្រូវយកតួនាទីរបស់ខ្លួនធ្វើជាខ្នងបង្អែក និងបក្សពួកខ្លួនណាមួយឡើយ។ មិនត្រូវលាបពណ៌គ្នាឯង ជាពិសេសមន្ត្រីនៅថ្នាក់ក្រោមបន្ទុករបស់ខ្លួន មិនមើលបំណាំគ្នា និងស្តាប់យោបល់ថ្នាក់ក្រោមបង្គាប់ ដោយអនុវត្តគោលការណ៍«សមូហភាពដឹកនាំ បុគ្គលទទួលខុសត្រូវ»។ មិនត្រូវអនុវត្តទ្រឹស្តី ដុតឱ្យខ្លោច រោចឱ្យឆៅនោះទេ ពោលគឺត្រូវជៀសវាងនូវការបំបែកបំបាក់ផ្ទៃក្នុង និងមិនកេងចំណេញយកផលប្រយោជន៍សម្រាប់បុគ្គលខ្លួន។

ទី២-ខ្ញុំសូមឱ្យឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា មន្ត្រីរាជការទាំងអស់ ត្រូវតែទទួលស្គាល់ និងចងចាំថា មិនត្រូវមានមោទនភាពខ្លួនឯងជ្រុលនោះទេ ថ្វីត្បិតតែយើងមានចំណេះដឹង បទពិសោធន៍ខ្លះៗក៏ដោយ ប៉ុន្តែកត្តាចាំបាច់មួយចំនួនទៀត ដែលសំខាន់និងមិនអាចខ្វះបាននោះ គឺការយកចិត្តទុកដាក់ និងពុះពារជម្នះនូវឧបសគ្គការងារអំណត់អត់ធន់ ទន់ភ្លន់តែម៉ឺងម៉ាត់ និងរៀនសូត្រដកស្រង់បទពិសោធន៍ពីការងារ ដែលយើងធ្លាប់ជួបប្រទះ។ ជាពិសេសត្រូវខិតខំហាត់ពត់លត់ដំខ្លួនបន្ថែមទៀត ដើម្បីឱ្យក្លាយខ្លួនទៅជាអ្នកដឹកនាំដែលមានគំរូល្អ មានសាមគ្គីភាព ឯកភាពផ្ទៃក្នុងល្អ និងជាក្តីសង្ឃឹមជឿជាក់ប្រកបដោយភាពកក់ក្តៅដល់មន្ត្រីរាជការក្រោមឱវាទ។

ទី៣-ទាំងថ្នាក់ដឹកនាំនិងមន្ត្រីរាជការទាំងអស់ ត្រូវខិតខំបំពេញការងារដោយគោរពឱ្យបាននូវគុណសម្បត្តិនៃឥរិយាបថរបស់មន្ត្រីរាជការតាមចំណុចគន្លឹះដូចជា៖ ១-ការផ្តល់សេវាសាធារណៈ គឺត្រូវមាន «ចរិកមហាជន» ដែលមានភាពប៉ិនប្រសព្វក្នុងការទំនាក់ទំនង ដើម្បីចែករំលែកនូវចំណេះដឹងបច្ចេកទេសថ្មីៗ និងបទពិសោធន៍ល្អៗ។ ២-ឆន្ទៈម្ចាស់ការ ៖ ត្រូវមានទឹកចិត្តស្រឡាញ់ការងារ មានគំនិតផ្តួចផ្តើម



ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញប្រគល់សេចក្តីប្រកាស ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការ ឆ្នាំ២០២១





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញប្រគល់សេចក្ដីប្រកាស ក្នុងឱកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការ ឆ្នាំ២០២១

និងច្នៃប្រឌិត បំពេញកាតព្វកិច្ចក្នុងស្មារតីជាក្រុមមានស្មារតីឈ្មុសឈ្មុលក្នុងការងារ និងជម្នះគ្រប់ឧបសគ្គ ។ ៣-ភក្ដីភាពចំពោះស្ថាប័ន ភក្ដីភាពចំពោះវិជ្ជាជីវៈ និងភក្ដីភាពចំពោះប្រជាជនដែលទទួលប្រើប្រាស់សេវាពីយើង និង៤-មនសិការវិជ្ជាជីវៈ ៖ ត្រូវស្និតស្នាញការងារជាមួយគ្នា និងសម្រេចលទ្ធផលការងារជាមួយគ្នាឱ្យបានត្រឹមត្រូវដើម្បីផលប្រយោជន៍សាធារណៈ ត្រូវបង្កើនសមត្ថភាពជំនាញ អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនឱ្យទាន់សភាពការណ៍ ត្រូវគោរពពេលវេលាធ្វើការ ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ ប្រកាន់ខ្ជាប់នូវកាតព្វកិច្ចលក្ខណការណ៍ គឺមិននិយាយឬសរសេរពីអ្វីដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងកិត្យានុភាពរបស់អង្គភាព ឬសមត្ថកិច្ចថ្នាក់ដឹកនាំរបស់ខ្លួន ពោលគឺត្រូវទទួលខុសត្រូវលើការប្រតិបត្តិរបស់ខ្លួនចំពោះភារកិច្ចដែលអង្គភាពប្រគល់ឱ្យ។

ជាថ្មីម្ដងទៀត ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា និងអង្គពិធីទាំងមូលនឹងយកអស់ស្មារតី កម្លាំងកាយចិត្តបន្តនូវកិច្ចខិតខំប្រឹងប្រែងចូលរួមអនុវត្តឱ្យបានសកម្មថែមទៀត តាមចំណុចគន្លឹះទាំងឡាយដែលបានលើកឡើង ក៏ដូចជាការប្ដេជ្ញាចិត្តរបស់ឯកឧត្តម **ពុំ សុធា** ក្នុងការបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ ព្រមទាំងចែករំលែកព័ត៌មាន ចំណេះដឹង និងបទពិសោធន៍នានាដែលទទួលបាននេះ ជូនដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ដើម្បីធ្វើការកែលម្អ និងអនុវត្តការងារឱ្យបានកាន់តែល្អប្រសើរ សំដៅសម្រេចឱ្យបាននូវសមិទ្ធផលថ្មីៗ ថែមទៀតសមស្របតាមចក្ខុវិស័យ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល ដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ចជាតិ ធានាសមធម៌ ធានាសន្តិសុខស្បៀង ការកាត់បន្ថយភាពក្រីក្រ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទប្រកបដោយចីរភាព ក្នុងបរិបទនៃការប្រែប្រួលប្រកបដោយភាពវៃឆ្លាតនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងឌីជីថលភាវូបនីយកម្ម។

ទន្ទឹមនឹងនេះ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការល្អ និងការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ដែលបានរួមចំណែកយ៉ាងសកម្មក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយនិរន្តរភាព ជាពិសេសការបង្ក្រាបបទល្មើសជលផលតាមគ្រប់រូបភាពឱ្យទទួលបានលទ្ធផលល្អប្រសើរ។

ជាទីបញ្ចប់ ជាមួយនឹងការប្រកាសបិទកិច្ចប្រជុំបូកសរុបសភាពការណ៍វិស័យជលផលប្រចាំឆ្នាំ២០២០ និងទិសដៅវិធានការឆ្នាំ២០២១ ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ សូមទទួលនូវពុទ្ធពរទាំង ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**



# បច្ចេកទេសដាំកៅស៊ូលក្ខណៈគ្រួសារ

ដោយ ៖ អគ្គនាយកដ្ឋានកៅស៊ូ

បន្តពីទស្សនាវដ្ដីកសិកម្មលេខ៧៦

## ២.៣ ចន្លោះរង (ខ្នាតដាំ) និងដង់ស៊ីតេ

ការជ្រើសរើសចន្លោះរងសម្រាប់ដាំកៅស៊ូ អាស្រ័យលើសណ្ឋានដីនៃចម្ការ និងលទ្ធភាពដែលអាចដាំដំណាំចន្លោះរងបាន។ ចន្លោះរងសម្រាប់ដាំដុះកៅស៊ូមានដូចខាងក្រោម៖

| សណ្ឋានដី | ចន្លោះរង | ចំនួនដើម/ហ.ត |
|---|---|---|
| តំបន់ភ្នំ (ដាំជាថ្នាក់តាមនីវ៉ូដី) | ៩.០ x ២,៥ | ៤៤៤ |
| | ៨,០x ២,៥ | ៥០០ |
| | ១០,០ x ២,០ | ៥០០ |
| | ៨,០ x ៣.០ | ៤១៦ |
| តំបន់រៀបស្មើ ឬចំណោតទាប | ៥,០ x ៤,០ | ៥០០ |
| | ៦,០ x ៣,០ | ៥៥៥ |
| | ៧,០ x ៣.០ | ៤៧៦ |
| វិធីដាំជួរភ្លោះជាលក្ខណៈ | ៣,០ x ២,៥ x១៣ | ៥០០ |

នៅប្រទេសកម្ពុជាយើងគេនិយមអនុវត្តចន្លោះរងដាំដុះ ៦ម x ៣ម ស្មើនឹង៥៥៥ដើម/ហិកតា។

## ២.៤ ការបោះបង្គោលតម្រុយតំបន់ដីរាបស្មើ

រងកៅស៊ូ តែងតែត្រូវបានបោះពីទិសខាងកើត ទៅលិច ដើម្បីឱ្យកៅស៊ូ អាចទទួលបានពន្លឺគ្រប់គ្រាន់។ ជំហានក្នុងការបោះបង្គោលតម្រុយមានដូចខាងក្រោម៖

- បន្ទាប់ព្រំគោលលាតសន្ធឹង ពីទិសខាងកើតទៅខាងលិចត្រូវបានកំណត់ជាគោល
- វាស់ និងកំណត់មុំ ៩០ដឺក្រេ ដោយប្រើម៉ែត្រប្រវែង ៣ម៉ែត្រ ៤ម៉ែត្រ និង៥ម៉ែត្រ នៅចុងសងខាងនៃព្រំគោល
- ចន្លោះរង និងចន្លោះដើម ត្រូវវាស់តាមបន្ទាត់ ជាមុំ ៩០ដឺក្រេ
- ចន្លោះដើមនៃកូនកៅស៊ូ ត្រូវអនុវត្តតាមខ្សែបន្ទាត់មុំ៩០ដឺក្រេ
- វាស់ប្រវែងចន្លោះដើមនីមួយៗក្នុងជួរតាមគំនូសព្រាងរហូតដល់បញ្ចប់ក្នុងចម្ការទាំងមូល។











ការបោះបង្គោលក្នុងតំបន់រាបស្មើ

## ២.៥ ការបោះបង្គោលតម្រុយលើសណ្ឋានដីមានចំណោត

ការដាំដុះតាមវណ្ឌ (ជាថ្នាក់ៗ) ត្រូវបានអនុវត្តនៅតំបន់សណ្ឋានដីមានចំណោត មានជម្រាលមុំធំជាង ២០ដឺក្រេ ដោយដាំដុះតាមបន្ទាត់កាត់ទទឹងចំណោត។ ជម្រាលសមស្របនៃវណ្ឌ ត្រូវបានជ្រើសរើសដោយបែងចែកជម្រាលជាថ្នាក់ៗទៅតាមប្រវែងចន្លោះរងកោស៊ូ។ ឧបករណ៍ស្ទង់រាងអក្សរ A ត្រូវបានគេប្រើប្រាស់ ដើម្បីកំណត់ទីតាំងវណ្ឌតាមជម្រាល។



ឧបករណ៍ស្ទង់រាងអក្សរ (A) សម្រាប់បោះបង្គោលនៅលើតំបន់ភ្នំ

បន្ទាប់ពីបានបង្កើតបន្ទាត់វណ្ឌ លើជម្រាលរួចមកត្រូវកាប់កន្លែងដែលត្រូវដាំឱ្យរាបស្មើ។ ផ្ទៃរាបស្មើគឺមានសារៈសំខាន់សម្រាប់តំបន់ភ្នំ ព្រោះវាអាចទប់ស្កាត់ការហូរច្រោះដី និងងាយស្រួលក្នុងការចៀរជ័រ។ ដើម្បីបង្កើតផ្ទៃរាបស្មើនៃជម្រាលគឺត្រូវកាប់ដីប្រវែងពី ១,០ ទៅ ១,៥ម ពីបង្គោលរណ្ដៅដាំកូនកៅស៊ូទៅទីខ្ពស់នៃផ្ទៃជម្រាល និងកាប់ជម្រៅពី ២៥-៥០ ស.ម. ពីទីខ្ពស់នៃផ្ទៃជម្រាលទៅផ្ទៃរាបស្មើ។




ការបង្កើតផ្ទៃរាបស្មើដោយរពង្រាបដី

## ២.៦ ការជីករណ្ដៅ

ទំហំរណ្ដៅភាគច្រើនពឹងផ្អែកទាំងស្រុងលើលក្ខខណ្ឌដី និងរុក្ខសម្ភារ (ប្រភេទកូនកៅស៊ូ)។ រណ្ដៅដាំត្រូវមានទំហំ ៦០ស.ម x ៦០ស.ម x ៦០ស.ម។ តាមធម្មតាគេត្រូវជីករណ្ដៅយ៉ាងតិច ១ខែ ឬ២ខែមុនពេលដាំ ដែលជាទូទៅការជីករណ្ដៅចាប់ផ្ដើមពីខែមេសា។

## ២.៧ ការដាំដុះ

កូនកៅស៊ូដែលត្រូវយកទៅដាំត្រូវមានស្លឹក ១ផ្ទៃពណ៌បៃតងក្រម៉ៅ (ស្លឹកចាស់ល្អ)។ ការដាំដុះត្រូវធ្វើនៅរដូវវស្សាចាប់ពីចុង ខែឧសភា ដល់ខែសីហា។ ការដាំដុះត្រូវអនុវត្តជាបន្តបន្ទាប់ដូចខាងក្រោម៖

- កាយដីស្តារបាតរណ្ដៅឱ្យបានជម្រៅយ៉ាងតិច ៥០ ស.ម (ដីស្រទាប់លើទុកផ្នែកម្ខាងដីស្រទាប់ក្រោមទុកទៅម្ខាង)
- ច្របល់ដីស្រទាប់លើជាមួយជី NPK ចំនួន ១០០ ក្រាមក្នុង១រណ្ដៅ
- ប្រើកាំបិតមុតកាត់បាតថង់កម្រាស់២ស.មពីបាតថង់ (ត្រូវជៀសវាងកុំឱ្យប៉ះភ្នែកបំប៉ៅ)
- ដាក់កូនកៅស៊ូចំកណ្ដាលរណ្ដៅ ដោយប្រុងប្រយ័ត្ន និងបែរភ្នែកបំប៉ៅទៅទិសនិរតី
- ទុកភ្នែកបំប៉ៅកម្ពស់ ២ស.ម (ប្រហែល ២ធ្នាប់ដៃ) ពីមាត់រណ្ដៅ
- ប្រើកាំបិតមុតវះ ១/៣ ពីបាតថង់ ចាប់លាត់ពីក្រោមឡើងលើដោយប្រុងប្រយ័ត្ន កុំឱ្យបែកដីចេញពីឫសបន្ទាប់មកលុបដី ដែលបានលាយជីដាក់ចូលរណ្ដៅរួចជាន់ឱ្យហាប់ណែនល្អ
- វះ ២/៣ នៃថង់ដែលនៅសល់ ចាប់លាត់ថង់ដោយថ្នមៗចេញទាំងស្រុង ហើយប្រមូលថង់ និងបាតថង់ទុកមួយឡែក
- លុបបំពេញរណ្ដៅ និងជាន់ឱ្យហាប់ណែនល្អ ដោយកុំឱ្យប៉ះដីក្នុងថង់ និងធ្វើមាត់រណ្ដៅជារាងបាតខ្ទះ
- ដោតក្បាំងឬស្សីចំងាយប្រមាណ១៥ស.ម ទៅ ២០ ស.ម ពីខាងមុខភ្នែកបំប៉ៅ
- ប្រមូលសំបកថង់ និងបាតថង់ចេញពីចម្ការ។

## III. ការថែទាំកៅស៊ូមិនទាន់ផ្ដល់ផល

### ៣.១ ការដាំជួស

កូនកៅស៊ូដែលងាប់ត្រូវដាំជួសឡើងវិញនៅឆ្នាំទី១ ឬឆ្នាំទី២បន្ទាប់ពីការដាំដំបូង។ កូនកៅស៊ូដែលល្អសម្រាប់ការដាំជួស គឺជាកូនស្ទុមដែលមានកម្ពស់ខ្ពស់ ឬកូនក្នុងថង់ដែលមានទំហំ និងអាយុប្រហាក់ប្រហែលគ្នាជាមួយកូនកៅស៊ូដែលបានដាំឆ្នាំដំបូង។ បច្ចុប្បន្ននេះគេនិយមយកកូនកៅស៊ូ១ ឬ២ ធ័ត្រសម្រាប់ធ្វើការដាំជួស។

### ៣.២ ការដាក់ជី

ការដាក់ជីត្រូវចាប់ផ្ដើមតាំងពីកូនកៅស៊ូនៅតូច ដើម្បីឱ្យវាដុះលូតលាស់បានល្អ លប់លើស្មៅ និងរុក្ខជាតិចង្រៃផ្សេងៗទៀត។ បីឆ្នាំដំបូងនៃការដាំដុះកៅស៊ូជាដំណាក់កាលសំខាន់បំផុត ដែលត្រូវផ្ដល់នូវសារធាតុចិញ្ចឹមឱ្យបានគ្រប់គ្រាន់សម្រាប់ការដាំដុះលូតលលាស់របស់ដើមកៅស៊ូ។ បន្ទាប់ពីដំណាក់កាលនេះ ការដាក់ជីត្រូវមើលតាមរោគសញ្ញាកង្វះសារធាតុចិញ្ចឹមរបស់កូនកៅស៊ូ។

អនុសាសន៍ នៃការដាក់ជីកំណត់ដោយវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជាមានដូចខាងក្រោម៖

| ឆ្នាំដាំ | បរិមាណជី (១៥ ១៥ ១៥ ក្រាម/ដើម/ឆ្នាំ | ចម្ងាយពីគល់កៅស៊ូ (ម) | បរិមាណជីដាក់ ២ដង/ឆ្នាំ |
|---|---|---|---|
| ឆ្នាំទី១ (ឆ្នាំដាំ) | ២០០ | ០.៣ | ១០០ក្រ/ដើម ដាក់នៅខែកញ្ញា-តុលា |
| ឆ្នាំទី២ | ២០០ | ០.៥ | ១០០ក្រ/ដើម ដាក់នៅខែឧសភា-កញ្ញា |
| ឆ្នាំទី៣ | ៣០០ | ១ | ១០០ក្រ/ដើម ដាក់នៅខែកញ្ញា-តុលា |
| ឆ្នាំទី៤ | ៤០០ | ០.៥ | ១០០ក្រ/ដើម ដាក់នៅខែកញ្ញា-តុលា |
| ឆ្នាំទី៥ | ៥០០ | ៣ | ១០០ក្រ/ដើម ដាក់នៅខែកញ្ញា-តុលា |

វិធីសាស្ត្រនៃការដាក់ជី៖

- កូនកៅស៊ូអាយុ ១-២ ឆ្នាំ ជីត្រូវដាក់នៅជុំវិញគល់កៅស៊ូចម្ងាយប្រមាណពី ០,២ ទៅ ០,៥ម ពីដើមកៅស៊ូ។
- កូនកៅស៊ូអាយុ៣ឆ្នាំ ការដាក់ជីត្រូវដាក់ចម្ងាយ ១ម ពីជួរកៅស៊ូ ដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ
- កូនកៅស៊ូអាយុ៤ឆ្នាំ ការដាក់ជីត្រូវដាក់ចម្ងាយ១,៥ម ពីជួរកៅស៊ូ ដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ
- កូនកៅស៊ូអាយុ៥ឆ្នាំ ការដាក់ជីត្រូវដាក់ចម្ងាយ៣ម ពីជួរកៅស៊ូ ដោយឆូតជាចង្អូរតាមចន្លោះរងកៅស៊ូ។










### ៣.៣ ការកាត់ខ្នែង

លទ្ធផលនៃការកាត់ខ្នែង គឺទទួលបានដើមត្រង់ល្អមិនមានបែកមែក និងស្នាមពកនៅលើសំបកដែលមិនបង្កការលំបាក នៅពេលកៅស៊ូដល់ដំណាក់កាលចៀរជ័រ។ ការកាត់ខ្នែងដុះតាមដើមដោយប្រើកាំបិតមុត ដើម្បីកាត់ខ្នែងលើដើមកៅស៊ូហើយការកាត់ខ្នែងត្រូវកាត់រហូតកៅស៊ូមានកម្ពស់

រហូតដល់២,៥ម ទៅ ៣ម។ ការកាត់ខ្នែងត្រូវអនុវត្តដូចខាងក្រោម៖

- រយៈពេល២ខែដំបូងនៃឆ្នាំទី១ការកាត់ខ្នែងប្រព្រឹត្ត ៨ថ្ងៃទៅ១៥ថ្ងៃម្តង
- រយៈពេលចាប់ពី ៣ខែរហូតដល់ឆ្នាំទី២ ការកាត់ខ្នែង ប្រព្រឹត្តទៅ១ខែម្តង
- កូនកៅស៊ូមានអាយុ ២ទៅ ៣ឆ្នាំ ការកាត់ខ្នែងប្រព្រឹត្ត ទៅ២ខែម្តង




### ៣.៨ ការគ្រប់គ្រងរុក្ខជាតិចង្រៃ

ការកម្ចាត់រុក្ខជាតិចង្រៃក្នុងចម្ការកៅស៊ូអាចគ្រប់គ្រងបានដោយការជម្រះតាមចន្លោះរងនីមួយៗ និងការជម្រះជារង្វង់ជុំវិញគល់ ឬការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិចង្រៃ ចាប់ពីឆ្នាំទី២ ឡើងទៅ។ ការជម្រះស្មៅនៅតាមរងកៅស៊ូឱ្យបាន ១ម ពីគល់កៅស៊ូទាំងសងខាង។ ការជម្រះស្មៅប្រព្រឹត្តទៅនៅពេលកៅស៊ូដាំបាន៦ខែដំបូង។ ការជម្រះស្មៅត្រូវធ្វើឡើង ១៥ទៅ ២០ថ្ងៃម្តង ហើយការសម្អាតឱ្យបាន៤ ទៅ ដងក្នុង ១ឆ្នាំ។ ចំពោះស្មៅតាមរងចន្លោះរងកៅស៊ូវិញ ត្រូវសម្អាតឱ្យបាន២ទៅ ៣ដងក្នុងរយៈពេល១ឆ្នាំ។ ចំពោះការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិចង្រៃទាំងអស់គួរប្រើប្រភេទផូស្វាត(Glyphosate)លាយជាមួយ២,៤ដេ(2,4D)។

តារាងវិធីប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិចង្រៃដូចខាងក្រោម៖

| រុក្ខជាតិចង្រៃ | ប្រភេទថ្នាំសម្លាប់ (ក្រ/ហ.ត) | |
|---|---|---|
| | គ្លីផូស្វាត | ២.៤ដេ |
| ស្មៅស្បូវ¹ | ២៨០ | ៧២០ |
| ស្មៅចង្រៃផ្សេងៗ | ១៤៤០ | ៧២០ |

**សំគាល់៖**

១ស្បូវត្រូវកាត់វាឱ្យខ្លីពី ៣០ស.ម ទៅ ៤០ស.ម ក្នុងករណីស្បូវខ្ពស់ ហើយទុកវាចោលពី ៤ ទៅ ៥ថ្ងៃ ទើបបាញ់ថ្នាំសម្លាប់។ ចំពោះធុងសម្រាប់បាញ់ដោយដៃ ចំណុះ១៨លីត្រ៖

- ចំណុះធុង ១៨លីត្រ
- សមត្ថភាពបាញ់ក្នុង ១ធុង បាញ់បាន ០.៨ ហិកតា
- ១៣ធុងបាញ់ក្នុងផ្ទៃដី ១ហិកតា

ជាទូទៅការសម្អាតស្មៅតាមរងកៅស៊ូ គួរតែប្រើដោយចបនៅក្នុងឆ្នាំដាំ និងឆ្នាំទី១។ ក្នុងករណីចាំបាច់អាចប្រើប្រាស់ថ្នាំកម្ចាត់ស្មៅបាន ប៉ុន្តែត្រូវតែគ្របកូនកៅស៊ូឱ្យបានល្អ។ ចាប់ពីឆ្នាំទី២ ការប្រើប្រាស់ថ្នាំកម្ចាត់ស្មៅតាមរងកៅស៊ូអាចអនុវត្តបានដោយបាញ់រៀងរាល់ ៤ខែម្តងនៅក្នុងឆ្នាំទី២ និង៦ខែម្តងចាប់ពីឆ្នាំទី៣ឡើងទៅ។

### ៣.៩ ការដាំដំណាំចន្លោះរង (Intercrops)

ដំណាំចន្លោះរង គឺជាដំណាំដែលគេដាំលើដីទំនេរតាមចន្លោះរងដែលមានពីរ ឬច្រើនប្រភេទ ហើយដុះលូតលាស់ដំណាលគ្នានៅលើផ្ទៃតែមួយ។ ហើយវាបានផ្តល់នូវប្រភពធនធានជាម្ហូបអាហារ និងថវិកាសម្រាប់កសិករកៅស៊ូគ្រួសារក្នុងកំឡុងពេលកូនកៅស៊ូមិនទាន់ផ្តល់ផល។ គុណសម្បត្តិនៃដំណាំចន្លោះរងរួមមាន៖

- ការពារកុំឱ្យដុះរុក្ខជាតិចង្រៃ
- ធ្វើឱ្យប្រសើរឡើងនូវលក្ខណៈរបស់ដី ព្រោះដំណាំចន្លោះរងខ្លះផ្តល់សារធាតុចិញ្ចឹមឱ្យដី ដូចជាពពួកសណ្តែក
- កាត់បន្ថយការហូរច្រោះដី
- ផ្តល់ការងារ និងប្រាក់ចំណូលបន្ថែមដល់កសិករ។

#### ក. ប្រភេទដំណាំចន្លោះរង

ប្រភេទដំណាំចន្លោះរង ដែលគេនិយមដាំក្នុងចម្ការកៅស៊ូចាប់ពីកៅស៊ូអាយុ ១ - ៣ឆ្នាំ មានដូចជា សណ្តែកដី សណ្តែកបាយ សណ្តែកសៀង ខ្ញី ម្នាស់ និងដំណាំប្រចាំរដូវផ្សេងៗ។

ក្រៅពីដំណាំទាំងនោះ គេក៏អាចដំដុះដំណាំរយៈពេលវែងដូចជា សាវម៉ាវ ចេក កាហ្វេ ក្រូចខ្វិច ធូរេន និងដូងតឿ។ ប៉ុន្តែដំណាំរយៈពេលវែងតាមចន្លោះរងកៅស៊ូអាចអនុវត្តបានតែក្នុងជួរភ្លោះតែប៉ុណ្ណោះ។

ខ. គំរូដំណាំចន្លោះរង

គំរូប្លង់ដំណាំចន្លោះរងក្នុងដំណាំកៅស៊ូ មានច្រើនប្រភេទទៅតាម ទំហំ ចន្លោះរងកៅស៊ូ និងប្រភេទដំណាំដែលគេចង់ដាំ។ ខាងក្រោមនេះជាប្រភេទគំរូប្លង់ដំណាំចន្លោះរងដែលធ្លាប់អនុវត្តកន្លងមក៖

១. ការដាំដំណាំចន្លោះរងតែមួយ

- ចន្លោះរងកៅស៊ូ ៦ម×៣ម= ៥៥៥ដើម/ហិកតា




គំរូប្លង់ដំណាំចន្លោះរងកៅស៊ូ៦ម×៣ម

- ចន្លោះរងកៅស៊ូ ៨ម×៣ម= ៤១៦ដើម/ហិកតា




គំរូប្លង់ដំណាំចន្លោះរងកៅស៊ូ៨ម×៣ម

- ចន្លោះរងកៅស៊ូ ៧ម×៣ម= ៤៧៦ដើម/ហិកតា




គំរូប្លង់ដំណាំចន្លោះរងកៅស៊ូ៧ម×៣ម

ជាទូទៅ គេនិយមដាំដំណាំចន្លោះរងនៅក្នុងចម្ការដែលមានចន្លោះរង ៦ម×៣ម ប៉ុន្តែគេអាចជ្រើសរើសចន្លោះរងទំហំណាក៏បានដោយត្រូវមានចំនួនដើមកៅស៊ូមិនតិចជាង ៥០០ដើម/ហិកតា និងមិនលើសពី ៦០០ដើម/ហិកតា។

២. ការដាំដំណាំរយៈពេលវែង និងដំណាំផ្សេងៗ

ក. ចន្លោះរងកៅស៊ូ ១២ម×២ម=៤១៦ដើម/ហិកតា

រងកៅស៊ូត្រូវតែបែរទៅរកទិសកើត-លិច




ដំណាំកៅស៊ូជាមួយដំណាំចន្លោះរង

ខ. ចន្លោះរងកៅស៊ូ ២×៣×១៤ម(ជួរភ្លោះ)=៤១៦ដើម/ហិកតា

រងកៅស៊ូត្រូវតែបែរទៅរកទិសកើត-លិច




ដំណាំកៅស៊ូជាមួយដំណាំរយៈពេលវែង

## ៣.៦ ដំណាំគម្របដី (Cover Crops)

ក្រៅពីដំណាំចន្លោះរងដូចបានរៀបរាប់ខាងលើ គេក៏អាចដាំដំណាំគម្របដីនៅចន្លោះរងកៅស៊ូបានដែរ។ ប្រភេទដំណាំគម្របដីដែលគេធ្លាប់បានដាំដុះកន្លងមកមានដូចជា៖

- ស្ទីលឡូសាំងតែស (Stylosanthes)
- មូគូណា (Mucuna Bracteata)
- ពូអេរអារីយ៉ា (Pueraria Phaseoloides)
- សង់ត្រូសេម៉ា (Centrosema Pubescens)
- ប្រាការីយ៉ា (Brachiaria Brizantha)
- កាឡូប៉ូយ៉ូម (Calopogonium mucunodies).

។ល។ ដំណាំគម្របដីផ្ដល់ផលប្រយោជន៍ជាច្រើន៖

- កាត់បន្ថយការហូរច្រោះដី
- រក្សាសំណើមដី
- ផ្ដល់សារធាតុចិញ្ចឹម
- ទប់ស្កាត់ការលូតលាស់រុក្ខជាតិចង្រៃ។



ពូអេរអារីយ៉ា (Pueraria phaseoloide)



ប្រាការីយ៉ា (Brachiaria brizantha)



ស្ទីលឡូសាំងតែស(Stylosanthes)



មូគូណា (Muvuna bracteata)

### ៣.៧ ការធ្វើឱ្យបែកមែក

ក្លូនកៅស៊ូមួយចំនួនមានការបែកមែកយឺត និងដុះលូតទៅលើខ្ពស់ គ្មានមែក ជាហេតុធ្វើឱ្យដើមស្រឡូនឡើងទៅលើ ដោយសារការពង្រឹងទំហំដើមយឺត។ ដើមកៅស៊ូទាំងនោះត្រូវបានជំរុញឱ្យបែកមែក ដើម្បីទទួលបានគម្របស្លឹកល្អ ហើយដើមកៅស៊ូដុះលូតលាស់ និងមានទម្រង់ល្អ។

ការជំរុញឱ្យបែកមែកត្រូវធ្វើនៅលើដើមកៅស៊ូដែលមានអាយុយ៉ាងតិច ១៨ខែ ដោយប្រើឧបករណ៍ កាត់សំបកជុំវិញដើម។ វិធីនេះ គឺដាក់ឧបករណ៍នៅលើដើមដែលមានកម្ពស់២,៥ម៉ែត្រពីដី រួចបង្វិលមួយជុំដើម ដើម្បីឱ្យឧបករណ៍អាចកាត់សំបកដល់សាច់ឈើ។ វិធីនេះអាចធ្វើឱ្យបែកមែកពី ៤-៥ម៉ែត្រ។ ក្រៅពីវិធីសាស្ត្រខាងលើ គេមានវិធីសាស្ត្រផ្សេងៗទៀតដើម្បីឱ្យដើមកៅស៊ូបែកមែក។ វិធីសាស្ត្រទាំងនោះមានដូចជា ការកាត់តួស្លឹកនៅផ្នែកខាងចុងចេញ និងការក្ដោបកំពូលត្រួយដោយស្លឹក។ ការក្ដោបកំពូលស្លឹកដែលក្ដោបនឹងត្រូវស្រាយចេញក្រោយរយៈពេល ៣ ទៅ ៤អាទិត្យ បន្ទាប់មកជ្រើសរើសខ្នែងដែលដុះចេញល្អចំនួន ៥យ៉ាងច្រើន។




ការធ្វើឱ្យបែកមែក

សូមរង់ចាំអានបន្តនៅទស្សនាវដ្ដីកសិកម្មលេខ៧៨



# ចំណេះដឹងស្តីអំពីសុខភាពសត្វ

រៀបចំដោយ៖
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

បន្តពីទស្សនាវដ្តីកសិកម្មប្រចាំត្រីមាសទី៤ ឆ្នាំ២០២០ លេខ៧៦

ពោត)និងខ្លាញ់(មានក្នុងកន្ទក់)។

**ប្រូតេអ៊ីន:** ប្រូតេអ៊ីន និងអាស៊ីត អាមីណេ ចាំបាច់សម្រាប់ការលូតលាស់ និងផលិតស៊ុត។ ឧទាហរណ៍ ការចិញ្ចឹមមាន់សាច់ពាក់កណ្តាលពាណិជ្ជកម្ម ចាប់ពី២១ថ្ងៃត្រូវការប្រូតេអ៊ីន ១៩% និងមានយកស៊ុតត្រូវការ ១៦%ក្នុងចំណី។ តម្រូវការប្រូតេអ៊ីនជា បញ្ហាចម្បង ព្រោះកសិករមិនមានលទ្ធភាពទិញម្សៅត្រី ឬសណ្តែកសៀងបានទេ។ ដូច្នេះកសិករអាចរកជន្លេន ដង្កូវ កណ្តៀរ ខ្យង (សម្រាប់ទា) និងសត្វល្អិតដែលសម្បូរប្រូតេអ៊ីនជំនួសវិញ។ ពន្លកស្មៅខ្ចីៗ ជួយបំពេញបន្ថែមបញ្ហាកង្វះប្រូតេអ៊ីនបាន។



មេទីញូនីនអាស៊ីតអាមីណេ ចាំបាច់សម្រាប់បង្កើតរោម

លីស៊ីន ជាអាស៊ីតអាមីណេចាំបាច់សម្រាប់បង្កើតសាច់

ត្រកួន(ស្មៅទឹក)ចញ្ច្រាំ និងលាយជាមួយចុងអង្ករ និងកន្ទុកដើម្បីផ្តល់ប្រូតេអ៊ីនបន្ថែម



- វីតាមីន និងសារធាតុរ៉ែ

ជាតិកាល់ស្យូម (Ca)និងផូស្វ័រ(P) ក្នុងចំណីមានកម្រិតទាបសម្រាប់មាន់ចិញ្ចឹមលែង។ កាល់ស្យូម និងផូស្វ័រងាយស្រួលផ្តល់ឱ្យសត្វតាមរយៈកំទេចសំបកខ្យងខ្ចៅ(៣ទៅ៤ក្រាមក្នុងមួយថ្ងៃសម្រាប់មេមាន់មួយក្បាល)។

### ១.៨ ស្នូកទឹក និងស្នូកចំណី

ដើម្បីជៀសវាងការខ្ជះខ្ជាយ និងងាយស្រួលដល់សត្វ ចំណីទឹកត្រូវដាក់ក្នុងស្នូកទឹក និងស្នូកចំណី នៅកន្លែងស្អាត។

- មេមាន់១០ក្បាល ត្រូវការផឹកទឹក៥លីត្រក្នុង១ថ្ងៃ
- មាន់សាច់ទម្ងន់១គីឡូក្រាម ៥០ក្បាលត្រូវការផឹកទឹក ១០លីត្រក្នុង១ថ្ងៃ។



## ២.ជ្រូក

### ២.១ ការផ្តល់ចំណី

ក្នុងការចិញ្ចឹមជ្រូក ចំណីគឺមានការចំណាយប្រាក់ច្រើនជាងការចំណាយផ្សេងៗ ជាការចាំបាច់ត្រូវដឹងពីតម្រូវការចំណីដើម្បីបង្ការការខ្វះខាត និងលូតលាស់បានល្អ។

**ចំពោះជ្រូកសាច់:** គោលបំណងគឺផលិតសាច់ច្រើន និងមានខ្លាញ់តិច ហើយមានការលាតលាស់លឿន។ ការចិញ្ចឹមជ្រូកសាច់ ត្រូវចែកជាដំណាក់កាល ហើយដំណាក់កាលនីមួយៗ

មានចំណីជាក់លាក់(ប្រូតេអ៊ីន និងថាមពល)។



**ដំណាក់កាល់ទី១៖** កូនជ្រូកបន្ទាប់ពីផ្ដាច់ដោះទម្ងន់ ៧ ទៅ១២គីឡូក្រាម ត្រូវការចំណីដែលមានសភាពទន់ និងសម្បូរដោយប្រូតេអ៊ីនងាយស្រួលក្នុងការរំលាយ(រយៈពេល២អាទិត្យ)កូនជ្រូកកូនកាត់ ត្រូវការប្រូតេអ៊ីន២០%។ ដូច្នេះ ចំណីផ្សំសម្រាប់កូនជ្រូកផ្ដាច់ដោះត្រូវមានឱជារស់ឆ្ងាញ់ និងមានវត្ថុធាតុដើមជាក់លាក់ (ជាតិទឹកដោះ និងប្រូតេអ៊ីនសណ្ដែកសៀងពោត..) ងាយស្រួលរំលាយ ដើម្បីទាក់ទាញកូនជ្រូកស៊ីបានច្រើន និងធំធាត់លឿន។



*ពេលផ្ដាច់ដោះ ចំណីឆ្ងាញ់ទាក់ទាញកូនជ្រូកឱ្យស៊ីច្រើន*

- ដំណាក់កាលទី២៖ រយៈពេលនេះជ្រូកមានទម្ងន់ពី២៥ទៅ៣០គីឡូក្រាម(អាយុប្រហែល២ខែកន្លះ)កូនជ្រូកកូនកាត់ត្រូវការចំណីដែលមានប្រូតេអ៊ីន១៨%។
- ដំណាក់កាលលូតលាស់៖ ពី ៣០ ទៅ ៦០គ.ក្រ (អាយុប្រហែល៤ខែកន្លះ)។ ជ្រូកកូនកាត់ត្រូវការប្រូតេអ៊ីន១៦%។
- ដំណាក់កាលបំប៉នៈ ពី៦០គីឡូក្រាមរហូតដល់លក់មានទម្ងន់ពី៨០ទៅ៩០គីឡូក្រាម(អាយុ៦ខែ)។ជ្រូកកូនកាត់ត្រូវការប្រូតេអ៊ីន១៤%។

### ចំពោះជ្រូកពូជ

**មេជ្រូកផើម៖** ក្នុងកំឡុង ៣អាទិត្យដំបូង កសិករត្រូវផ្ដល់ចំណីបន្ថែម(៥០០ក្រាមលើសពីពេលមុន) ព្រោះមេជ្រូកត្រូវការដើម្បីចិញ្ចឹមកូន។ ក្នុងកំឡុង៣អាទិត្យ មុនពេលកើតចាំបាច់ត្រូវបន្ថែមបរិមាណចំណី ៥០០ក្រាមក្នុងមួយថ្ងៃ។ ត្រូវផ្ដល់ចំណីដែលជួយផលិតខ្លាញ់ ព្រោះមេជ្រូកត្រូវការថាមពលដើម្បីផលិតទឹកដោះក្នុងពេលបំបៅដោះ និងបម្រុងទុក។

**មេជ្រូកបំបៅដោះ៖** មេជ្រូកត្រូវការថាមពល និងប្រូតេអ៊ីនច្រើនដើម្បីផលិតទឹកដោះ។ ចំណីត្រូវផ្ដល់យ៉ាងតិច ៣ដង ក្នុងមួយថ្ងៃ ដើម្បីជំរុញឱ្យស៊ីបានច្រើន។ បរិមាណចំណីត្រូវបន្ថែមចាប់ពីថ្ងៃទី១ប្រហែល១គីឡូក្រាមរហូតដល់១អាទិត្យបន្ទាប់ពីកើតកូន។ បរិមាណ ចំណីសរុបអាស្រ័យទៅនឹងចំនួនកូនជ្រូក។ ឧទាហរណ៍ មេជ្រូកមានកូន៦ក្បាលត្រូវការចំណី ៥គីឡូក្រាម និងមេជ្រូកមានកូន ១០ក្បាលត្រូវការចំណីយ៉ាងតិច ៦,៥គីឡូក្រាម។



*មេជ្រូកស៊ីច្រើនពេលបំបៅដោះកូន និងត្រូវការប្រូតេអ៊ីនថែមទៀតដើម្បីផលិតទឹកដោះបានគ្រប់គ្រាន់*

**ជ្រូកបា៖** ត្រូវការផលិតទឹកកាម និងត្រូវផ្ដល់ចំណីសម្រាប់មេជ្រូកផើមឱ្យស៊ី។ត្រូវផ្ដល់ចំណីបន្ថែមឱ្យបានទៀតទាត់ដែលមានវីតាមីន និងអាស៊ីតអាមីណេ។

### ២.២ ការផ្ដល់ចំណី និងការលូតលាស់

**ស្ថានភាពសុខភាព៖** ក្អករ៉ាំរ៉ៃ រាកប៉ះពាល់ដល់ការលូតលាស់។ ពពួកមីកូប្លាស្មា(Mycoplasma) កាត់បន្ថយការលូតលាស់ប្រហែលជា២០%។

**ពូជ៖** ការបង្កាត់ជ្រូកពូជក្នុងស្រុកជាមួយបាពូជឌុយរ៉ុក(Duroc) ឡាច់វ៉ាយ(Largewhite) ឡេនជ្រាស ឫម៉ាក្សស្ទែរ( landrace or Maxter) បានធ្វើឱ្យប្រសើរឡើងដល់ការលូតលាស់ និងប្រសិទ្ធភាពស៊ីចំណី។



*ចំពោះជ្រូកក្នុងស្រុក សូម្បីចំណីល្អ ក៏មិនបានការលូតលាស់លឿនដូចជ្រូកកូនកាត់ដែរ*



*របបចំណីត្រឹមត្រូវមានឥទ្ធិពលលើការលូតលាស់របស់ជ្រូកកូនកាត់*

**ចំណី៖** ប្រូតេអ៊ីនមានសារៈសំខាន់ណាស់ដើម្បីផលិតសាច់ក្រហម។ ប្រសិនចំណីមានប្រូតេអ៊ីនទាបពេក និងថាមពលច្រើននោះជ្រូកធំលូតលាស់យឺត និងមានខ្លាញ់ច្រើន។ តែបើចំណីមានប្រូតេអ៊ីន នឹងថាមពលទាបជ្រូកនឹងស្គម។

**កំណើនទម្ងន់ប្រចាំថ្ងៃ៖** គឺស្មើនឹង កំណើនទម្ងន់ជាក្រាមរៀងរាល់ថ្ងៃ។ បើគណនាកំណើនទម្ងន់ប្រចាំថ្ងៃ ពីពេលផ្ដាច់ដោះរហូតដល់លក់ កសិករត្រូវថ្លឹងទម្ងន់របស់ជ្រូកនៅពេលផ្ដាច់ដោះ។ ឧទាហរណ៍ៈ កូនជ្រូកមានទម្ងន់៨គីឡូក្រាមពេលផ្ដាច់ដោះបន្ទាប់មក កសិករត្រូវថ្លឹងទម្ងន់ នៅពេលលក់។ បើជ្រូកមានទម្ងន់៨២គីឡូក្រាម ដូចនេះកំណើនទម្ងន់គឺ ៨២-៨=៧៤គីឡូក្រាម ឬស្មើ៧៤០០០ក្រាម។ កសិករត្រូវគិតថា



*ពេលខ្លាញ់ក្រាស់ ជ្រូកលូតលាស់យឺត ធ្វើឱ្យខាតបង់ថវិកា*

តើត្រូវប្រើពេលប៉ុន្មានថ្ងៃ បន្ទាប់ពីផ្ដាច់ដោះរហូតដល់ពេលលក់? ឧទាហរណ៍ៈ គាត់បំប៉នកូនជ្រូកនៅអាយុ២៨ថ្ងៃ និងលក់នៅអាយុ៦ខែស្មើនឹង១៨០ថ្ងៃ។ ដូច្នេះមានរយៈពេល ១៥២ថ្ងៃ អាចគណនាកំណើតទម្ងន់ប្រចាំថ្ងៃ ដោយយក ៧៤០០០ក្រាមចែកនឹង១៥២ថ្ងៃ មានន័យថា កំណើនទម្ងន់ប្រចាំថ្ងៃ ប្រហែល៤៨៧ក្រាម។

បើគាត់អាចបង្កើនទម្ងន់ជ្រូកដល់ ៥៥០ ក្រាមក្នុងមួយថ្ងៃ គាត់នឹងអាចលក់ជ្រូកនៅទម្ងន់៨២គីឡូក្រាម នៅរយៈពេល១៣៤ថ្ងៃ ដោយជំនួសឱ្យការលក់នៅអាយុ ១៥២ ថ្ងៃវិញ។





*ការគណនាកំណើនប្រចាំថ្ងៃ និងបរិមាណស៊ីចំណី ដើម្បីផលិតបានសាច់ ចាំបាច់ត្រូវថ្លឹងជ្រូក និងចំណី*

បរិមាណស៊ីចំណី: ដើម្បីផលិតបានសាច់ ត្រូវគណនាបរិមាណចំណីដែលបានស៊ីចូល។ កសិករ ត្រូវថ្លឹងទម្ងន់កូនជ្រូកនៅពេលផ្តាច់ដោះ និងពេលលក់ ដោយបានគណនារួច គឺកំណើនទម្ងន់ស្មើនឹង៧៤គីឡូក្រាម។ កសិករគណនាបរិមាណចំណីដែលបានផ្តល់ឱ្យវាក្នុងកំឡុងពេលនេះ ឧទាហរណ៍: ២៦០គីឡូក្រាម ដូច្នេះចំណីចំនួន២៦០គ.ក្រ ផលិតបានជ្រូកទម្ងន់៧៤គីឡូក្រាម នោះបរិមាណស៊ីចំណីដើម្បីផលិតបានសាច់គឺ២៦០ចែកនឹង ៧៤ស្មើនឹង៣,៥គ.ក្រ ប្រសិនបើកសិករបង្កើនការគ្រប់គ្រង មានពូជល្អ ចំណីល្អ សុខភាពល្អ គាត់អាចទទួលបានបរិមាណស៊ីចំណីត្រឹម ៣ គ.ក្រ ដើម្បីផលិតបានសាច់ នេះមានន័យថា ដើម្បីបានជ្រូកទម្ងន់៨២គីឡូក្រាម គាត់ចំណាយចំណីត្រឹមតែ ២២២គ.ក្រ នោះគាត់ចំណេញបានលុយច្រើនជាងមុន។

- កសិដ្ឋានចិញ្ចឹមជ្រូកកូនកាត់ខ្នាតតូច ទិន្នផលរំពឹងទុកគួរតែ:
  - អាយុផ្តាច់ដោះ ២៨ថ្ងៃ ទម្ងន់ ៨គីឡូក្រាម
  - ទម្ងន់បន្ទាប់ពីដំណាក់កាលទី១ (ប្រើចំណីបំប៉នរយៈពេល២អាទិត្យ:១២គីឡូក្រាម
  - អាយុ២ខែកន្លះ ទម្ងន់២៥គីឡូក្រាម
  - អាយុ៤ខែកន្លះ ទម្ងន់៦០គីឡូក្រាម
  - អាយុប្រហែល៦ខែ ទម្ងន់៨០គីឡូក្រាម
  - កម្រាស់ខ្លាញ់: ១៥មីលីម៉ែត្រ
  - អត្រាងាប់ ក្រោយពេលផ្តាច់ដោះរហូតដល់លក់ត្រូវតែតិចជាង ៥%។

## ២.៣ ការលូតលាស់ និងប្រព័ន្ធផ្តល់ចំណី

កសិករផ្តល់ចំណីប្រភេទផ្សេងៗគ្នា អាស្រ័យនឹងចំនួនសត្វ និងថវិកាដែលមាន។

ចំណីឧស្សាហកម្ម: កំណើនទម្ងន់ប្រចាំថ្ងៃ (ADG) ប្រហាក់ប្រហែល ៧០០ក្រាមមានន័យថាជ្រូកលូតលាស់ជាមធ្យម គឺ៧០០ក្រាមរៀងរាល់ថ្ងៃ ពីទម្ងន់៣០គីឡូក្រាម រហូតដល់ពេលលក់ មានទម្ងន់ប្រហែល៨០គីឡូក្រាម។

ចំណីផ្សំតាមផ្ទះ: (កាកសំណល់ផ្ទះបាយ ជាមួយបាយ និងកន្ទក់) នោះកំណើនទម្ងន់ប្រចាំថ្ងៃ អាចប្រហាក់ប្រហែលនឹង៣០០ក្រាម។

- ចំណីផ្សំតាមផ្ទះជាមួយម្សៅត្រី(១០%) កំណើនទម្ងន់ប្រចាំថ្ងៃអាចប្រហាក់ប្រហែលនឹង៤៥០ក្រាម។
- ចំណីផ្សំតាមផ្ទះជាមួយសារធាតុផ្សំដែលមានជាតិវីតាមីនរ៉ែ និងអាស៊ីតអាមីណេលីស៊ីន កំណើនទម្ងន់ប្រចាំថ្ងៃអាចប្រហាក់ប្រហែលនឹង៦០០ក្រាម។ បទពិសោធន៍នេះបង្ហាញថា ក្នុងលក្ខខណ្ឌដូចគ្នា ពូជជ្រូកដូចគ្នានោះការលូតលាស់ពាក់ព័ន្ធ នឹងរបបចំណីអាហារ។ ត្រូវមានតុល្យភាពរបបចំណី នោះការលូតលាស់នឹងលឿន។ ការចំណាយក្នុងការផ្តល់ចំណីល្អ ធ្វើឱ្យចំណេញច្រើនសម្រាប់កសិករពេលគាត់ចិញ្ចឹមជ្រូកកូនកាត់ដែលមានសុខភាពល្អ។

## ២.៤ វត្ថុធាតុដើម និងសារធាតុបន្ថែមក្នុងចំណីជ្រូក

- ប្រូតេអ៊ីនមានសារៈសំខាន់ ដើម្បីផលិតសាច់ដុំ។ វត្ថុធាតុដើមមានបរិមានប្រូតេអ៊ីនផ្សេងៗគ្នា:
- ម្សៅត្រី មានប្រូតេអ៊ីន ពី៤០ទៅ៦៥%
- សណ្តែកសៀង មានប្រូតេអ៊ីន៤០%
- កន្ទក់ស្រូវសាលី មានប្រូតេអ៊ីន ១២ទៅ១៤%
- កន្ទក់ មានប្រូតេអ៊ីន ៩ទៅ១២%
- ពោត មានប្រូតេអ៊ីន ៩%
- ស្រូវ មានប្រូតេអ៊ីន៦%
- ដំឡូងមី មានប្រូតេអ៊ីនត្រឹមតែ២%



ពោត និងត្រីក្រៀម



**អាស៊ីតអាមីណេដែលចាំបាច់:**

មានអាស៊ីតអាមីណេសំខាន់ចំនួន៨ ហើយ៤ចាំបាច់សម្រាប់ការលូតលាស់:

- លីស៊ីន(lysin):ចាំបាច់បំផុត
- មេត្យូនីន(Methionin):ជាទូទៅមានគ្រប់គ្រាន់ក្នុងវត្ថុធាតុដើម
- ត្រេអូនីន(Threonin): សំខាន់ បន្ទាប់ពីលីស៊ីន
- ទ្រីបតូផាន (Tryptophan):សារធាតុនេះមានគ្រប់គ្រាន់ក្នុងស្រូវ

**ថាមពលសម្រាប់ជ្រូក:**

- សណ្តែកសៀង និងកន្ទក់ ផ្តល់ថាមពលច្រើន ព្រោះវាផ្ទុកជាតិប្រេង។
- ស្រូវ ដំឡូងមី ពោត ផ្តល់ថាមពល ព្រោះវាមានជាតិម្សៅ។



*សណ្តែកសៀងមានខ្លាញ់២០%ត្រូវការចម្អិនរយៈពេល២០ នាទីព្រោះវាមានផ្ទុកសារធាតុពុល*

**វីតាមីន និងរ៉ែ:**

វីតាមីន និងរ៉ែ គឺមិនមានគ្រប់គ្រាន់ក្នុងវត្ថុធាតុដើមសម្រាប់ការលូតលាស់របស់ជ្រូកទេ។ ចាំបាច់ត្រូវទិញផលិតផលដែលហៅថាប្រេមិច (premix) ដែលផ្តល់នូវសារធាតុចាំបាច់ដូចជា វីតាមីន អា ដេ អឺ បេ (Vitamin A,D,E,B)... និងសារធាតុរ៉ែ ដូចជា ដែក សង្កសី ម៉ាញ៉េស្យូម.....។ ត្រូវលាយវាជាមួយរបបចំណីរៀងរាល់ថ្ងៃ។ ឧទាហរណ៍: រូបមន្តចំណីជ្រូក ពី៣០ ទៅ ៩០គីឡូក្រាមគឺ:

- ពោត ៣៥%
- ចុងអង្ករ ១០%
- កន្ទក់ ៤០%
- សណ្តែកសៀង (ចំអិន)១០%
- ម្សៅត្រី ៤%
- ប្រេមិច (premix) ១%។



*ស្បែកស្អាត និងមានកើតរមាស់ដោយសារការចិញ្ចឹមឱ្យស៊ីកន្ទក់សុទ្ធ និងកង្វះសារធាតុសង្កសី*



*មានទឹកគ្រប់គ្រាន់ និងសុវត្ថិភាពល្អជាចំណុចចាប់ផ្តើមក្នុងការចិញ្ចឹមជ្រូក*

**ទឹក:**

ទឹកជាសារធាតុចិញ្ចឹមសម្រាប់ជ្រូកដើម្បីឱ្យមានការលូតលាស់ល្អ។ បរមាណផឹកទឹកជាមធ្យមគឺ:

- មេដើម ៣០លីត្រក្នុង១ថ្ងៃ
- មេបំបៅដោះ៤៥លីត្រក្នុង១ថ្ងៃ
- ការលាតលាស់ និងបំប៉នគឺ ១៥%នៃទម្ងន់របស់វាគឺស្មើនឹងទឹក១,៥លីត្រ សម្រាប់ជ្រូក១០គីឡូក្រាម។

**៣. គោ ក្របី**

**៣.១ បច្ចេកទេសផ្តល់ចំណី**

ការប្រឈមក្នុងការផ្តល់ចំណីដល់គោក្របីមានរយៈពេល ៦ខែក្នុងមួយឆ្នាំ ដោយរួមផ្សំតម្រូវការកំលាំងពលកម្មផងដែរ។

**ការរកស្មៅ:**

- តាមវាលស្រែ

- ផ្ទៃដីគ្មានដំណាំ និងភ្លឺស្រែ
- ជុំវិញស្រែ
- ចិញ្ចើមផ្លូវ
- ផ្ទៃដីវាលស្មៅធម្មជាតិ ឬព្រៃ



ម្ចាស់មិនអាចធ្វើការងារអ្វីផ្សេងបាន



ការស្វែងរកស្មៅនៅតាមទីវាល

ការផ្តល់ចំណីដាក់ក្នុងទ្រុងនៅឯផ្ទះ:

- ដោយកាត់ និងប្រមូលស្មៅ
- ចំបើង



ការផ្តល់ជាចំណី

## ៣.២ តម្រូវការរបស់គោក្របី

សរីរៈវិទ្យានៃការរំលាយអាហាររបស់គោ ក្របីបង្ហាញថាចំណីមានសារធាតុចិញ្ចឹមពីរប្រភេទ:

- សារធាតុចិញ្ចឹមសម្រាប់មីក្រុបក្នុងពោះធំ ដើម្បីផលិតប្រូតេអ៊ីន និងថាមពល
- សារធាតុចិញ្ចឹមសម្រាប់គោ ក្របីស្រូបដោយផ្ទាល់តម្រូវការរបស់គោ ក្របីផ្លាស់ប្តូរអាស្រ័យដោយ:
- ស្ថានភាពរបស់គោ: ធើម បំបៅដោះ ធ្វើការនៅស្រែ ឬបំប៉ន
- ទម្ងន់រាងកាយ: គោទម្ងន់១៥០គីឡូក្រាមត្រូវការចំណីតិចជាងគោទម្ងន់៣០០គីឡូក្រាម។

ទឹក:

- កង្វះទឹក ធ្វើឱ្យកាត់បន្ថយការស៊ីចំណី។ មេគោទម្ងន់២៥០គីឡូក្រាម ត្រូវការទឹកប្រហែល ៣៥លីត្រ ប៉ុន្តែបរិមាណនេះនឹងកើនឡើងច្រើនប្រសិនបើ:
- សីតុណ្ហភាពខ្ពស់
- មេគោផលិតទឹកដោះ
- គោ ក្របី ធ្វើការអូសទាញ គោ ក្របីចិញ្ចឹមដោយឱ្យស៊ីចំបើង



បរិមាណចំណី:

មិនអាចប្រើប្រាស់សារធាតុចិញ្ចឹមក្នុងចំណី ប្រសិនបើវាមិនបានស៊ីគ្រប់គ្រាន់។

- ចំណីមានគុណភាពទាប សត្វស៊ីមិនគ្រប់គ្រាន់ និងមិនទទួលសារធាតុចិញ្ចឹមបានត្រឹមត្រូវ។

☑ ប្រសិនបើចំណីផ្ទុកសារធាតុចិញ្ចឹមទាប បើទោះជាគោស៊ីរហូតដល់ពេញពោះ ក៏វាមិនអាចទទួលបានសារធាតុចិញ្ចឹមគ្រប់គ្រាន់ដែរ។



គោស៊ីចំបើងតែមួយមុខ

### ថាមពល:

ថាមពលត្រូវការចាំបាច់ដូចជា:

☑ ការទ្រទ្រង់ (ការថែទាំ) ដើម្បីទ្រទ្រង់មុខងាររាងកាយ(ការរំលាយអាហារដកដង្ហើម កំដៅ...)

☞ មេផើម: ត្រូវការថាមពលច្រើននៅមួយខែមុនពេលកើត និងពេលកូនក្នុងពោះរីកចំរើនលឿន។

☞ ការបំបៅដោះ: កង្វះថាមពលមានឥទ្ធិពលដល់ការផលិតទឹកដោះ។ មេគោត្រូវប្រើប្រាស់សារជាតុបម្រុងរបស់ខ្លួនធ្វើឱ្យវាចុះស្គម។



បង្កើតរបបចំណីថាមពលបង្កើនការផលិតទឹកដោះ កូនគោលូតលាស់លឿន កម្លាំងខ្លាំង មេមិនស្រកទម្ងន់

☞ ការបំប៉ន: ថាមពលដែលនៅសល់ អាចប្រើដើម្បីកើនទម្ងន់

☑ ការអូសទាញ ការភ្ជួររាស់ សត្វត្រូវការថាមពលខ្លាំង ប្រសិនបើគោមិនបានស៊ីចំណីគ្រប់គ្រាន់ក្នុងពេលភ្ជួររាស់ វានឹងបាក់កំលាំង និងធ្វើការយឺត។

ថាមពល ត្រូវបានផ្តល់តាមរយៈ៖

☑ ជាតិសរសៃ (សែលុយឡូស)ចំណីសត្វ និងចំបើងមានជាតិសរសៃច្រើន

☑ ម្សៅ មានច្រើនក្នុងមើមដំឡូងមី ពោត និងកន្ទក់

☑ ខ្លាញ់ មានក្នុងកន្ទក់ស្រូវ។

### ប្រូតេអ៊ីន:

ការផ្តល់ប្រូតេអ៊ីនដល់សត្វទំពារអៀងមានពីរប្រភេទ:

☞ ប្រូតេអ៊ីនមានដើមកំណើតពីរុក្ខជាតិ: ដូចជា រុក្ខជាតិខ្ចីៗ ស្លឹកឈើ ស្មៅស្ងួត មានប្រូតេអ៊ីន ៧% ស្តេចស្មៅមានប្រូតេអ៊ីន៨% ស្លឹកកន្ទុំថេតមានប្រូតេអ៊ីន១៨% និងស្លឹកដំឡូងមីមានប្រូតេអ៊ីន២៤%។



ដើមកន្ទុំថេត



ស្លឹកដំឡូង

☞ មីក្រូសរីរាង្គក្នុងពោះធំ: បានជួយរំលាយ និងផ្តល់ជាប្រូតេអ៊ីនដល់គោ។ គោអាចប្រើជាតិអ៊ុយរ៉េផងដែរ ដែលវាបំលែងជាអាម៉ូញ៉ាក់ដើម្បីទៅចិញ្ចឹមមីក្រូសរីរាង្គ។ អ៊ុយរ៉េជាសារធាតុផលិតប្រូតេអ៊ីន ដែលមានចំពោះតែសត្វទំពារអៀងប៉ុណ្ណោះ។

តម្រូវការរបស់សត្វប្រែប្រួល:

សម្រាប់ការទ្រទ្រង: ចំណី (ប្រូតេអ៊ីនឆៅមាន៧%) គ្រប់គ្រាន់សម្រាប់តម្រូវការប្រូតេអ៊ីនរបស់មេគោ។

សម្រាប់បំបៅដោះ: ទឹកដោះមានប្រូតេអ៊ីនខ្ពស់។ ប្រូតេអ៊ីនមួយផ្នែកបានមកពីចំណី និងមួយផ្នែកផ្សេងទៀតបានមកពីសាច់ដុំរបស់គោ ដូចនេះវាធ្វើឱ្យគោចុះស្គម ប្រសិនបើផ្ដល់តែស្មៅ និងចំបើង។

កំឡុងពេលដើម: ក្នុងពេលដើម កូនគោលូតលាស់ពិសេសខែចុងក្រោយ ដូចនេះយើងត្រូវបន្ថែមប្រូតេអ៊ីនក្នុងចំណីក្នុងកំឡុងពេលនេះ ដោយផ្ដល់ចំណីផ្សំ ឬកន្ទក់ ឬចំបើងផ្អាប់ដោយអ៊ុយរ៉េ (ដែលមានប្រូតេអ៊ីន ៧-១២%) តែចំបើងមានប្រូតេអ៊ីន ២ទៅ៤%។



គោគ្មានសាច់ដុំបញ្ជាក់ថាកង្វះប្រូតេអ៊ីន

ការលូតលាស: សាច់ដុំមានប្រូតេអ៊ីន លើសពី៥០% ដូចនេះ ការលូតលាស់ត្រូវការប្រូតេអ៊ីន យ៉ាងច្រើន។

ការភ្ជួររាស់: ចំណីតែមួយមុខ គោមិនអាចស៊ីគ្រប់គ្រាន់ដើម្បីបំពេញថាមពល និងប្រូតេអ៊ីន ដែលបានបាត់បង់ក្នុងពេលធ្វើការក្នុងពេលធ្វើការក្នុងស្រែទេ។ ដូច្នេះត្រូវផ្ដល់ចំណីផ្សំបន្ថែមដើម្បីកុំឱ្យគោចុះស្គម។

សារធាតុរ៉ែ:

សារធាតុរ៉ែមានតិចតួចក្នុងចំណីគោ ប៉ុន្តែគោត្រូវការសារធាតុរ៉ែនេះច្រើន សម្រាប់ទ្រទ្រង់ លូតលាស់ និងការផលិត។ សារធាតុរ៉ែ ម៉ាក្រូចំនួន៧ប្រភេទ រួមមាន: កាល់ស្យូម ផូស្វ័រ ម៉ាញ៉េស្យូម សូដ្យូម ប៉ូតាស្យូម ក្លរ និងស្ពាន់ធ័រ(Ca,P, Mg,Na,K,CI,S) សារធាតុរ៉ែចំនួន ១៨ ដែលចាំបាច់មាន: ដែក ទង់ដែង កូបាល់ សង្ក័សី អ៊ីយ៉ូត ម៉ង់កាណែស សេលីស្យូម....(Fe,Cu,Co,Zn,I,Mn,Se...) សមាសភាពរ៉ែក្នុងរុក្ខជាតិ និងក្នុងដីអាចមានផលប៉ះពាល់ដល់គោ។ ឧទាហរណ៍:ពេលគោខ្វះជាតិរ៉ែ យើងអាចសង្កេតឃើញរោគសត្វមានពណ៌



ការផ្លាស់ប្ដូរពណ៌រោម ផុះរោម ជាសញ្ញានៃការកង្វះសារធាតុរ៉ែ ជាពិសេសសារធាតុសង្គសី និងទង់ដែង

ស្រអាប់ និងបញ្ហាបន្តពូជ។ កសិករគួរដាក់នំគោដែលមានជាតិរ៉ែឱ្យវាលិទ្ធរៀងរាល់ថ្ងៃដើម្បីទទួលបានជាតិរ៉ែគ្រប់គ្រាន់។

វីតាមីន:

វីតាមីនចាំបាច់ ដើម្បីប្រើប្រាស់សារជាតុផ្សេងៗទៀតឱ្យមានប្រសិទ្ធភាព។

- ☑ វីតាមីនអា (Vitamin A) សំខាន់ជាងគេបំផុតសម្រាប់គោ។ សម្រាប់ការលូតលាស់ បន្តពូជ ទ្រទ្រង់ស្បែក និងការលូតលាស់ឆ្អឹង។ ចំណីនិងស្លឹកឈើដែលមានគុណភាពផ្ដល់បរិមាណវីតាមីនអា គ្រប់គ្រាន់ ប៉ុន្តែចំបើងមិនមានទេ។
- ក្រុមវីតាមីនបេ (Vitamin B) ត្រូវបានសំយោគក្នុងពោះធំ។

### ៣.៣ ការរៀបចំចំណីបន្ថែម

នៅក្នុងពេលបំបៅដោះ ពេលសត្វធ្វើការបាក់កំលាំង ឬពេលគោស្គម ការផ្ដល់ចំណីតែមួយមុខ នោះមិនមានគុណភាពគ្រប់គ្រាន់នោះទេ។ កសិករអាចរកស្មៅដែលមានគុណភាពខ្ពស់មានដូចជាស្ដេចស្មៅ ហ្គីណេៀរ ណាពៀ និងស្លឹករុក្ខជាតិដូចជា រលួស កន្ទុំថេត។

រូបមន្តនៃការផលិតចំណីផ្សំ:

- កន្ទក់ស្រូវ ១២គីឡូក្រាម
- មើមដំឡូងមីស្ងួតចំណិតតូចៗ ៧គីឡូក្រាម
- ម្សៅស្លឹកដំឡូងមីស្ងួត ៣គីឡូក្រាម
- អ៊ុយរ៉េ ០,៣គីឡូក្រាម
- អំបិល ០,២៥គីឡូក្រាម
- ស្ករត្នោត ០,២៥គីឡូក្រាម

សូមរងចាំអានបន្តនៅទស្សនាវដ្ដីកសិកម្ម លេខ ៧៨

# បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមបង្កង

## កសិករ ព្រំ វ៉ាត នៅភូមិព្រៃសំបួរ សង្កាត់អង្គរបូរី ក្រុងអង្គរបូរី ខេត្តតាកែវ



ដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រង នូវរាល់បទពិសោធន៍ជោគជ័យ លើការងារ និងមុខរបរផ្សេងៗ របស់ប្រជាកសិករ សហគមន៍ ក៏ដូចជាអង្គភាពពាក់ព័ន្ធនានា ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាកសិករ សហគមន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀតដែលមិនទាន់ទទួលបានជោគជ័យ ដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ធ្វើការអភិវឌ្ឍ លើមុខរបររបស់ខ្លួន ឱ្យទទួលបានជោគជ័យដូចទៅនឹងប្រជាកសិករ ឬអង្គភាពពាក់ព័ន្ធខាងលើផងដែរ។

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកយកបទពិសោធន៍ជោគជ័យរបស់កសិករ ព្រំ វ៉ាត ជាម្ចាស់កសិដ្ឋានភ្ញាស់ និងចិញ្ចឹមបង្កង ខ្នាតមធ្យមមួយកន្លែង ស្ថិតនៅភូមិព្រៃសំបួរ សង្កាត់អង្គរបូរី ក្រុងអង្គរបូរី ខេត្តតាកែវ ជាកសិករដែលកំពុងទទួលបានភាពជោគជ័យលើមុខរបរចិញ្ចឹមបង្កង មកបង្ហាញជូនដូចខាងក្រោមៈ

### ១. ស្ថានភាពទូទៅ

ខេត្តតាកែវ ជាពិសេសនៅក្នុងស្រុកអង្គរបុរី ដែលពីមុនបង្កងសំបូរណាស់ក្នុងធម្មជាតិ ព្រោះខេត្តតាកែវនៅជិតសមុទ្រ មានទឹកជោរនាច ហើយបង្កងអាចពងកូន នៅក្នុងទឹកភ្លាវ ធ្វើឱ្យបង្កងសកបានល្អ មានសាច់រឹង សំបូរចំណីធម្មជាតិ ពិសេសពេលមានទឹកជោរនាច ធ្វើឱ្យមានកំហាប់សារធាតុអំបិល ធ្វើឱ្យបង្កងមានភាពបន្សាំទៅនឹងលក្ខណៈជីវសាស្ត្ររបស់វា ទើបធ្វើឱ្យបង្កងលូតលាស់បានល្អ។ ចំណីធម្មជាតិដែលមាននៅក្នុងស្រះមានដូចជាៈ ត្រីខ្សង និងសត្វល្អិតតូចៗជាប្រភពចំណី ធ្វើឱ្យបង្កងមានរសជាតិឆ្ងាញ់។ នៅក្នុងខេត្តតាកែវ ប្រជាកសិករចិញ្ចឹមបង្កងមាន៣ស្រុកគឺ បុរីជលសា អង្គរបុរី និងស្រុកកោះអណ្ដែត ដោយសារបច្ចុប្បន្នមានគ្រោះរាំងស្ងួត និងមានការប្រែប្រួលអាកាសធាតុ ធ្វើឱ្យធនធានធម្មជាតិមានការថយចុះមួយចំនួន។

យោងលើស្ថានភាពខាងលើនេះ រាជរដ្ឋាភិបាលជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានជំរុញឱ្យមានការចិញ្ចឹមបង្កង ដើម្បីបំពេញតម្រូវការក្នុងស្រុកក៏ដូចជាការនាំចេញទៅក្រៅប្រទេស ហើយជាលទ្ធផល យើងសង្កេតឃើញមានការកើនឡើងនូវចំនួនប្រជាកសិករបានចាប់យកមុខរបរនេះ។

ចាប់តាំងឆ្នាំ២០២០ រហូតដល់ឆ្នាំ២០២១ នេះ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កំពុងជំរុញគម្រោងពង្រីកការចិញ្ចឹមបង្កង ឱ្យមានការរីកសាយជាច្រើនកន្លែងបន្ថែមទៀត និងជំរុញការធ្វើពិសោធន៍ ការចិញ្ចឹមបង្កងក្នុងស្រះ និងក្នុងស្រែផងដែរ ដើម្បីធ្វើការផ្សព្វផ្សាយដល់ប្រជាកសិករដទៃទៀតកុំឱ្យទុកនៅទំនេរ។

### ២. អំពីប្រវត្តិ

កសិករ ព្រំ វ៉ាត មានទីលំនៅក្នុងភូមិព្រៃសំបួរ សង្កាត់អង្គរបូរី ក្រុងអង្គរបូរី ខេត្តតាកែវ បានចាប់យកមុខរបរចិញ្ចឹមត្រី និងចិញ្ចឹមបង្កង តាំងពីឆ្នាំ២០០៦មកម្ល៉េះ គាត់ជាកសិករក្រីក្រម្នាក់ កាលដើមឡើយមានដីតែ ១០អាប៉ុណ្ណោះ ដោយមានមន្ត្រីជំនាញមកពីមន្ទីកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ តែងចុះមកបើកវគ្គបណ្ដុះបណ្ដាលពីបច្ចេកទេស

ភ្ញាស់កូនត្រីបង្កង និងចិញ្ចឹមបង្កងគាត់ក៏ចាប់ផ្តើមមុខរបរភ្ញាស់កូនត្រី បង្កង និងចិញ្ចឹមត្រី បង្កង នៅក្នុងទំហំដី១០អានោះ បន្ទាប់ពីការចិញ្ចឹមតិចៗក៏ទៅជាធំបន្តិចម្តងៗ ហើយគាត់ក៏ទទួលបានជោគជ័យរហូតមកដល់ពេលបច្ចុប្បន្ននេះ ដោយការព្យាយាមខិតខំរកលុយបានពី ការភ្ញាស់ត្រី បង្កង និងចិញ្ចឹមបង្កង មកដល់ពេលបច្ចុប្បន្ននេះគាត់បានទិញដីពង្រីកកសិដ្ឋានរបស់គាត់បានចំនួន៤ហិកតាកន្លះ។ ដោយមានការយកចិត្តទុកដាក់ និងចង់ចេះពីបច្ចេកទេស និងតែងធ្វើតាមបច្ចេទេសភ្ញាស់ត្រី បង្កង និងចិញ្ចឹមបង្កង ពីមន្ត្រីជំនាញរដ្ឋបាលជលផលតាកែវ តាមរយៈការចូលរួមក្នុងវគ្គបណ្តុះបណ្តាល ធ្វើឱ្យមុខរបររបស់ចេះតែទទួលបានផ្លែផ្កា ជារៀងរហូតមក។

បច្ចុប្បន្នគាត់មានស្រះចំនួន៥ ស្រះក្នុងនោះមានស្រះមួយទំហំ ១.៣ ហិចតា និងមួយទៀតមានទំហំជាង១០០០ម៉ែត្រការ៉េ។



ស្រះចិញ្ចឹមបង្កងកសិករ ព្រំ រ៉ាត ក្នុងពេលបច្ចុប្បន្ន

## ៣. បច្ចេកទេសចិញ្ចឹម

កសិករ ព្រំ រ៉ាត លោកបានរៀបរាប់ប្រាប់ថា ដើម្បីចិញ្ចឹមបង្កងទទួលបានជោគជ័យ ត្រូវមានការគិតដល់ការងារមួយចំនួនដូចជា៖

### ក. ការជ្រើសរើសទីតាំងស្រះ

ដើម្បីចិញ្ចឹមបង្កងទឹកសាបទទួលបានលទ្ធផលល្អ ស្រះគួរមានទីតាំងស្ថិតនៅជិតផ្ទះ ងាយស្រួលនៅក្នុងការគ្រប់គ្រង និងស្ថិតនៅទីវាលស្រឡះ គ្មានដើមឈើ ឬរុក្ខជាតិផ្សេងៗដុះព័ទ្ធជុំវិញ ស្ថិតនៅទីវាលទំនាប តែមិនលិចទឹកនៅរដូវវស្សា និងស្រះគួរមានទីតាំងស្ថិតនៅលើដីមានគុណភាពល្អ ពោលគឺជាល្បាយដីឥដ្ឋ ដែលអាចរក្សាទឹកបានយូរ លើសពី៥ខែ។ ត្រូវរៀបចំស្រះមុនពេលដាក់កូនបង្កងចិញ្ចឹមដូចជា ត្រូវបូមទឹកពង្រីងចេញពីស្រះ ដើម្បីចាប់ចេញឱ្យអស់ នូវរាល់ពពួកសត្វចង្រៃផ្សេងៗដូចជា៖ កង្កែប អន្ទង់ ពស់ ក្តាម ជាពិសេសត្រីកាច ស្ការភក់បាតស្រះ ដោយរក្សាជម្រៅចន្លោះពី ៥ ទៅ ១០សង់ទីម៉ែត្រ បាចកំបោរ បន្ទាប់ពីបានបូមទឹកពង្រីងចេញពីស្រះ និងស្ការភក់បាតស្រះរួច នូវបរិមាណចន្លោះពី ៥ ទៅ ១០គីឡូក្រាម ក្នុង១០០ម៉ែត្រការ៉េស្រះ រួចហាលថ្ងៃរយៈពេលពី ២ ទៅ៣ថ្ងៃ បញ្ចូលទឹកចូលស្រះ ជម្រៅចន្លោះពី២០ទៅ៣០សង់ទីម៉ែត្រ ដោយមានតម្រងច្រោះទឹក ការពារសត្វល្អិតចង្រៃផ្សេងៗ ឬត្រីកាចចូលទៅក្នុងស្រះ បញ្ចូលល្បាយទឹកជីលាមកសត្វ នូវបរិមាណពី ២៥ ទៅ ៣០គីឡូក្រាមក្នុង ១០០ម៉ែត្រការ៉េ រួចហាលថ្ងៃរយៈពេលពី ២ ទៅ ៣ថ្ងៃ បញ្ចូលទឹកបំពេញបន្ថែមបង្គ្រប់ជម្រៅចន្លោះពី ១ទៅ ១.៥ម៉ែត្រ។



ការសម្អាតស្រះ



ការធ្វើឱ្យទឹកស្រះផ្កា និងផ្លុងភុង

### ខ. ពូជ

កសិករ ព្រំ រ៉ាត បានរៀបរាប់ប្រាប់បន្តទៀតថា ត្រូវជ្រើសរើសកូនបង្កងពូជដែលមានសុខភាពល្អ តាមរយៈការសង្កេតមើលលើពុកមាត់របស់វាមានលក្ខណៈស្របគ្នា។ តែផ្ទុយទៅវិញ ប្រសិនបើសង្កេតឃើញថា ពុកមាត់របស់វាមាន

រាងលក្ខណៈដូចអក្សរវី (V) នោះសបញ្ជាក់ឱ្យឃើញថាកូនបង្កងមានសុខភាពមិនល្អ ពោលគឺមានសុខភាពខ្សោយ។ និងម៉្យាងទៀត យើងអាចសង្កេតលើសកម្មភាពរបស់វា ដូចជាការហែលមានលក្ខណៈរហ័សរហួន លើផ្ទៃទឹកផ្នែកខាងលើនៅពេលយើងផ្តាច់ចរន្តខ្យល់អុកស៊ីហ្សែនម្តងៗ នោះសបញ្ជាក់ថា កូនបង្កងមានសុខភាពល្អ។ ក្រៅពីនេះយើងអាចធ្វើការកត់សម្គាល់ផងដែរ លើដងខ្លួនកូនបង្កងដែលមានសុខភាពល្អ តែងតែមានពណ៌ខៀវថ្លា តែចំពោះកូនបង្កងមានសុខភាពមិនល្អវិញ ឬមានជំងឺ គឺដងខ្លួនរបស់វាតែងតែមានពណ៌សស្រអាប់ ហើយសំបកគម្របថ្គាល់របស់វាមានពណ៌ខ្មៅ។



ការជ្រើសរើសកូនបង្កងពូជដើម្បីដាក់ចិញ្ចឹម

គ. ចំណី

កសិករ ព្រុំ រ៉ាត បានឱ្យដឹងដែរថា ចំណីសម្រាប់ចិញ្ចឹមបង្កងនាពេលបច្ចុប្បន្ននេះរួមមានបីប្រភេទ គឺចំណីស្រស់ ចំណីផ្សំ និងចំណីគ្រាប់ ឬចំណីផលិតចេញពីរោងចក្រ។ ចំណីស្រស់រួមមានដូចជា ត្រីល្អិត កំពឹស ក្តាម ខ្យង ។ល។



កំពិសក្តាមជាចំណីស្រស់សម្រាប់បង្កង

ចំណីផ្សំ ជាប្រភេទចំណីផ្សំឡើងពីសមាសធាតុផ្សេងៗ ឬពីវត្ថុធាតុដើមមានស្រាប់ អាចរកបានតាមមូលដ្ឋានដូចជា ម្សៅត្រី កន្ទក់ ចុងអង្ករ ពោត សណ្តែកសៀង និងគ្រាប់ធញ្ញជាតិផ្សេងៗទៀត។ល។ ចំណីគ្រាប់ ជាប្រភេទចំណីផលិតចេញពីរោងចក្រ អាចធានាបានទាំងបរិមាណសារធាតុបំប៉ន និងគុណភាព ងាយស្រួលប្រើប្រាស់នៅក្នុងការផ្តល់ឱ្យបង្កងស៊ី និងចិញ្ចឹមបង្កង តែមានតម្លៃខ្ពស់លើទីផ្សារ។



ម្សៅត្រី កន្ទក់ ចុងអង្ករ ពោត សណ្តែកសៀង
និងគ្រាប់ធញ្ញជាតិ ជាចំណីផ្សំសម្រាប់បង្កង



ចំណីផ្សំស្រេចចេញពីរោងចក្រ

ចំពោះការផ្តល់ចំណី កសិករ ព្រុំ រ៉ាត បានបន្តប្រាប់ថា អាស្រ័យលើលក្ខណៈជីវសាស្ត្របង្កង តែងតែមានសកម្មភាពសកនៅពេលយប់ ដូច្នេះយើងត្រូវផ្តល់ចំណីបង្កងចំនួនពីរដងក្នុងមួយថ្ងៃគឺនៅពេលព្រឹក និងពេលរសៀលមេឃត្រជាក់។

## ៤. ការប្រមូលផល

កសិករ ព្រាំ វ៉ាត បានឱ្យដឹងដែរថា ជាទូទៅ បង្កងចិញ្ចឹមក្នុងរយៈពេលចន្លោះពី ៤ ទៅ ៥ខែ អាចមានទម្ងន់ជាមធ្យមចន្លោះពី ៣០ ទៅ ៥០ ក្រាមក្នុង ១ក្បាល ដែលជាទំហំសមស្រប អាចប្រមូលផលយកទៅលក់លើទីផ្សារបាន។ ចំពោះបង្កងរបស់គាត់ ក្នុងមួយថ្ងៃអាចប្រមូលផលយកទៅលក់បានពី ៤០ ទៅ ៥០ គ.ក្រ ឥឡូវគាត់ប្រមូលផលបាន ជិតមួយតោនហើយ នៅសល់ស្រះខ្លះមិនទាន់បានប្រមូលផល។

ហើយចំពោះទីផ្សារវិញគាត់បានប្រាប់ថាសម្រាប់ពេលបច្ចុប្បន្ន គាត់បានលក់ជាបង្កងសាច់ ពី៣ ទៅ ៤តោនក្នុងមួយឆ្នាំ ហើយនៅក្នុងការលក់នេះដែរ ត្រូវមានបែងចែកទៅតាមចំណាត់ថ្នាក់ ដោយបង្កងចំណាត់ថ្នាក់លេខ១ ១ គ.ក្រ តម្លៃ ២០ដុល្លារ និងបង្កងចំណាត់ថ្នាក់លេខ២ ១ គ.ក្រ តម្លៃ១៥ ដុល្លារ រីឯអតិថិជនជាកម្ម៉ង់ទិញ ភាគច្រើនមកពីរាជធានីភ្នំពេញ ហើយសម្រាប់កូនបង្កងពូជវិញ គាត់បានលក់ជូនទៅគ្រប់បណ្ដា រាជធានី-ខេត្ត ទាំង២៥ នៃប្រទេសកម្ពុជា ហើយមានរយៈពេលពេញមួយឆ្នាំតែម្ដង កូនបង្កងមានតម្លៃចន្លោះពី ២៥០រៀល ទៅ ៣០០រៀល ក្នុងមួយក្បាល។ កូនបង្កងអាយុកាល១ខែ មានទំហំប្រហែល២លី ដោយមានធានាដឹកជញ្ជូនដល់គោលដៅ និងផ្ដល់បច្ចេកទេសចិញ្ចឹមបង្កង ជូនអតិថិជនដោយមិនគិតថ្លៃ។





*ការប្រមូលផលបង្កងសាច់*





*ការប្រមូលផលកូនបង្កងលក់ឱ្យអ្នកចិញ្ចឹម*

## ៥. សំណូមពរ

កសិករ ព្រាំ វ៉ាត បានសំណូមពរថា សុំបងប្អូនប្រជាកសិករទាំងអស់ ដែលមានដីទំនេរ សូមកុំទុកចោលសូមធ្វើស្រូវផង ចិញ្ចឹមបង្កងផង ធ្វើរបៀបកសិកម្មចម្រុះ លើកភ្លឺស្រែជុំវិញស្រះពេលទឹកឡើងយើងចិញ្ចឹមបង្កង ពេលទឹកស្រក់យើងប្រមូលផលបង្កងវិញ ហើយធ្វើស្រូវបន្ត។ ដោយសារការចិញ្ចឹមបង្កងនេះ ទទួលបានប្រាក់ចំណេញច្រើន សូមឱ្យបងប្អូនប្រជាកសិករទូទាំងប្រទេសបង្វែរមកចិញ្ចឹមបង្កងនេះវិញ ដោយសារបង្កងមានតម្លៃថ្លៃជាងត្រី យើងអាចចិញ្ចឹមបង្កងក្នុងស្រែបានដោយជីកប្រឡាយព័ទ្ធជុំវិញស្រែ នៅពេលដែលប្រមូលផលយើងអាចប្រមូលផលបង្កងផង និងស្រូវផង។ សូមបងប្អូនងាកមកចាប់មុខរបរចិញ្ចឹមបង្កងវិញព្រោះវាមានតម្លៃថ្លៃហើយងាយស្រួលចិញ្ចឹម។

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ
- កសិករ ព្រាំ វ៉ាត មានទីលំនៅភូមិព្រៃសំបួរ សង្កាត់អង្គរបូរី ក្រុងអង្គរបូរី ខេត្តតាកែវ

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០៩២ ២៥៣៧៨៥
០៨៨ ៨៧៤៥៦៨៦

# បទពិសោធន៍ជោគជ័យលើមុខរបរចិញ្ចឹមទា

## កសិករ សួត សុផល នៅភូមិស្រែននោង ឃុំស្រែននោង ស្រុកត្រាំកក់ ខេត្តតាកែវ



ដោយៈ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យលើការងារ និងមុខរបរផ្សេងៗរបស់ប្រជាកសិករ សហគមន៍ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានា ដើម្បីធ្វើការផ្សព្វផ្សាយបន្តដល់ប្រជាកសិករ សហគមន៍ និងដៃគូពាក់ព័ន្ធផ្សេងទៀតដែលមិនទាន់ទទួលបានជោគជ័យ ដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ធ្វើការអភិវឌ្ឍលើមុខរបររបស់ខ្លួនឱ្យទទួលបានភាពជោគជ័យដូចទៅនឹងប្រជាកសិករ និងអង្គភាពពាក់ព័ន្ធខាងលើដែរ។

ព្រឹត្តិបត្រព័ត៌មានកសិកម្មនេះដែរ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានលើកយកបទពិសោធន៍ជោគជ័យរបស់កសិករ សួតសុផល មានទីលំនៅភូមិស្រែននោងឃុំស្រែននោងស្រុកត្រាំកក់ខេត្តតាកែវជាកសិករដែលកំពុងទទួលបានភាពជោគជ័យ លើការងារចិញ្ចឹមទាភ្ញាស់ពង និងកូនទាលក់មកបង្ហាញជូនដូចខាងក្រោមៈ

### ១. ស្ថានភាពទូទៅ

ខេត្តតាកែវ ជាខេត្តមួយដែលមានលក្ខណៈអំណោយផលល្អ លើការងារចិញ្ចឹមសត្វ ពិសេសបក្សី ក្នុងចំណោម ២៥ រាជធានី-ខេត្ត ហើយក៏មានបទពិសោធន៍ច្រើនជាងគេ បើនិយាយពីការចិញ្ចឹមទា ហើយមានចំនួនបក្សីក៏ច្រើនជាងគេដែរ រហូតដល់ទៅជាងបីលានក្បាល ចំពោះការចែកចាយបក្សីទៅកន្លែងផ្សេងៗមានលក្ខណៈទូលំទូលាយ។ មូលហេតុដែលខេត្តតាកែវ មានប្រជាពលរដ្ឋភាគច្រើន បានចាប់យកមុខរបរចិញ្ចឹមទា ជាមុខរបរចម្បង សម្រាប់សេដ្ឋកិច្ចគ្រួសារ ដោយសារការចិញ្ចឹមទា មានការចំណាយតិច ហើយអាចដាក់ចិញ្ចឹមប្រដេញតាមដំណាក់ៗ។

ប្រភពពងទា ដែលបាននាំចេញពីខេត្តតាកែវ អ្នកទទួលទានភាគច្រើនសសើរថាមានរស់ជាតឆ្ងាញ់ នេះដោយសារប្រជាកសិករជាអ្នកផលិតម្នាក់ៗពោរពេញទៅដោយបទពិសោធន៍ ប្រើប្រាស់ចំណីធម្មជាតិ ហើយមានបច្ចេកទេសនៃការភ្ញាស់ត្រឹមត្រូវ មានឡភ្ញាស់ពងទាសម្រាប់ចែកចាយទៅភ្នំពេញ ហើយប្រភពនៃពងទាកូនដែលបានធ្វើការចែកចាយទៅតាមបណ្ដារាជធានី-ខេត្តប្រហែលជា៦៥ទៅ៧០ភាគរយគឺចេញពីភូមិស្រែននោង ឃុំស្រែននោងនេះតែម្ដង។





ការចែកចាយពងទា និងកូនទាទៅតាមបណ្ដារាជធានី-ខេត្ត

## ២- អំពីប្រវត្តិ

កសិករ **សួត សុផល** បានចាប់ផ្តើមចិញ្ចឹមទា ចាប់តាំងពីឆ្នាំ២០០០ ដោយចិញ្ចឹមផងដឹកឱ្យគេផង ហើយប្រមូលកូនទាគេ យកទៅលក់ផង ដោយសារការស្រឡាញ់មុខរបរ និងចង់ធ្វើឱ្យមុខរបរមួយនេះមានការរីកចម្រើនជាងមុនក៏មានគំនិតចង់ភ្ញាស់ពងទាលក់។ បន្ទាប់ពីបានគិតរួច ក៏ចាប់ផ្តើមភ្ញាស់ពងទានេះ នៅឆ្នាំ២០០៧ ។ ដោយសារការដឹកពងទាកូនឱ្យគេជាងរៀងរាល់ថ្ងៃ តែងមើលឃើញ ការភ្ញាស់ ការចិញ្ចឹមរបស់គេមានការរីកចម្រើន ពេលនោះកសិករ **សួត សុផល** ក៏មានគំនិតមួយចង់ភ្ញាស់ពងទាលក់កូនបន្ថែមមួយទៀត។ ការភ្ញាស់ពងទាមុនដំបូងរបស់គាត់ គឺមានតែ១០០០ពងទេក្រោយមកចេះតែកើនទៅៗ រហូតមកដល់បច្ចុប្បន្ននេះការដាក់ភ្ញាស់រយៈពេល៤ថ្ងៃប្រហែល៤០០០០ពង ហើយអាចរកទីផ្សាបានច្រើន គឺទូទាំង២៥ រាជធានី-ខេត្ត ។

ចំណូលគាតច្រើន បានពីការភ្ញាស់កូនទាលក់ ហើយសម្រាប់មុខរបររបស់គាត់ក្នុងពេលបច្ចុប្បន្ននេះ គាត់ភ្ញាស់ពងយកកូនលក់ផង លក់ពងទាកូនផង និងលក់ពងទាសាបផង។



*ការភ្ញាស់កូនទាសម្រាប់លក់*



*ការភ្ញាស់ពងទាកូនសម្រាប់លក់*



*ការរៀបចំពងទាសម្រាប់លក់*

## ៣. បច្ចេកទេស

កសិករ **សួត សុផល** បានរៀបរាប់ប្រាប់ពីបច្ចេកទេសចិញ្ចឹមខ្លះៗថា ដើម្បីចិញ្ចឹមទាបានជោគជ័យ ត្រូវគិតទៅលើកត្តាមួយចំនួនដូចខាងក្រោម៖

**កត្តាពូជ៖** ត្រូវជ្រើសរើសប្រភេទពូជទាកន្លាស់ មិនជាន់ឈាម មិនរើសចំណី ធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ពងច្រើន។ ចំពោះទាមេ ធំលឿន ចំពុះតូច ដកករវែង រោមភ្លឺថ្លា ក្បាលតូច គូថធ្លាក់ ពូកែស៊ីចំណី ជម្រុះស្លាបរហ័ស។



*កូនទាពូជដែលបានសម្រិតសម្រាំង*

**កត្តាទ្រុង៖** ទ្រុងសម្រាប់កូនទា ត្រូវសង់លើដីទួល ដីខ្សាច់ សងបែរឱ្យចំនឹងពន្លឺព្រះអាទិត្យ ក្រាលអង្កាមដើម្បីកុំឱ្យមានសំណើមខ្លាំង ហ៊ុំព័ទ្ធដោយល្អួសសំណាញ់ ឬបន្ទះឫស្សីស្តើងៗ ពេលយប់ត្រូវដាក់ភ្លើង សូឡា ឬអំពូលម៉ែត្រ បំបែកកូនទាជាក្រុមៗ ពី១០០ ទៅ ២៥០ ក្បាល។ ទ្រុងសម្រាប់មេទាពង ពេលថ្ងៃត្រូវដាក់ក្រោមម្លប់ឈើ ដែលបានហ៊ុំព័ទ្ធដោយឫស្សី ឬស្បៃមុង ស្ថិតក្បែរមាត់ទឹក ពេលយប់ត្រូវដាក់ក្នុងរោង ដើម្បីការពារពីបាត់បង់ដោយប្រការផ្សេងៗ ទាពង

១០០ក្បាល ត្រូវការផ្ទៃដី២៤ម²។ ទ្រុងទាយកសាច់ ការរៀបចំដូចទៅនឹងទ្រុងចិញ្ចឹមមេទាពង និងទ្រុងចិញ្ចឹមកូនទាដែរ ក៏ប៉ុន្តែពេលទាអាយុ៣០-៣៥ថ្ងៃឡើងទៅ ពេលថ្ងៃអាចឱ្យវានៅក្រោមម្លប់ និងពេលយប់អាចឱ្យនៅលើទីវាល ឬក្រោមម្លប់ឈើ ពិសេសកន្លែងមានសុវត្ថិភាព។



ប្រភេទទ្រុងសម្រាប់កូនទា



ប្រភេទទ្រុងសម្រាប់ទាមេព័ទ្ធសំណាញ់ជុំវិញម្លប់ឈើ



ប្រភេទទ្រុងសម្រាប់ទាសាច់ព័ទ្ធសំណាញ់ជុំវិញម្លប់ដែលមានប្រភពទឹក

**កត្តាចំណី៖** កូនទាអាយុ១-៣ ថ្ងៃ មានដូចជាអង្ករ ឬគ្រាប់ពោត កិនរួចស្ងោឱ្យឆ្អិន ចាក់ទឹក លាយឱ្យខាប់ច្របាច់ឱ្យសព្វ ទុកឱ្យត្រជាក់ទើបឱ្យទាស៊ី ម៉ោង១០យប់ និងពេលថ្ងៃ ៣ដង។ ផឹកទឹកស្អាត ឬយកទឹក ៥០-៦០លីត្រ បុកជាមួយស្លឹកខ្ទឹម ១គីឡូក្រាម លាយទឹកឬលាយក្នុងចំណីឱ្យស៊ី។

ពាក់ព័ន្ធនឹងការផ្ដល់ចំណីដល់កូនទានេះដែរ កសិករ **ស្ងួត សុផល** បានរៀបរាប់ប្រាប់បន្ថែមទៀតថា ៣ថ្ងៃដំបូង មិនត្រូវឱ្យស៊ីចំណីជាតិសាច់ ឬលេងទឹកឡើយ។ កូនទាអាយុ៤-១០ថ្ងៃ ត្រូវបង្ហាត់ឱ្យចេះស៊ីបាយ លាយជាមួយបន្លែ និងចំណីដែលមានសារធាតុខ្លាញ់ខ្លះ រួចអាចឱ្យវាចុះលេងទឹករយៈពេល ៥-១០នាទី។ កូនទាអាយុ១១-១៦ថ្ងៃ ត្រូវឱ្យស៊ីអង្ករសម្រូប ឬពោត (មិនបាច់ចម្អិន) ត្រាំទឹកឱ្យទន់ (ចំពោះស្រូវត្រូវស្ងោរឱ្យទន់)បើលាយកន្ទុកបានកាន់តែប្រសើរ ក្នុងមួយថ្ងៃត្រូវឱ្យស៊ី១ទៅ២ដង រួចលែងឱ្យចេញស៊ីតាមវាលស្រែ តែត្រូវតាមឃ្វាលជាប់ជាប្រចាំ។ កូនទាអាយុ៣០ថ្ងៃ អាចលែងឱ្យស៊ីតាមវាលស្រែ ជាហ្វូង ដោយមានការឃ្វាលជាប់ជាប្រចាំ។ ចំណីមេពង មាន ៣ប្រភេទ ១.ចំណីជាតិសាច់ មានដូចជា ខ្យង ក្ដាម កូនត្រី កំពិស ឈ្លើង ជន្លេន ២.ចំណីជាតិម្សៅមានដូចជា ស្រូវ ពោត មើមថ្លុង និង៣ចំណីរុក្ខជាតិ មានដូចជា ស្លឹកស្មៅ ស្លែ សារាយ។ល។ ចំពោះស្រូវត្រូវត្រាំទឹក២យប់ រួចស្រង់ដាក់លើគោគទុក១-២យប់ឱ្យដុះចេញពន្លកទើបឱ្យស៊ី។ ចំណីទាសាច់ កូនទាអាយុ១-៣០ ថ្ងៃឱ្យស៊ីដូចកូនទាពង និងមេទាដែរ កូនទាអាយុលើសពី៣០ថ្ងៃ អាចលែងឱ្យស៊ីតាមវាល ដោយមានអ្នកនៅចាំមើល ឬឃ្វាល។

**កត្តាថែទាំ៖** ចំពោះកូនទាពេលកើតភ្លាម មិនត្រូវដាក់ចំណីឱ្យស៊ីភ្លាមទេ រងចាំរហូតដល់ ៤-៥ ម៉ោងចាំដាក់ ។ ត្រូវចែកកូនទាជាក្រុមៗ ក្នុងក្រុមអាចពី១០០-២៥០ក្បាល កុំឱ្យវានៅផ្ដុំគ្នា ព្រោះអាចជាន់គ្នាងាប់ កន្លែងចិញ្ចឹមត្រូវមានពន្លឺគ្រប់គ្រាន់។ ចំពោះមេទា មិនត្រូវធ្វើអ្វីដែលជាការបំភ័យ កុំដេញឱ្យវាឡើងចំណោទ ឬចុះចំណោទពេកទេ ទាខ្លាចភាពអូអរ សម្លេងភ្លេង ដីភក់ ដីបែកក្រហែង និងវាលស្មៅខ្ពស់ហើយក្រាស់ ពិសេសសត្វឆ្កែ។ ត្រូវផ្លាស់ប្ដូរទ្រុង១សប្ដាហ៍ម្ដង សម្អាតទ្រុងជាប្រចាំ រយៈពេល៣ ខែទើបអាចដាក់កន្លែងចាស់បាន។ ត្រូវមានទឹកស្អាតជាប្រចាំសម្រាប់វាផឹក។ និងចំពោះទាសាច់ ត្រូវមានការថែទាំដូចមេពងដែរ រយៈពេល ២ខែអាចមានទម្ងន់១.២-១.៥គ.ក្រ អាចលក់បាន។

## ៤. ជំងឺ

ពាក់ព័ន្ធនឹងបញ្ហាជំងឺ កសិករ ស្ងួត សុផល បានឱ្យដឹងថា កូនទាពេលដែលដាក់ចិញ្ចឹមពេលខ្លះអាចងាប់ បណ្ដាលមកពីកត្តាជាច្រើន ដូចជាពូជ ពេលទិញកូនមិនបានជ្រើសរើសត្រឹមត្រូវ ទាមានសុខភាពមិនល្អ ។ ជាទូទៅការចិញ្ចឹមជាលើកដំបូង ភាគច្រើនទិញពូជពីគេ ក្នុងចន្លោះពេលញាស់ពី៤-៥ម៉ោងដំបូងកូនទាមិនត្រូវការផ្ដល់ចំណីទេ ព្រោះប្រដាប់រំលាយអាហារនៅខ្សោយ បើមានការផ្ដល់ចំណីក្នុងអំឡុងពេលនេះ ពីកន្លែងផលិតកូនមក ពេលអ្នកយកទៅដាក់ចិញ្ចឹមកូនអាចខ្សោយ ឬងាប់បាន ម៉្យាងទៀតនៅក្នុងចន្លោះពេលញាស់ រួច ៤-៥ម៉ោងនេះ ពុំចាំបាច់មានការព្រួយបារម្ភពីការផ្ដល់ចំណីឡើយព្រោះអំឡុងពេលនេះកូនសត្វមានសារធាតុប៉ូវរ៉ុងសម្រាប់ចិញ្ចឹមខ្លួនវាហើយ ។ ម៉្យាងទៀតការខ្វះកំដៅ អាចធ្វើឱ្យកូនទាចុះខ្សោយដែរ ត្រូវមានចំណីផ្ដល់សារធាតុប្រូតេអ៊ីនខ្ពស់ ដើម្បីផ្ដល់កំដៅនៅក្នុងខ្លួនឱ្យបានគ្រប់គ្រាន់ ក្រោយញាស់២៤ម៉ោង។ ចំណុចមួយទៀតទាពាក់អាវកាក់ច្រើនតែឈឺ ដោយសារបរិស្ថាននៅជុំវិញសត្វមិនល្អ ដូច្នេះត្រូវមានការចាក់វ៉ាក់សាំងអាសន្នរោគ ប៉េស្ដ អុត និងជំងឺផ្សេងៗទៀតដល់វា។

ពាក់ព័ន្ធនឹងវិធានការកសិករ ស្ងួត សុផល បានឱ្យដឹងដែរថា ការចិញ្ចឹមទាតែងតែមានហានិភ័យបន្តិចបន្តួចជៀសមិនផុត ដូច្នេះដើម្បីដោះស្រាយបញ្ហានេះ ត្រូវមានការយកចិត្តទុកដាក់ រាល់ពេលមានការចុះណែនាំពីរបៀបចិញ្ចឹម របៀបធ្វើអនាម័យ របៀបចាក់វ៉ាក់សាំង និងរបៀបថែរក្សាពីសំណាក់មន្ត្រីពេទ្យសត្វខេត្ត ពេទ្យសត្វស្រុក ទើបការចិញ្ចឹមអាចទទួលបានជោគជ័យហើយជៀសផុតពីហានិភ័យទាំងនេះ។

## ៥. ទីផ្សារ

ការភ្ញាស់ពងទានៅឃុំស្រែននោងទាំងអ្នកចិញ្ចឹម អ្នកភ្ញាស់ពង និងអ្នកប្រមូលទិញផលិតផលពង ទៅលក់នៅតាមទីផ្សារមានជាង ៥០គ្រួសារ។ ដោយមានការសហការគ្នាជាមួយមន្ទីរពាណិជ្ជកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានប្រមែប្រមូលអ្នកភ្ញាស់ពង អ្នកចិញ្ចឹម អ្នកប្រមូលទិញផលិតផលពង ដើម្បីចងក្រងជាសមាគន៍ក្នុងគោលបំណងពង្រីកអាជីកម្មឱ្យមានការរីកចម្រើនធំជាងមុន ជាលទ្ធផលក្រោយបានបង្កើតសហគមន៍រួចមក មានអតិជនបញ្ជាទិញច្រើន និងមានទំនុកចិត្តលើសមាគមន៍ឃុំស្រែននោង ហើយមានការបញ្ជាទិញកាន់តែច្រើនឡើងៗ ដែលធ្វើឱ្យកសិករ ស្ងួត សុផល និងកសិករផ្សេងទៀត នៅក្នុងសហគមន៍ឃុំស្រែននោងទាំងមូលមានជីវភាពកាន់តែប្រសើរឡើង។



ទិដ្ឋភាពលំនៅដ្ឋានប្រជាសហគមន៍ឃុំស្រែននោង

កសិករ ស្ងួត សុផល បានឱ្យដឹងទៀតថាសហគមន៍នេះ មានលទ្ធភាពផលិតស៊ុតក្នុងមួយថ្ងៃប្រហែល១៥ម៉ឺនគ្រាប់ អាចចែកចាយទៅតាមបណ្ដារាជធានី-ខេត្ត ពិសេសអ្នកដែលបញ្ជាទិញពង នៅភ្នំពេញទាំងពងទាកូន ពងទាសាប និងមានការចែកចាយកូនទាផងដែរ ភាគច្រើនកូនទាដែលយកទៅចិញ្ចឹមនោះ គឺចេញពីឃុំស្រែននោងនេះ ការផលិតពងទានៅទីនេះមិនមានការថយចុះទេ ហើយតម្លៃពងទាក្នុងពេលបច្ចុប្បន្ន១គ្រាប់ចាប់ពី ៣០០ ទៅ ៤០០រៀល។



ការចែកចាយកូនទាទៅតាមបណ្ដារាជធានី-ខេត្ត

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ
- កសិករ ស្ងួត សុផល មានទីលំនៅភូមិ ឃុំស្រែននោង ស្រុកត្រាំកក់ ខេត្តតាកែវ
- ទំនាក់ទំនងទូរស័ព្ទលេខ៖ ០១២ ២៥៥ ០៤១




ឯកសារយោង៖ គេហទំព័រ Khmer Note & Brightside

ដោយលោក **ឃៀង អៀងគិច** ការិយាល័យផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ នៃរដ្ឋបាលព្រៃឈើ

# វិធីសាស្ត្រក្នុងការយករួចខ្លួនពីការដេញប្រហារពីសត្វសាហាវទាំង១២ដែលអ្នកគួរតែចងចាំ

យើងសង្ឃឹមថាអ្នកនឹងមិនជួបសត្វតោដែលស្រេកឃ្លានហើយមិនត្រូវរត់ចេញពីសត្វរមាសឬហែលចេញពី ក្រពើ ឬក៏សត្វសាហាវផ្សេងៗទៀត ប៉ុន្តែប្រសិនបើវាកើតឡើងមែននោះ ជាការសំខាន់បំផុតដែលយើងចាំបាច់ត្រូវតែដឹងអំពីឥរិយាបថរបស់សត្វទាំងនោះ ដើម្បីរកវិធីសាស្ត្រសមស្របឱ្យបានត្រឹមត្រូវក្នុងការគេចខ្លួនឱ្យរួចជីវិត។

ខាងក្រោមនេះជាវិធីសាស្ត្រខ្លីៗមួយចំនួនដែលអ្នកគួរតែយល់ដឹង និងចងចាំដើម្បីត្រៀមលក្ខណៈជាមុនក្នុងការជួយសង្គ្រោះជីវិតរបស់អ្នក ប្រសិនបើអ្នកជួបហេតុការណ៍អាក្រក់ទាំងនោះ។

## ១.ត្រីឆ្លាម

រឿងដែលអ្នកគួរតែយល់ដឹងនោះគឺ ក្នុងចំណោមត្រីឆ្លាម ១៥០ប្រភេទក្នុងសមុទ្រ គឺមានត្រឹមតែ ២០ប្រភេទប៉ុណ្ណោះដែលប្រហារមនុស្សជាចំណីរបស់វា ហើយអ្វីដែលគួរឱ្យអ្នកបារម្ភនោះគឺ ប្រសិនបើត្រីឆ្លាមមានបំណងដេញប្រហារអ្នកហើយ គឺអ្នកពិបាកនឹងរត់គេចផុតពីវាណាស់។ ហេតុនេះ ដើម្បីជាជំនួយខ្លះៗក្នុងការការពារខ្លួនពីការតាមប្រហាររបស់ត្រីឆ្លាម អ្នកគួរតែយល់ដឹងនូវចំនុចមួយចំនួន។ អ្នកគួរតែចៀសវាងបណ្ដោយឱ្យឈាមហូរ ឬក៏បន្ទោរបង់នៅក្នុងទឹក ដែលជាប្រភពអាចឱ្យវាតាមរកអ្នកយ៉ាងងាយតាមរយៈការហិតក្លិន ទោះបីជាស្ថិតក្នុងចម្ងាយច្រើនគីឡូក្រាមក៏ដោយ។ ប្រសិនបើអ្នកជួបត្រីឆ្លាមភ្លាមៗ សូមកុំព្យាយាមហែលគេចបែរខ្នងពីវាដោយភ័យខ្លាច ដែលកាន់ធ្វើឱ្យខ្លួនកាន់តែគ្រោះថ្នាក់។ វិធីល្អអ្នកគួរតែហែលយឺតៗ ហើយក្នុងករណីដែលអ្នកគ្មានផ្លូវគេច សូមព្យាយាមវាយប្រហារ ទៅលើគ្រាប់ភ្នែក និងស្រកីរបស់វាដែលជាចំនុចខ្សោយរបស់ត្រីឆ្លាម។





## ២.កង់គូរូ




សត្វកង់គូរូ នឹងដេញប្រហារអ្នកនៅពេលដែលអ្នកឈ្លានពានទឹកដីវាតែប៉ុណ្ណោះ។ ក្នុងករណីនេះ អ្នកគួរតែព្យាយាមក្អក ឬបង្ហាញអាការៈធ្វើដូចជាមនុស្សឈឺ និងគេចឃើតៗ។ សូមកុំព្យាយាមបែរខ្នងរត់គេចពីវា ព្រោះសត្វកង់គូរូអាចហក់លោតបានក្នុងចម្ងាយឆ្ងាយ ហើយតាមទាន់ អ្នកក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។

## ៣.តោ




ប្រសិនបើអ្នកជួយនឹងសត្វតោ សូមកុំព្យាយាមរត់គេច។ អ្នកត្រូវព្យាយាមសម្លឹងមើលទៅក្នុងភ្នែករបស់វា និងព្យាយាមធ្វើយ៉ាងណាឱ្យខ្លួនរបស់អ្នកមានទំហំធំ ដូចជាការលើកដៃ ឬត្រដាងអាវក្រៅ។ ការធ្វើបែបនេះនឹងធ្វើឱ្យវាខ្សោយជាងអ្នក ហើយវាចៀសវាងមិនប្រយុទ្ធជាមួយទេ។ អ្នកអាចជ្រើសរើសយកការនិយាយជាមួយវា ដោយប្រើសម្លេងធំ ខ្លាំងៗ និងជឿជាក់ ដែលបញ្ជាក់ថាអ្នកមិនខ្លាចវាឡើយ។ ចំណុចនេះពិតជាពិបាកធ្វើណាស់ ព្រោះថាមនុស្សគ្រប់រូបបើជួបហេតុការណ៍នេះ ច្បាស់ជាភ័យព្រលឹងចុងសក់បាត់ទៅហើយ...។

## ៤.ដំរី




ដំរីជាសត្វមួយប្រភេទដែលមានភាពវៃឆ្លាត និងជាសត្វរួសរាយ។ ពួកវាដេញប្រហារលុះត្រាតែវាគិតថាអ្នកបង្កគ្រោះថ្នាក់ដល់កូនរបស់វាតែប៉ុណ្ណោះ ដែលភាគច្រើនគឺដំរីញីតែម្តង។ ប្រសិនបើអ្នកជួបហេតុការណ៍នេះ ត្រូវយកចិត្តទុកដាក់លើកាយវិការរបស់វា។ ប្រសិនបើភ្លុក និងត្រចៀករបស់វាបះទៅក្រោយនោះមានន័យថាវាកំពុងតែខឹងនឹងអ្នក។ ក្នុងពេលដែលវាចាប់ផ្តើមវាយប្រហារ សូមកុំរត់គេចត្រង់ៗ ជំនួសដោយការរត់ ត្រូវព្យាយាមរករបស់អ្វីមួយដែលអាចធ្វើជាខែលបាំងចន្លោះខ្លួនអ្នក និងសត្វដំរី ដែលអាចជាដើមឈើ ឬដុំថ្មធំៗជាដើម។

## ៥.រមាស




រមាសជាសត្វដែលមានការសម្លឹងអន់បំផុត ដែលជាហេតុធ្វើឱ្យវាឆាប់ភ័យ និងធ្វើការវាយប្រហារតបតទៅវិញ។ រមាសអាចបង្កើនល្បឿនជាង ៦០ គីឡូម៉ែត្រក្នុងមួយម៉ោង ព្រមទាំងពិបាកនឹងរត់គេចពីវាបំផុត។ តែទោះជាយ៉ាងណាក៏មានវិធីខ្លះអាចជួយសង្គ្រោះបានដែរ។ វិធីតែមួយដែលអាចរត់គេចពីសត្វរមាសបានគឺមានតែលាក់ខ្លួនក្រោយដើមឈើតែប៉ុណ្ណោះ ដែលជាឧបសគ្គតែមួយគត់របស់រមាស។ អ្នកក៏អាចជ្រើសរើសយកការលាក់ខ្លួនក្នុងគម្ពោតព្រៃ ឬស្មៅក្រាស់ៗបានដែរ ព្រោះភ្នែកវាអន់តូចៗព្រឹមៗ។

## ៦.ដំរីទឹក




សត្វប្រភេទនេះ មើលទៅហាក់ស្អាតស្លូតណាស់ តែទោះជាយ៉ាងណាក្ដី អត្រានៃមនុស្សស្លាប់ដោយសារវាគឺខ្ពស់ជាងក្រពើទៅទៀត។ ទោះវាមានទម្ងន់ធ្ងន់ តែល្បឿនរបស់ដំរីទឹកអាចរត់បានរហូតដល់ ៣០គីឡូម៉ែត្រក្នុងមួយម៉ោងឯណោះ ហើយវាថែមទាំងឆាប់ខឹងទៀតផង។ ប្រសិនបើស្ថិតក្នុងអាកាសធាតុក្ដៅ កុំព្យាយាមចូលទៅក្នុងរូងឈើ។ ក្នុងកំឡុងពេលគ្រោះរាំងស្ងួត ទឹកស្រក ដំរីទឹក តែងតែលាក់ខ្លួននៅក្នុងស្មៅខ្ពស់ៗ។ ដើម្បីកុំឱ្យដំរីទឹកដេញប្រហារ អ្នកគួរតែឡើងលើដើមឈើ ថ្មធំ ឬកន្លែងស្រួចៗ ហើយរង់ចាំនៅទីនោះរហូតដល់វាចាកចេញ។

## ៧.គោ






ទោះជាយ៉ាងណាក្តី សត្វគោមិនមែនត្រឹមតែដេញប្រហារអ្វីដែលមានពណ៌ក្រហម (ឬពណ៌ផ្សេងទៀត) នោះទេ តែវាប្រតិកម្មនឹងចលនាផងដែរ។ ហេតុនេះហើយបានជាគោតែងតែបោលទៅរកជល់អ្នក ដូច្នេះអ្នកត្រូវឈរឱ្យស្ងៀមស្ងាត់។ អ្នកគួរតែប្រើមួក អាវយឺត ឬក៏សម្លៀកបំពាក់ផ្សេងៗទៀតជានុយ ដោយរង់ចាំគោមកដល់ជិតដល់ អ្នកត្រូវគប់របស់ទាំងនោះចេញពីអ្នកជានុយបញ្ឆោតវា ហើយវានឹងរត់ទៅតាមរបស់នោះជាមិនខាន។

## ៨.សារ៉ាយរមាស់






ព្រុយរបស់សារ៉ាយរមាស់គឺវែង និងអាចធ្វើឱ្យយើងចុកចាប់។ ដើម្បីទាញវាចេញ អ្នកអាចយកទឹកនោមចាក់ទៅលើព្រុយវា ហើយលាងខ្លួនដោយទឹកអំបិល។ ការប្រើទឹកសាបលាងនឹងធ្វើឱ្យស្ថានភាពឈឺចាប់កាន់តែធ្ងន់ធ្ងរ។ ប្រើជន្លៀសដើម្បីចាប់យកផ្នែករបស់វាដែលនៅសេសសល់ ចេញឱ្យអស់ព្រមទាំងលាបក្រែមព្យាបាល។

## ៩.សត្វក្រពើ




ក្រពើជាសត្វមួយដែលមានថ្គាមរឹងមាំបំផុត។ ប្រសិនបើអ្នកត្រូវវាវាយប្រហារ គឺពិតជាមានការពិបាកក្នុងការរត់គេចណាស់។ វិធីល្អគឺត្រូវវាយចំភ្នែក និងបំពង់ក ដែលជាចំណុចខ្សោយរបស់វា ដើម្បីជាឱកាសគេចខ្លួនរបស់អ្នក។ ប្រសិនបើនៅលើគោកវាដេញតាមអ្នកនោះ ត្រូវរត់បត់បែន ព្រមទាំងស្រែកខ្លាំងៗ។ តែក្នុងករណីនៅក្នុងទឹក សូមកុំព្យាយាមបញ្ចេញសម្លេង ហើយហែលគេចខ្លួនដោយស្ងាត់ៗបំផុត។

## ១០.ពស់




ពស់ភាគច្រើនគ្មានគ្រោះថ្នាក់ និងគ្មានពិសទេ។ មនុស្សប្រមាណជាង៨០% ដែលត្រូវពស់ចឹកគឺដោយសារ តែពួកគេព្យាយាមចាប់វា ឬប៉ះពាល់វា។ ប្រសិនបើអ្នកចាប់អារម្មណ៍ថាត្រូវពស់តាម សូមប៉ះអ្វីឱ្យញ័រៗ នោះវានឹងចាកចេញពីអ្នក។ ប្រសិនបើអ្នកត្រូវពស់ចឹក សូមកុំព្យាយាមបឺត ពិសចេញពីមុខរបួសដូចដែលយើងឃើញនៅក្នុងខ្សែភាពយន្តឱ្យសោះ។ វាជាការល្អប្រសើរគឺលាងមុខរបួសជាមួយនឹងទឹកម៉ាស៊ីន រុំរបួសរឹតកៀបសរសៃឈាម និងទៅរកការសង្គ្រោះបន្ទាន់ពីគ្រូពេទ្យ។

## ១១. ស្វាធំ (Gorillas)




ស្វាធំ ត្រូវបានហៅថា ជាស្ដេចព្រៃ ដោយសារតែវាតែងតែការពារបងប្អូន និងតំបន់រស់នៅរបស់វា។ ស្វានេះនឹងមិនវាយប្រហារអ្នកទេ ប្រសិនបើអ្នកប្រព្រឹត្តល្អ តែក្នុងករណីដែលត្រូវប្រមាញ់ពីវាវិញនោះ អ្នកគួរតែអង្គុយចុះ ធ្វើខ្លួនឱ្យតូចបំផុត។ ព្យាយាមនិយាយខ្សឹបៗ និងគេចពីខ្សែភ្នែករបស់វា។ អ្នកអាចរមៀលដូចជាបាល់ ធ្វើខ្លួនឱ្យមើលទៅទន់ខ្សោយបំផុត ព្រោះស្វាធំជាសត្វដែលមានអំនួត វានឹងមិនធ្វើបាបអ្នកទន់ខ្សោយជាងវានោះទេ។

## ១២.ពពួកឃ្មុំ




ពពួកឃ្មុំនឹងការពារសំបុករបស់វា ហើយវានឹងទិចអ្នក បើទោះបីជាអ្នកគ្រាន់តែដើរកាត់ក៏ដោយ។ ពណ៌ស្រគាំគឺទាក់ទាញសត្វឃ្មុំជាពិសេស។ ដូច្នេះបើអ្នកពាក់អាវខ្មៅងងឹតនោះ ឱកាសនៃការផ្ដើលដោយសត្វឃ្មុំកាន់តែខ្ពស់។ ប្រសិនបើអ្នកត្រូវឃ្មុំដេញតាម ត្រូវព្យាយាមពួនក្នុងកន្លែងងងឹត។ កង្វះពន្លឺធ្វើឱ្យវាវង្វេងបានយ៉ាងងាយ។

ពពួកឃ្មុំមានច្រើនប្រភេទ ឃ្មុំខ្លះទិចគ្រាន់តែឈឺហើមឯខ្លះទៀត ដូចជាឪម៉ាល់ជាដើម វាពិសខ្លាំងណាស់ បើទិចច្រើនអាចគ្រោះថ្នាក់ដល់ជីវិតផង៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្ដីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំត្រីមាសទី១ ឆ្នាំ២០២១ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងត្រីមាសទី១នេះ ការងារបង្កបង្កើនផលដំណាំរដូវប្រាំងមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ជាពិសេសស្រូវរដូវប្រាំងសម្រេចបាន ៦៤៩ ៥៣៩ហ.ត ស្មើនឹង១៤១,៤៥% នៃផែនការចំនួន ៤៥៩ ២០០ហ.ត។ វិធានការជំរុញផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្មត្រូវបានដាក់ចេញ និងអនុវត្តយ៉ាងសកម្មដើម្បីជួយដល់កសិករ។ រីឯការចូលរួមទប់ស្កាត់បទល្មើស ជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផល បទល្មើសចលនាសត្វដោយខុសច្បាប់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងត្រីមាសទី១នេះ គឺបានរៀបចំកិច្ចប្រជុំការងារចាំបាច់តាមរយៈការប្រជុំពីចម្ងាយ រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។ ចំពោះលទ្ធផល និងសកម្មភាពការងារតាមផ្នែកផ្សេងៗ ឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ២០២១ រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅ របស់រាជរដ្ឋាភិបាល ដែលសម្រេចបានក្នុងឆ្នាំ២០២១នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្ដាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះ

#### ១.១ ផលិតកម្មដំណាំស្រូវរដូវប្រាំង

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៦៤៩ ៥៦៦ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៤ ២៥៧ហ.ត ស្មើនឹង០,៦៦% និងដោយគ្រឿងយន្តចំនួន ៦៤៥ ៣០៩ហ.ត ស្មើនឹង៩៩,៣៤%
- ផ្ទៃដីសាបសម្រេចបានចំនួន ២៦ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ៦៤៩ ៥៣៩ហ.ត ស្មើនឹង១៤១,៤៥% នៃផែនការចំនួន ៤៥៩ ២០០ហ.ត លើសឆ្នាំមុន ៣៣ ៣៧៥ហ.ត។

#### ១.២ ល្បឿនការងារប្រមូលផលស្រូវប្រាំង

-ការប្រមូលផលស្រូវប្រាំងបានចំនួន ៥៣៥ ៣៦៩ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៣៩៦ ៧០៣តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤៧៧តោន/ហ.ត។

#### ១.៣ ដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

-ដំណាំសាកវប្បកម្មអនុវត្តបានសរុបចំនួន ៣៨ ៣៧៤ហ.ត ស្មើនឹង១០២,៨៥% នៃផែនការចំនួន ៣៧ ៣១២ហ.ត លើសឆ្នាំមុន ៧៤៨ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១០០ ៩២៧ហ.ត ស្មើនឹង១១៩,០៦% នៃផែនការចំនួន ៨៤ ៧៧០ហ.ត លើសឆ្នាំមុន ២១ ៦៥៣ហ.ត។

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

### ១.៤ ការនាំចេញផលិតផលកសិកម្ម

#### ១.៤.១ ការនាំចេញអង្ករ

បរិមាណនាំចេញអង្ករបានចំនួន ១៥៣ ៦៨៨តោន មានការថយចុះចំនួន ៧៧ ២៦០តោន (-៣៣,៤៥%) តិចជាងបរិមាណនាំចេញក្នុងរយៈពេល៣ខែឆ្នាំ២០២០ មានចំនួន ២៣០ ៩៤៨តោន។ ការនាំចេញទៅកាន់ទិសដៅចំនួន ៤១ប្រទេស ក្នុងនោះប្រទេសចិនឈរលំដាប់ទី១ មានចំនួន ៨៥ ៣៧០តោន ប្រទេសបារាំងឈរលំដាប់ទី២ មានចំនួន ១៦ ០៦៦តោន ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៣ មានចំនួន ១០ ៧៩៦តោន ប្រទេសហ្គាបុងឈរលំដាប់ទី៤ មានចំនួន ៩ ០៥២តោន ប្រទេសណេដឺឡែនឈរលំដាប់ទី៥ មានចំនួន ៤ ៤៦៧តោន ប្រទេសអូស្ត្រាលីឈរលំដាប់ទី៦ មានចំនួន ៣ ០៣៤តោន ចក្រភពអង់គ្លេសឈរលំដាប់ទី៧ មានចំនួន ២ ៩៩៧តោន ប្រទេសអេស្ប៉ាញឈរលំដាប់ទី៨ មានចំនួន ២ ៦៩០តោន ប្រទេសអាល្លឺម៉ង់ឈរលំដាប់ទី៩ មានចំនួន ២ ២២៥តោន និងប្រទេសបែលហ្ស៊ិកឈរលំដាប់ទី១០ មានចំនួន ២ ០៨៧តោន។ ហើយបច្ចុប្បន្នក្រុមហ៊ុនបាននាំចេញអង្ករមានចំនួន ៥១ក្រុមហ៊ុន។

#### ១.៤.២ ការនាំចេញកសិផលផ្សេងៗ

បរិមាណនាំចេញផ្លែចេកស្រស់ចំនួន ១១៩ ៧៣៨,៥៨តោន ទៅកាន់ប្រទេសចិន វៀតណាម សិង្ហបុរី និងប្រទេសជប៉ុន ។ ផ្លែស្វាយស្រស់ចំនួន ១០២ ៧១៤,២១តោន ទៅកាន់ប្រទេសវៀតណាម ថៃ កូរ៉េ សិង្ហបុរី ហុងកុង និងគុយវ៉ែត។ គ្រាប់ពោតចំនួន ១០៨ ៩៧៨,៩៧តោន ទៅកាន់តៃវ៉ាន់ ប្រទេសកូរ៉េ ថៃ វៀតណាម និងប្រទេសបង់ក្លាដេស។ គ្រាប់ស្វាយចន្ទីចំនួន ៤៥០ ៨៧៧,៦១តោន ទៅកាន់ប្រទេសវៀតណាម ចិន ថៃ ឡាវ ជប៉ុន និងប្រទេសអារ៉ាប់។ ម្រេចចំនួន ១ ១១៧,១៩តោន ទៅកាន់ប្រទេសស៊ុយអ៊ែត ជប៉ុន បែលហ្ស៊ិក អាមេរិក កូរ៉េ បារាំង វៀតណាម ប៉ូឡូញ អាល្លឺម៉ង់ រុស្ស៊ីឆេក និងតៃវ៉ាន់។ ម្ទេសស្រស់ចំនួន ៤៥ ៤៩៧,១២តោន ទៅកាន់ប្រទេសថៃ។

## ២ ផ្នែកផលិតកម្មកៅស៊ូ

### ២.១ ផ្ទៃដីកៅស៊ូ

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤០៤ ១១៨ហ.ត ក្នុងនោះ ផ្ទៃដីចៀរជ័រចំនួន ២៩២ ៤៩៧ហ.ត ស្មើនឹង៧២% និងផ្ទៃដីថែទាំចំនួន ១១១ ៦២១ហ.ត ស្មើនឹង២៨%។

### ២.២ ផលិតកម្មកៅស៊ូ

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៤៧ ៤១២តោន បានកើនឡើងចំនួន ៤ ៩៦៤តោន ស្មើនឹង១២% ធៀបត្រីមាសទី១ឆ្នាំ២០២០។

### ២.៣ ការនាំចេញកៅស៊ូ

- បរិមាណជ័រកៅស៊ូបញ្ចេញលក់សម្រេចបានចំនួន ៤៥ ៩៦៥តោន បានកើនឡើងចំនួន ៤ ៤៧២តោន ស្មើនឹង ១១% ធៀបត្រីមាសទី១ឆ្នាំ២០២០។

### ២.៤ តម្លៃកៅស៊ូ

- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងខែមីនាគឺ ១ ៦២៩ដុល្លារ/តោន បានកើនឡើងចំនួន ៦៨ដុល្លារ/តោនស្មើនឹង៤,៣៣% ធៀបខែមុន និងបានកើនឡើងចំនួន ២១៨ដុល្លារ/តោនស្មើនឹង១៥% ធៀបខែមីនា ឆ្នាំ២០២០។
- តម្លៃជ័រកៅស៊ូលក់មធ្យមក្នុងត្រីមាសទី១គឺ ១ ៥៨៤ដុល្លារ/តោន បានកើនឡើងចំនួន ១៦២ដុល្លារ/តោន ស្មើនឹង ១១% ធៀបត្រីមាសទី១ឆ្នាំ២០២០។
- តម្លៃប្រមូលទិញជ័រកៅស៊ូគ្រួសារចម្ការក្នុងខែមីនាគឺទឹកជ័រ (DRC 100%) មានការប្រែប្រួលពី ៥ ៥៧៥៛/គ.ក្រ ដល់ ៥ ៨៥០៛/គ.ក្រ និងជ័រកក (DRC50%) មានការប្រែប្រួលពី ២ ១៥០៛/គ.ក្រ ដល់ ២ ៧៥០៛/គ.ក្រ។

## ៣ ផ្នែកព្រៃឈើ

### ៣.១ ការខាររព្រៃឈើ

- បាននិងកំពុងពិនិត្យ ផ្ទៀងផ្ទាត់ និងវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២១ និងទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០២១ ចំនួន ១០ផ្ទាំង និងរូបភាពផ្កាយរណប Sentinel-2 ចំនួន ១០ផ្ទាំង និងចុះប្រមូលព័ត៌មាននៅទីវាលជាក់ស្តែងតាមចំណុចនិយាមកាដែលបានធ្វើការចាត់ថ្នាក់រួចតាមរូបភាពផ្កាយរណបដើម្បីផ្ទៀងផ្ទាត់ និងវាយតម្លៃកម្រិតជឿជាក់ក្នុងខេត្តកំពង់ធំចំនួន ១០២ចំណុច និងខេត្តពោធិ៍សាត់ចំនួន ៤២ចំណុច
- បានចេញសេចក្តីប្រកាសស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន ៤កន្លែងមានផ្ទៃដីសរុបទំហំ ៣ ៣៦៦,៨៦ហ.ត

២

- ផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ៧៥គ្រឿង និងយានយន្តចំនួន ១០១គ្រឿងជូនក្រុមហ៊ុនចំនួន ៥ក្រុមហ៊ុន

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផលអនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន ៧ក្រុមហ៊ុន និងអ្នកស្នើសុំចំនួន ១នាក់ មានឈើហ៊ុបមូលចំនួន ៥ ៦៣៨ម៣ ឈើអារចំនួន ១ ៥២៧ម៣ ឈើជ្រុងចំនួន ៤ម៣ កូនឈើចំនួន ៦៩ ៨៤៤ដើម បង្គោលរបងចំនួន ៣៥ដើម បង្គោលក្រាក់ចំនួន ៤០ដើម អុសចម្រុះចំនួន ២៥ ៩២៥ស្ទែរ ជ័រទឹកចំនួន ១០០តោន ធ្យូងចំនួន ៣ ០០០គ.ក្រ ឬស្សីចំនួន ៩៦តោន គ្រឿងសង្ហារឹម និងផលអនុផលព្រៃឈើមួយចំនួនទៀត។

### ៣.២ ការងារអភិរក្សសត្វព្រៃ

- បានសហការជាមួយមន្ត្រីមន្ទីរបរិស្ថានខេត្តស្ទឹងត្រែង និងអង្គការ FFI ដើម្បីចុះប្រមូលលាមកសត្វដំរីក្នុងដែនជម្រកសត្វព្រៃ (ព្រៃឡង់) ខេត្តស្ទឹងត្រែង ដែនជម្រកសត្វព្រៃឆែប និងដែនជម្រសត្វព្រៃព្រះរការស្ថិតក្នុងស្រុកជាំក្សាន្ត និងស្រុកឆែប ខេត្តព្រះវិហារ ដោយប្រមូលបានសំណាកលាមកដំរីចំនួន ១៤៩សំណាក ត្រូវចម្រាញ់ទាញយក DNA នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដើម្បីកំណត់ពីចំនួនដំរី និងចម្រុះភាពនៃសេនេទិចក្រុមដំរីនៅក្នុងតំបន់សិក្សា

- បានសហការជាមួយអង្គការ FFI ដើម្បីចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ១២គ្រឿងនៅតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុង ថតជាប់សត្វដំរីព្រៃចំនួន ២៨ក្បាល ប្រើសចំនួន ១១ក្បាល ឈ្លូសចំនួន ៩ក្បាល ស្វាត្រោសចំនួន ៣២ក្បាល ប្រម៉ាចំនួន ១ក្បាល និងជ្រូកព្រៃចំនួន ៨ក្បាល និងចុះសិក្សាអំពីជម្លោះរវាងសត្វដំរីព្រៃ និងប្រជាពលរដ្ឋមូលដ្ឋានចំនួន ៦ករណី កើតឡើងក្នុងស្រុកកំពង់សិលា ខេត្តព្រះសីហនុ និងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

- បានចេញលិខិតអនុញ្ញាតថែរក្សាសត្វព្រៃជាលក្ខណៈគ្រួសារចំនួន ៥២ច្បាប់ ក្នុងនោះ ៥១ច្បាប់សម្រាប់ការថែរក្សាសត្វត្រចៀកកាំ និង១ច្បាប់សម្រាប់ការថែរក្សាសត្វឃ្មុំ ស្ថិតនៅខេត្តកោះកុង កំពត តាកែវ ពោធិ៍សាត់ កណ្តាល សៀមរាប និងខេត្តបន្ទាយមានជ័យ។

### ៣.៣ កសិដ្ឋានចិញ្ចឹម បង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្រុមហ៊ុនចំនួន៧កំពុងដំណើរការកសិដ្ឋានស្រាវជ្រាវ ចិញ្ចឹម និងបង្កាត់ពូជសត្វស្វាក្តាមយកកូននាំចេញចំនួន ៨ទីតាំងស្ថិតនៅរាជធានីភ្នំពេញ ខេត្តកំពង់ធំ សៀមរាប កំពង់ចាម កំពង់ស្ពឺ ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំងមានសត្វស្វាក្តាមសរុបចំនួន ៧៣ ៧៥៥ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ១៥ ៣៥៨ក្បាល ដឹកជញ្ជូនក្នុងស្រុកចំនួន ៧០០ក្បាល និងនាំចេញទៅក្រៅប្រទេសចំនួន ៤ ៨៦៨ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៧០៤ក្បាល (បក្សីចំនួន ៥៨ប្រភេទ ថនិកសត្វចំនួន ៤៥ប្រភេទ និងល្មូនចំនួន ១៦ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ២៧៤ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ១០៨ក្បាល ស្តារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងទៅព្រៃធម្មជាតិវិញនូវសត្វព្រៃគ្រប់ប្រភេទចំនួន ១៤៩ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI ក្រុមល្បាតចំនួន ៣០នាក់ បានចុះល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺៈ អារ៉ែង ឆាយរាប តំបន់ស្តារក្រពើស្ទឹងដាច់ ស្ទឹងខៀវ(ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់) អង្កេតតាមដានប្រចាំឆ្នាំនៅស្ទឹងខៀវ ស្ទឹងអារ៉ែង ស្ទឹងដាច់ក្នុងខេត្តកោះកុង និងបឹងវាលវែង ខេត្តពោធិ៍សាត់ រកឃើញក្រពើភ្នំចំនួន ៩ក្បាល លាមកក្រពើចំនួន ១១២ដុំ និងស្នាមដានក្រពើចំនួន ១៥កន្លែង

- បានបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ចំនួន ១វគ្គក្នុងខេត្តពោធិ៍សាត់ មានអ្នកចូលរួមចំនួន ១១នាក់ (ស្រី៩នាក់)

- បានជួសជុលផ្លូវដោយក្រាលក្រួសក្រហមសរុបប្រវែង ១៦ ៤៦៣ម៉ែត្រ និងកាប់ឆ្ការអនាម័យព្រៃទំហំ ២,៦០ហ.ត នៅតំបន់សួនសត្វ។

### ៣.៤ ការងារដាំដើមឈើ

- បានជីកប្រឡាយក្នុងឆ្នាំ២០២១ ប្រវែង ២០០ម៉ែត្រនៅខេត្តកំពង់ធំ និងឈូសឆាយដីទំហំ ១០ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអន្លង់ថ្ម ខេត្តកំពង់ធំ

- បានចុះសិក្សា និងពិនិត្យទីតាំងសម្រាប់បង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើក្នុងខេត្តប៉ៃលិនលើទីតាំងដីចម្ការម៉ៃសាក់របស់រដ្ឋទំហំ ២០០ ហ.ត

- បាននិងកំពុងថែទាំចម្ការឈើសរុប ៨២២ហ.ត ក្នុងនោះចម្ការពូជឈើទំហំ ៩៤ហ.ត ឡូតិ៍បង្ហាញកសិ-រុក្ខកម្ម ៤៤ហ.ត ចម្ការឈើដាំទំហំ ៦៥៤ហ.ត និងចម្ការរុក្ខទិវា ៩ កក្កដា សរុបទំហំ ៣០ហ.ត នៅខេត្តកំពត កណ្តាល សៀមរាប ព្រះសីហនុ ស្វាយរៀង កំពង់ធំ និងខេត្តក្រចេះ ដោយសម្អាតស្លឹកឈើ ស្មៅ និងការពារភ្លើងឆេះព្រៃ

៣

- បានបណ្ដុះកូនឈើគ្រប់ប្រភេទចំនួន ១៣៨ ៦៦២ដើម ក្នុងនោះបណ្ដុះកូនឈើដោយខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣០ ៩៦២ដើម និងថ្នាលបណ្ដុះកូនឈើចំនួន ៦ចំនួន ១០១ ៧០០ដើម។ ចែកចាយកូនឈើសម្រាប់ដាំអាស្រ័យផលចំនួន ៦ ៧៨៨ដើម ខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៦ ៧៨៨ដើម និងថ្នាលបណ្ដុះកូនឈើទទួលថវិកាពីនាយកដ្ឋាន (ថវិការដ្ឋ) ចំនួន ៥ ០០០ដើម។

### ៣.៥ ការងារនីតិកម្ម និងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១៦៤ករណី (ព្រៃឈើចំនួន ១៤០ករណី សត្វព្រៃចំនួន ៨ករណី និងកាប់រានដីព្រៃចំនួន ១៦ករណី)

- វត្ថុតាងនៃបទល្មើសព្រៃឈើបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងចំនួន ២៥ម៣ គ្រាក់ក្រញូងចំនួន ០,៣២៤ម៣ និង៨៦០គ.ក្រ ឈើអារសរុបចំនួន ២៤៩ម៣ ផ្ទៃដីព្រៃឈើកាប់រានទំហំ ៤០៨ហ.ត។

### ៣.៦ ការងារឧស្សាហកម្ម និងពាណិជ្ជកម្ម

- បានចុះពិនិត្យសំណើសុំបង្កើតរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៦នៅខេត្តបាត់ដំបង បន្ទាយមានជ័យ មណ្ឌលគិរី ព្រៃវែង កំពង់ស្ពឺ និងខេត្តកណ្ដាល និង សំណើសុំពន្យារសុពលភាពរោងសន្និធិលក់ចែកចាយផលអនុផលព្រៃឈើប្រភេទធំ (ច្រកចេញចូលតែមួយ) ចំនួន ៦នៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង ព្រៃវែង រតនគិរី កំពង់ធំ និងខេត្តកណ្ដាល

- ក្រុមហ៊ុនចំនួន ៦បាននាំចេញផលិតផលរានទេវតា ឈើកែច្នៃ និងជ័រទឹក ទៅក្រៅប្រទេសចំនួន ៣៨៧ម៣ និងជ័រទឹកចំនួន ១២៨តោន

- ក្រុមហ៊ុនចំនួន ២បាននាំចូលឈើកែច្នៃមានបរិមាណចំនួន ៤០០ម៣

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន ៤មានឈើកែច្នៃចំនួន ៥៥ម៣ ឫស្សីកែច្នៃចំនួន ២៥តោន និងជ័រទឹកចំនួន ១០៨តោន

- បានផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលជូនក្រុមហ៊ុនចំនួន ១មានឈើកែច្នៃចំនួន ៦០០ម៣។

### ៣.៧ ការងារចំណូលព្រៃឈើ

- បានចំណូលពីថ្លៃសួយសារផលអនុផលព្រៃឈើចំនួន ១ ៩៤៨ ១៤៣ ៤៥៧រៀល និង៧៥៦ ៣៥៨,០៣ដុល្លារ។

## ៤ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

**៤.១ ការងារផលិតកម្មសត្វ៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្ដុះបណ្ដាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្ដាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្ដារាជធានី-ខេត្តរៀងរាល់សប្ដាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើស្តូនដំណាំចំណីសត្វ ការផ្ដល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ និងចុះពិនិត្យនិងកែសម្រួលឡជីវឧស្ម័នដែលបានសាងសង់រួចហើយ ដែលមានបញ្ហាបច្ចេកទេសនៅតាមខេត្តគោលដៅ។

### ៤.២ ការងារសុខភាពសត្វ

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖** បទល្មើសសត្វនិងផលិត-ផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន ១៤ករណី។ រាជធានី-ខេត្តចំនួន ២៥ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៥១ ៤៧៧លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វ។
- **ការងារផ្សព្វផ្សាយបច្ចេកទេស**

- ពិនិត្យ និងកែសម្រួលលើឯកសារជំងឺបេស្ដជ្រូកអាហ្វ្រិក (ASF) ចូលរួមផ្សព្វផ្សាយ និងទប់ស្កាត់ជំងឺផ្ដាសាយបក្សីនៅឃុំនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង និងចុះផ្សព្វផ្សាយជំងឺឆ្លងសត្វនៅតាមបណ្ដាខេត្តចំនួន៤។

៤

- **ការងារនីតិកម្ម និងវិវាទ**

- កំពុងប្រជុំពិភាក្សាផ្ទៃក្នុងនាយកដ្ឋានលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការធ្វើអាជីវកម្មពិឃាតសត្វ ទីកន្លែងកែច្នៃបឋមផលិតផលសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគំរូសំណុំលិខិតដោះស្រាយបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

**៤.៣ ការងារស្រាវជ្រាវ**

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ១០៤ក្បាល។
- **ការងារស្រាវជ្រាវសុខភាពសត្វ៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៤ ២៦៩វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។ ជំងឺផ្តាសាយបក្សីមានផ្ទុះចំនួន១កន្លែងនៅភូមិព្រៃកតាប្រែង ឃុំព្រៃងនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបងកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១។ ជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF) បានរកឃើញតាមរយៈការលួចនាំជ្រូកចូលពីប្រទេសថៃ ចំនួន ២ករណី ពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ និងថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ នៅខេត្តបន្ទាយមានជ័យ និងត្រូវមន្ត្រីជំនាញសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធសម្រេចដុតកម្ទេចចោលតាមវិធានការបសុពេទ្យ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ជាយត្រីអនុវត្តបានចំនួន ១ ៣១០តោន ស្មើនឹង១០,៩២% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១៩០តោន

- នេសាទគ្រួសារដែននេសាទអនុវត្តបានចំនួន ៥៦ ៨០០តោន ស្មើនឹង១៦,៤៦% នៃផែនការចំនួន ៣៤៥ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១២ ៦០០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ១២ ៨០០តោន ស្មើនឹង៨,៨៣% នៃផែនការចំនួន ១៤៥ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៤ ៧០០តោន។

#### ៥.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ២៥ ៧៨០តោន ស្មើនឹង១៩,៨៣% នៃផែនការចំនួន ១៣០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៨០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ៤៤ ៨០០តោន ស្មើនឹង៩,៣១% នៃផែនការចំនួន ៤៨១ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៧ ០០០តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៧ ៥០០ក្បាល ស្មើនឹង៨,៣៣% នៃផែនការចំនួន ៣៣០ ០០០ក្បាល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៣ ២៥០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ៤៩ ៥០០ ០០០កូន ស្មើនឹង១៨,៣៣% នៃផែនការចំនួន ២៧០ ០០០ ០០០កូន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួនប្រមាណ ១ ០០០ ០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ១៥ ២១០តោន ស្មើនឹង១៩,០១% នៃផែនការចំនួន ៨០ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ២ ៥៤០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ២ ៧០០តោន ស្មើនឹង២២,៥០% នៃផែនការចំនួន ១២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៥០តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ១២ ២៥០ ០០០លីត្រ ស្មើនឹង២២,២៧% នៃផែនការចំនួន ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៥០ ០០០លីត្រ។

### ៥.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ៦៤៨ករណី ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ៤៩ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ៦៣២ករណី និងសមុទ្រចំនួន ១៦ករណី។

### ៥.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់នាំចេញចំនួន ៩៧៨តោន ស្មើនឹង១២,២៣% នៃផែនការចំនួន ៨ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ១៦២តោន
- ផលនេសាទកែច្នៃនាំចេញចំនួន ១៧២តោន ស្មើនឹង៨,៦០% នៃផែនការចំនួន ២ ០០០តោន ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ ថយចុះចំនួន ៦០តោន។

### ៥.៦ ការប្រមូលថវិកា

- ចំណូលសេវាផលផលចំនួន ៣៣៧ ៦៥៦ ៧៧៩រៀល ស្មើនឹង៩៤,១៦% នៃផែនការចំនួន ៣៥៨ ៦០០ ០០០រៀល ប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០២០ កើនឡើងចំនួន ២៤៤ ៥៤០ ៦៩៩រៀល។

## ៦ ផ្នែកអគ្គាធិការដ្ឋាន

- ចុះត្រួតពិនិត្យលើការងារអនុវត្តតួនាទីភារកិច្ចរបស់អធិការដ្ឋានរដ្ឋបាលជលផលចតុមុខ និងមេគង្គ
- ចុះស្រាវជ្រាវពាក្យបណ្ដឹងរបស់ឈ្មោះ អូម វ៉ាន់ សុំអន្តរាគមន៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀងប្រគល់ដីស្រែភោគៈមិនទាន់ចុះបញ្ជីទំហំ៤ហ.ត នៅភូមិតាប៉ោញ ឃុំព្រៃតាអី ស្រុកស្វាយទាប ខេត្តស្វាយរៀង
- ចុះត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបការដឹកជញ្ជូនផលិតផលជលផលនាំចេញ នាំចូល និងឆ្លងកាត់គ្មានការអនុញ្ញាតនៅខេត្តតាកែវ កណ្ដាល ត្បូងឃ្មុំ តាកែវ ព្រៃវែង និងខេត្តកំពត
- ចុះស្រាវជ្រាវពាក្យបណ្ដឹងរបស់មន្ត្រីរាជការនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាបពីភាពមិនប្រក្រតីលើការដឹកនាំ និងគ្រប់គ្រងរបស់លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប
- ចុះធ្វើអធិការកិច្ចលើការងារដឹកនាំ និងគ្រប់គ្រងរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបន្ទាយមានជ័យ និងពិនិត្យលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរដែលក្រសួងបានណែនាំឱ្យកែលម្អកន្លងមក
- ស្រាវជ្រាវព័ត៌មានតាមបណ្ដាគេហទំព័រពាក់ព័ន្ធនឹងវិស័យកសិកម្មចំនួន ៤៥៦ករណី
- ការចូលរួមកម្មវិធីប្រជុំ សិក្ខាសាលា និងការងារសង្គមចំនួន ២៤លើក។

## ៧ ផ្នែករដ្ឋបាល

- បានទទួលលិខិតសរុបចំនួន ២ ១២៦ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៨៤៣ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៩៣៩ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ៣៤៤ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល
- បានបញ្ជូនឯកសារ និងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ២ ៤៧៨ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរចំនួន ១៥១ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ៧៦ច្បាប់
- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបាននូវរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្ដាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម)។

## ៨ ផ្នែកបុគ្គលិក និងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៥ ៨២៨នាក់ (ស្រី១ ៤១៥នាក់ ស្មើនឹង២៤,២៧%) រួមមាន៖
  - \+ អង្គភាពថ្នាក់កណ្ដាលចំនួន ២ ៩១៣នាក់ (ស្រី៨២១នាក់ ស្មើនឹង២៨,១៨%)
  - \+ អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ២ ៩១៥ នាក់ (ស្រី៥៩៤នាក់ ស្មើនឹង២០,៣៧%)
- តែងតាំងដំឡើងឋានៈ និងផ្ទេរសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ៧០នាក់ (ស្រី២៩នាក់)
- រៀបចំប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌចំនួន ៧នាក់ (ស្រី៣នាក់)
- រៀបចំលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកការងារចំនួន ១៧នាក់ (ស្រី១០នាក់) ក្នុងនោះ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន ៤នាក់ ច្បាប់ឈប់សម្រាករយៈពេលខ្លីចំនួន ១នាក់ ច្បាប់ឈប់សម្រាកលំហែមាតុភាពចំនួន ៦នាក់និងឈប់សម្រាកសម្រាប់ព្យាបាលជំងឺចំនួន ៦នាក់

៦

- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ចំនួន ៨នាក់ (ស្រី៦នាក់)
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈចំនួន ១នាក់
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការចូលបម្រើការងារវិញចំនួន ២នាក់
- រៀបចំប្រកាសដាក់ឱ្យមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៩នាក់ (ស្រី១នាក់)
- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៥៨៥នាក់ (ស្រី១៤៩នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ៥៨១នាក់ (ស្រី១៤៨នាក់)
  + ការបណ្តុះបណ្តាលក្រៅប្រទេសចំនួន ៤នាក់ (ស្រី១នាក់)។

## ៩ ផ្នែកផែនការ និងស្ថិតិ

- បានចូលរួមកិច្ចប្រជុំអន្តរក្រសួងកម្រិតបច្ចេកទេសដើម្បីពិនិត្យកែសម្រួលបញ្ជីចំណុចដៅសូចនាករ និងតម្លៃចំណុចដៅសូចនាករតាមឆ្នាំនីមួយៗរបស់របស់គោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា(គ.អ.ច.ក) ផ្អែកលើផលប៉ះពាល់នៃការរីករាលដាលនៃមេរោគកូវីដ-១៩
- បានអនុញ្ញាតជាគោលការណ៍ឱ្យមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកណ្តាលបញ្ចេញដោះដូរពូជស្រូវជលសារចំនួន ៦ ៩៦៩គ.ក្រ
- បានចុះពិនិត្យ និងផ្ទៀងផ្ទាត់សន្និធិស្រូវពូជនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តបាត់ដំបង
- បានធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងឆ្នាំ២០២១ នៅខេត្តក្រចេះ ពោធិ៍សាត់ បាត់ដំបង និងខេត្តកំពង់ឆ្នាំង
- បានធ្វើការតាមដានការងារត្រួតពិនិត្យ វាយតម្លៃលើការធ្វើអង្កេតស្ទង់ទិន្នផលស្រូវប្រាំងបានទាន់ពេលវេលាសម្រាប់ធ្វើតុល្យភាពស្បៀងប្រចាំឆ្នាំ២០២១
- បានពិនិត្យតាមដានល្បឿនការងារបង្កបង្កើនផលស្រូវប្រាំងឆ្នាំ២០២១
- បានចុះប្រមូលព័ត៌មានតម្លៃទីផ្សារកសិផលលក់ដុំក្នុងមួយសប្តាហ៍បីដងគឺថ្ងៃចន្ទ ពុធ និងសុក្រ និងតម្លៃលក់រាយម្តងក្នុងមួយសប្តាហ៍នៅរៀងរាល់ថ្ងៃព្រហស្បតិ៍តាមបណ្តាទីផ្សារសំខាន់ៗទីតាំងប្រមូលទិញ និងកន្លែងលក់ដុំផលិតផលក្នុងបណ្តារាជធានីខេត្តចំនួន២៥ និងបញ្ចូលទិន្នន័យទៅក្នុងកុំព្យូទ័រ https://tmp.amis.org.kh ធ្វើការកែច្នៃ វិភាគទិន្នន័យសម្រាប់ធ្វើរបាយការណ៍ប្រចាំខែ និងឆ្នាំ។

## ១០ ផ្នែកគណនេយ្យ ហិរញ្ញវត្ថុ

- បានអនុវត្តប្រមូលចំណូលនូវទឹកប្រាក់សរុបមានចំនួន ១៥ ២៥៦ ៨៣៣ ៤៤០រៀល
- បានបញ្ចេញអាណត្តិបើកប្រាក់ពីក្រសួងសរុបមានចំនួន ២០ ៥៤០ ៨៩៣ ១៤៨រៀល
- បានចុះប្រតិបត្តិការចំណូលក្នុងប្រព័ន្ធNRMIS សរុបទឹកប្រាក់ចំនួន ១៤ ៧៨២ ៨៧៤ ១១៤រៀល
- បានរៀបចំសំណើសុំថវិកាចំនួន ៤១ ២៩១,២៥ដុល្លារ និងចំនួន ២៥ ៦២០អឺរ៉ូ សម្រាប់ទូទាត់ជូនក្រុមហ៊ុន Agriconsulting Europe S.A (AESA) ក្នុងការអនុវត្តកម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish Aquaculture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់ទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍ (AFD)
- បានរៀបចំសំណើសុំពិនិត្យគាំទ្រផែនការសកម្មភាពឆ្នាំ២០២១ របស់កម្មវិធីជំរុញកំណើនវិស័យជលផលប្រកបដោយចីរភាព និងបរិយាប័ន្នផ្នែកវារីវប្បកម្ម (CaPFish-Capture) ក្រោមហិរញ្ញប្បទានឥតសំណងរបស់សហភាពអឺរ៉ុប
- បានទទួលបង្កាន់ដៃបង់ប្រាក់ថ្លៃសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៤
- បានចុះពិនិត្យការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មនៅខេត្តព្រៃវែង កំពង់ចាម និងខេត្តកំពង់ឆ្នាំង
- បានចុះពិនិត្យ និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ចនៅខេត្តពោធិ៍សាត់ បាត់ដំបង និងខេត្តសៀមរាប របស់ក្រុមហ៊ុនចំនួន៨
- បានរៀបចំលិខិតជូនដំណឹងស្តីពីកាតព្វកិច្ចបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនក្រុមហ៊ុនចំនួន២១
- បានចូលរួមប្រជុំ ពិនិត្យ សិក្សា និងវាយតម្លៃមធ្យោបាយដឹកជញ្ជូនបទល្មើសព្រៃឈើគ្រប់ប្រភេទរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ ត្បូងឃ្មុំ ក្រចេះ កំពត និងខេត្តកំពង់ស្ពឺដែលស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- បានរៀបចំឯកសារសម្រាប់ដេញថ្លៃ និងចរចាថ្លៃចំនួន ៣គម្រោង

៧

- បានចុះពិនិត្យលើដំណើរការអនុវត្តកិច្ចសន្យាស្តីពីការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពនៅតាមបណ្តាសហគមន៍កសិកម្មចំនួន ៦ស្ថិតក្នុងខេត្តកំពង់ចាម ព្រៃវែង និងខេត្តកំពង់ឆ្នាំងរបស់អគ្គនាយកដ្ឋានកសិកម្ម ដែលអនុវត្តដោយនាយកដ្ឋានវិស្វកម្ម

- បានចូលរួមប្រជុំ ពិនិត្យ និងវាយតម្លៃការលក់ផលឈើដាំមានក្នុងទីតាំងស្ថានីយ៍ផ្សព្វផ្សាយនិងស្តារព្រៃឈើបឹងចារ ស្រុកសំបូរ ខេត្តក្រចេះ និងស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

## ១១ ផ្នែកសវនកម្មផ្ទៃក្នុង

- បានរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៩ (ឆ្នាំគោល) និងធ្វើការគ្រប់គ្រង បែងចែកសម្ភារការិយាល័យ សង្ហារិម សម្ភារបរិក្ខារបច្ចេកទេស ថែទាំ និងជួសជុល

- បានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងឆ្នាំ២០២១-២០២៣ ផែនការសវនកម្មផ្ទៃក្នុងឆ្នាំ២០២១ ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២១-២០២៣ ផែនការថវិកាឆ្នាំ២០២១ ផែនការលទ្ធកម្មសាធារណៈឆ្នាំ២០២១ និងផែនការវជ្ជ-ទេយ្យបុរេប្រទានឆ្នាំ២០២១

- រៀចំរបាយការណ៍តាមដាន និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីតាមទម្រង់ M1 ប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆមាសទី១ M2 ប្រចាំឆ្នាំ និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ។

## ១២ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចូលរួមកិច្ចប្រជុំចំនួន ១លើក ក្រោមក្របខ័ណ្ឌទ្វេភាគី និងពហុភាគី
- បានចូលរួមកិច្ចប្រជុំ (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ចំនួន ២លើក ក្រោមក្របខ័ណ្ឌអាស៊ាន
- បានចូលរួមសិក្ខាសាលា (តាមប្រព័ន្ធវីដេអូពីចម្ងាយ) ចំនួន ២លើក ក្រោមក្របខ័ណ្ឌអាស៊ានលើការងារក្រៅប្រទេស
- បានសម្របសម្រួលរៀបចំកិច្ចប្រជុំចំនួន ៤លើក
- បានសម្របសម្រួលការចុះហត្ថលេខារវាងអង្គការ FAO និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១គម្រោង
- បានសម្របសម្រួលការងារកិច្ចព្រមព្រៀងអនុវត្តគម្រោងជាមួយអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ១គម្រោងគិតជាទឹកប្រាក់ចំនួន ៤ ៣៥០ ០០០ដុល្លារអាមេរិក
- បាននិងកំពុងសម្របសម្រួលការស្នើសុំចុះកិច្ចព្រមព្រៀងអនុវត្តគម្រោងរបស់អង្គការ Swisscontact និងអង្គការអភិរក្សនិងការពារសត្វព្រៃ
- បានសម្របសម្រួលរៀបចំការចុះហត្ថលេខារវាងអង្គការ FAO ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទស្តីពី Climate Adaptationand Resilience in Cambodia Coastal Fishery Dependent Communities។

## ១៣ ផ្នែកនីតិកម្មកសិកម្ម

### ១៣.១ ការិយាល័យអាជីវកម្មជី-ថ្នាំកសិកម្ម

- ផ្តល់វិញ្ញាបនបត្របញ្ជាក់បញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៩ក្រុមហ៊ុន សរុបចំនួន ៧៨៦មុខ
- ផ្តល់លិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦៥ក្រុមហ៊ុន
- ផ្តល់លិខិតអនុញ្ញាតនាំចេញថ្នាំកសិកម្ម និងជីកសិកម្មចំនួន ២ក្រុមហ៊ុន
- ផ្តល់វិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៨ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៧ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតវេចខ្ចប់ជាថ្មីជីកសិកម្មចំនួន ២ក្រុមហ៊ុន។

### ១៣.២ ការិយាល័យមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ២១ក្រុមហ៊ុន សរុបចំនួន ៩០សំណាក។

### ១៣.៣ ការិយាល័យអភិវឌ្ឍបទដ្ឋានគតិយុត្ត

បានពិនិត្យ និងផ្តល់មតិចំនួន ៩ករណី។

### ១៣.៤ ការិយាល័យអនុវត្តច្បាប់

- ចុះត្រួតពិនិត្យការនាំចូលថ្នាំកសិកម្ម និងជីកសិកម្ម និងផ្តល់សុពលភាពផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្ម

៨

ចំនួន ៣៧ក្រុមហ៊ុន

- អនុញ្ញាតចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្ម និងលាយផ្សំវេចខ្ចប់ជាថ្មីចំនួន ១៤ក្រុមហ៊ុន

- បានចុះធ្វើអធិការកិច្ចត្រួតពិនិត្យបទល្មើសថ្នាំកសិកម្ម និងជីកសិកម្មខេត្តគោលដៅចំនួន ៩ខេត្ត គឺខេត្តព្រះវិហារ ឧត្តរមានជ័យ កំពង់ចាម កំពត កែប បន្ទាយមានជ័យ បាត់ដំបង ព្រះសីហនុ និងខេត្តកោះកុង។

## ១៤ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- ស្រង់ព័ត៌មានប្រចាំថ្ងៃសកម្មភាពរបស់ថ្នាក់ដឹកនាំក្រសួង និងតាមបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តដើម្បីផុសក្នុងហ្វេសប៊ុកផេកក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសរុបចំនួន ៥៤២ព័ត៌មាន

- បានដាក់ឱ្យដំណើរការប្រើប្រាស់អ៊ីម៉ែល (@maff.gov.kh) ផ្លូវការរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ថ្នាក់ដឹកនាំប្រើប្រាស់ក្នុងការទំនាក់ទំនងផ្លូវការ

- បានបង្កើត Sub Domain (dal.maff.gov.kh) របស់នាយកដ្ឋាននីតិកម្មកសិកម្មសម្រាប់ភ្ជាប់ទៅកាន់ប្រព័ន្ធ QR Code នៃព័ត៌មានផលិតផលថ្នាំកសិកម្មដែលបានចុះបញ្ជី

- បានថែទាំលើគេហទំព័រ (Web) និង Mobile App របស់ក្រសួង និងអង្គភាពក្រោមឱវាទក្រសួងសរុបចំនួន ១៧ (១៦គេហទំព័រ និង១កម្មវិធី) និងគេហទំព័រមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត

- បានសម្អាត Cache នៅលើ Cloud server នៃគេហទំព័រទាំង៤១ និងតាមដានទិន្នន័យដែលផ្ទុកនៅលើ Cloud server នៃគេហទំព័រទាំង៤១

- តំឡើងប្រព័ន្ធ Firewall សម្រាប់ម៉ាស៊ីនមេដើម្បីការពារការលុកចូលពីខាងក្រៅ (Hacker)

- បណ្ណាល័យកសិកម្មទទួលសៀវភៅ ឯកសារបច្ចេកទេសកសិកម្ម ទស្សនាវដ្តី ដែលទទួលបានពីនាយកដ្ឋាន-កិច្ចការរដ្ឋបាល នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងផ្នែកផ្សេងៗសរុបចំនួន ១៦៧ក្បាល/ច្បាប់។

## ១៥ ផ្នែកផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹមបង្កង ភ្ញាស់កូនបង្កងលក់ បច្ចេកទេសចិញ្ចឹមមាន់ ភ្ញាស់កូនមាន់លក់ និងការដាំដុះបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់នៅក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

- បានសហការជាមួយទូរទស្សន៍ជាតិកម្ពុជាចុះផលិតខ្សែវីដេអូបទយកការណ៍ស្តីពីបច្ចេកទេសចិញ្ចឹម និងភ្ញាស់ពូជ-មាន់ខ្មៅ មាន់ស្រែ ត្រីអណ្តែង ត្រីឆ្លាញ ខ្យង ចិញ្ចឹមទា និងកង្កែប ដំណាំបន្លែខាត់ណាដើម ខាត់ណាផ្កាក្នុងផ្ទះសំណាញ់ ផលិតកម្មសត្វ នៅខេត្តមណ្ឌលគិរី ក្រចេះ កណ្តាល និងខេត្តតាកែវ

- បានចុះទៅថត Video បទយកការណ៍ចំនួន ៤ប្រធានបទ
- បានផលិត Video វេទិកាស្វែងយល់ពីកសិកម្មចំនួន ៤ប្រធានបទ
- បានផលិត Video នាទីចុះស្រែជាមួយកសិករចំនួន ៤ប្រធានបទ
- បានបញ្ជូនអត្ថបទបច្ចេកទេសកសិកម្មចំនួន ១៨ដើម្បីចាក់ផ្សាយ
- បានធ្វើការបោះពុម្ពសម្ភារផ្សព្វផ្សាយចំនួន ៥ប្រធានបទ
- បានជួយដោះស្រាយបញ្ហា និងផ្តល់ព័ត៌មានបច្ចេកទេសកសិកម្មដល់កសិករ និងអតិថិជនចំនួន ៦៩សំណួរចម្លើយ។

## ១៦ ផ្នែកកសិ-ឧស្សាហកម្ម

- ចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការស្នើសុំបង្កើតរោងចក្រសិប្បកម្មកែច្នៃកៅស៊ូ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធគ្រប់គ្រងសុវត្ថិភាព និងគុណភាពចំណីអាហារតាមប្រព័ន្ធ Online
- ចូលរួមជាកិត្តិយសក្នុងសិក្ខាសាលាចាប់ផ្តើមអនុវត្ត និងពិធីចុះអនុស្សរណៈយោគយល់គ្នាស្តីពីគម្រោងបន្លែ ផ្លែឈើកម្ពុជា
- ចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យ និងផ្តល់ធាតុចូលលើក្របខ័ណ្ឌជំរុញវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម
- ចូលរួមប្រជុំលើកទី១របស់ក្រុមការងារអន្តរក្រសួង តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តគោលនយោបាយ និងផែនការសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម

៩

- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីរបាយការណ៍សិក្សាស្វែងយល់ពីវឌ្ឍនភាព និងឧបសគ្គក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣

- ចូលរួមដំណើរការជាមួយអ្នកជំនាញការ JICA ចុះពិនិត្យ និងសិក្សាបញ្ហាពាក់ព័ន្ធនឹងខ្សែច្រវាក់ផលិតកម្មស្វាយចន្ទីរបស់សហគមន៍កសិកម្មដែលស្នើសុំគម្រោង KUSANONE នៃរដ្ឋាភិបាលជប៉ុននៅខេត្តកំពង់ធំ

- ចុះពិនិត្យសិក្សាទីតាំងសមស្របសម្រាប់បើកវគ្គបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពផលនេសាទសមុទ្រ

- ចុះរៀបចំវគ្គបណ្តុះបណ្តាលបច្ចេកទេសគ្រប់គ្រងគុណភាព និងសុវត្ថិភាពក្រោយប្រមូលផលនេសាទសមុទ្រនៅខេត្តព្រះសីហនុជាមួយជំនាញការជប៉ុនលើខ្សែច្រវាក់តម្លៃប្រចាំនៅនាយកដ្ឋានកសិ-ឧស្សាហកម្ម

- ចុះរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

- បានបន្តបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពបុគ្គលិករោងចក្រកែច្នៃគ្រាប់ស្វាយចន្ទី ជ័យសំបូរ នៅខេត្តកំពង់ធំ អំពីប្រព័ន្ធ HACCP ការប្រើប្រាស់ឧបករណ៍ សម្ភារ និងគ្រឿងម៉ាស៊ីន

- ចុះសិក្សាស្រាវជ្រាវដំណាក់កាលស៊ីជម្រៅអំពីគំរូអាជីវកម្មរបស់ក្រុមហ៊ុន សហគមន៍កសិកម្ម និងបណ្តុំកសិករក្នុងខេត្តព្រះវិហារដោយសហការជាមួយមជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS)

- ធ្វើការវិភាគសំណាកចំណីសត្វ និងវត្ថុធាតុដើមរបស់រោងចក្រធំៗចំនួន១៧

- ធ្វើការវិភាគលើផលិតផលជលផល (ត្រីស្រស់) នាំចូលពីប្រទេសវៀតណាម។

## ១៧ ការស្រាវជ្រាវ ការអប់រំ និងការបណ្តុះបណ្តាលកសិកម្ម

### ១៧.១ វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានប្រមូលប្រភេទពូជដំណាំថ្មីៗបន្ថែមទៀតចំនួន ៥ប្រភេទ សរុបចំនួន ៧០សំណាក (ត្រសក់២៨សំណាក ល្ពៅ៣៤សំណាក ឪឡឹក២សំណាក ត្រប់៤សំណាក និងម្ទេស២សំណាក) មករក្សាទុកក្នុងធនាគារពន្ធុរបស់វិទ្យាស្ថាន និងបន្តការអភិរក្សពូជដំណាំនៅក្នុងវិទ្យាស្ថានចំនួន ៣៨ប្រភេទ រួមមានស្រូវចំនួន ៦ ៧៧៦បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន ៣៧ប្រភេទសរុបចំនួន ២ ៤៨១បញ្ជីក/សំណាក សរុបទាំងអស់ចំនួន ៩ ២៥៧បញ្ជីក/សំណាក។ ដាំវាយតម្លៃ និងកំណត់លក្ខណៈលើដំណាំ៤មុខ គឺមេទ្បុងចំនួន ៥០សំណាក ម្ទេសចំនួន ៥០សំណាក ល្ពៅចំនួន ៣០សំណាក និងត្រប់ចំនួន ៤០សំណាក

- បានធ្វើពិសោធន៍ចំនួន ៤៥ប្រភេទ នៅ១៤៦កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករ និងស្រែបង្ហាញចំនួន ៧០កន្លែង និងបើកវគ្គបណ្តុះបណ្តាលកសិករចំនួន ៤លើក មានកសិករចូលរួមចំនួន ១៥០នាក់ (ស្រី៩៥នាក់)

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន ៨លើកមានថ្នាក់ដឹកនាំនិងមន្ត្រីវិទ្យាស្ថានចូលរួមចំនួន ៥៨នាក់ (ស្រី១៤នាក់)។ មន្ត្រីសរុបចំនួន៤នាក់ទៀត បាននិងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតចំនួន ២នាក់ និងបរិញ្ញាបត្រជាន់ខ្ពស់ចំនួន ២នាក់នៅប្រទេសកូរ៉េ ជប៉ុន និងប្រទេសចិន

- អ្នកបើកស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មរបស់វិទ្យាស្ថានសរុបចំនួន ៤០៩ ៨១៣នាក់ និងគិតជាមធ្យមមានប្រមាណ ៦ ០២៦នាក់/ថ្ងៃ

- ថ្នាក់ដឹកនាំវិទ្យាស្ថានបានចូលរួមកិច្ចប្រជុំនានានៅក្នុងប្រទេសចំនួន៩លើក និងស្ថាប័ន/អង្គភាពនានាចំនួន ៩លើក ហើយទទួលជួបភ្ញៀវជាតិ អន្តរជាតិនៅវិទ្យាស្ថានចំនួន ៣លើក មានភ្ញៀវសរុបចំនួន ១៩នាក់។

### ១៧.២ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាក្នុងឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ៣ ២៥៦នាក់ ចែកចេញជា១០ មហាវិទ្យាល័យ គឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រជលផល កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ រៀបចំដែនដីនិងរដ្ឋបាលដីធ្លី និងមហាវិទ្យាល័យវិទ្យាសាស្ត្រកៅស៊ូ និងសាលាក្រោយឧត្តម

- បាននិងកំពុងដំណើរការបង្រៀននិស្សិតពីចំងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិកសម្រាប់កម្មវិធីសិក្សាឆមាសទី១ ឆ្នាំសិក្សា២០២០-២០២១ និងត្រៀមលក្ខណៈដើម្បីប្រលងបញ្ចប់ឆមាសទី១

- បានរៀបចំដឹកនាំនិស្សិតថ្នាក់បរិញ្ញារងជំនាន់ទី១០ (លក្ខណៈទ្រង់ទ្រាយតូច) ធ្វើទស្សនកិច្ចសិក្សាទៅកាន់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ

១០

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Laboratory Risk Assessment ដែលរៀបចំដោយ VOHUN និងដៃគូសហការ ចូលរួមជាគ្រូបង្គោលក្នុងវគ្គបណ្តុះបណ្តាលស្តីពីការស្រាវជ្រាវអេពីដេមីសាស្ត្រតាមការសម្របសម្រួលដោយ CAMBOHUN និងចូលរួមជាវាគ្មិនធ្វើបទបង្ហាញស្តីអំពីការបញ្ជូនកម្រិតភាពស៊ាំរបស់ជ្រូកមេ ទៅកូនជ្រូកតាមរយៈទងសុកនិងទឹកដោះដំបូងក្នុងសន្និសីទអន្តរជាតិអនឡាញលើកទី១២ របស់ ICERD

- បន្តការងារសិក្សាពិសោធន៍ស្រាវជ្រាវរបស់ខ្លួនលើប្រធានបទមួយចំនួនដូចជា ការកែច្នៃត្រសក់ចាវដោយបន្ថែមឡាក់ទិចអាស៊ីតបាក់តេរីការធ្វើតេស្តភាពធន់របស់បាក់ទិចអាស៊ីតបាក់តេរីទៅកម្រិត Bile sal ការសិក្សាពី Trichoderma spp ការពិសោធន៍អំពីដំណាំខ្ទឹមបារាំង ហើយនិស្សិតមួយចំនួនចុះហាត់ការងារផ្ទាល់នៅមន្ទីរពេទ្យសត្វ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្មជាជំនួយការថែទាំសត្វដែលសម្រាកព្យាបាលនៅមន្ទីរពេទ្យ ការវះកាត់គ្រាវសត្វឆ្មា និងឆ្កែ ចាក់វ៉ាក់សាំងនិងទម្លាក់បរាសិត។

### ១៧.៣ វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០២០-២០២១ សរុបចំនួន ១ ១២៧នាក់ (ស្រី៤៦៤នាក់) លើជំនាញៈ កសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិស្វកម្មកសិកម្ម ព្រៃឈើ ជលផល សាកវប្បកម្ម សុរិយោដីនិងការគ្រប់គ្រងដី ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ចកសិកម្ម មីក្រូហិរញ្ញវត្ថុ កែច្នៃអាហារ កុំព្យូទ័រ សេដ្ឋកិច្ចនយោបាយនិងស្បៀង និងភាសាអង់គ្លេស

- បាននិងកំពុងជំរុញការងារស្រាវជ្រាវ និងសហប្រតិបត្តិការជាមួយដៃគូសម្រាប់ការបណ្តុះបណ្តាលគម្រោងសិក្សាស្រាវជ្រាវសំខាន់ៗដែលកំពុងដំណើរការ គឺការពិសោធន៍ចិញ្ចឹមគោទឹកដោះ ការពិសោធន៍ចិញ្ចឹមបង្គា ការពិសោធន៍បង្កាត់ពូជមាន់ ការសិក្សាពិសោធន៍ថ្នាំបណ្តេញសត្វល្អិត ការពិសោធន៍ចិញ្ចឹមពពែនៅតំបន់ភ្នំ ការសិក្សាស្រាវជ្រាវបង្កាត់គេសរកូលការពិសោធន៍ដំណាំព្រីង ការសិក្សាពិសោធន៍ផលិតម្សៅឫស្សី ការបណ្តុះជាលិការុក្ខជាតិ ការពិសោធន៍ចិញ្ចឹមកង្កែបសាងសង់កសិដ្ឋានវារីសត្វ-រុក្ខជាតិ ការពិសោធន៍ចិញ្ចឹមត្រីបបែលនិងត្រីលម្អផ្សេងៗ ការសិក្សាផលិតកម្ម និងច្រវ៉ាក់តម្លៃស្វាយចន្ទី

- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្រស្រាវជ្រាវអេពីដេមីសាស្ត្រ
- បាននិងកំពុងសាងសង់ SMART FARM នៅក្នុងវិទ្យាស្ថានជាតិជិតរួចរាល់
- បានទៅពិនិត្យស្ថានីយ៍ពិសោធន៍កសិកម្មត្រាំកក់នៅខេត្តតាកែវ។

### ១៧.៤ វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០២០-២០២១ សរុបចំនួន ៥៨៨នាក់ (ស្រី២៦៨នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម ក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- បានរៀបចំបន្ទាន់លើការងារបង្រៀនតាម Online សម្រាប់និស្សិត
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើកម្មវិធីសិក្សាអំពីការប្រើប្រាស់ថាមពលកកើតឡើងវិញ (RET)
- បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយផែនការសកម្មភាពពហុវិស័យស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគនៅកម្ពុជា
- ពិសោធន៍លើជីសរីរាង្គពីការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- ពិសោធន៍តាមដានការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- ពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ប្រភពទឹកពីអាងចិញ្ចឹមត្រីនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហមនៅស្ថានីយពិសោធន៍ជលផលនៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម
- បានធ្វើការសាកល្បងចម្រាញ់ប្រេងស្វាយចន្ទីសម្រាប់ផលិតជាគ្រឿងក្រអូប
- បានចូលរួមបណ្តុះបណ្តាលកសិករជាមួយដៃគូរបស់ក្រុមហ៊ុន និងធ្វើការស្រាវជ្រាវរួមគ្នាអំពីការកែច្នៃកសិផលលើដំណាំស្វាយចន្ទី ល្ហុង ល្មៅ ក្រូចថ្លុង ស្លឹកគ្រៃ និងម្រេច
- បានបណ្តុះបណ្តាលមន្ត្រីលើការងារគ្រប់គ្រងមន្ទីរពិសោធន៍ និងវិភាគបាក់តេរីនៅវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា។

### ១៧.៥ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ត្រួតពិនិត្យទូទៅការការពារ និងថែទាំចម្ការពិសោធន៍ក្លូន កូនកៅស៊ូស៊ីដលីង ច្បារបង្កាត់ពូជ
- ស្រង់ទិន្នន័យ បញ្ចូល និងវិភាគទិន្នន័យចម្ការពិសោធន៍ក្លូនចំនួន ១២ចម្ការពិសោធន៍

១១

- ត្រួតពិនិត្យការចៀរជ័រ ការសាប្រមូលផលទឹកជ័រ និងស្រង់ទិន្នន័យជ័រកៅស៊ូតាមពិធីសាពិសោធន៍គ្រប់ចម្ការពិសោធន៍
- រៀបចំលាយថ្នាំរំញោច Ethephon តាមកំហាប់ខុសៗគ្នាដើម្បីលាបរំញោចតាមពិធីសាពិសោធន៍
- ត្រួតពិនិត្យការប្រមូលផលទឹកជ័រនៅចម្ការពិសោធន៍
- អនុវត្តការបំបៅកូនកៅស៊ូនៅថ្នាលបណ្ដុះកូនឆ្នាំ២០២០-២០២១
- ត្រួតពិនិត្យការប្រមូលផលដំណាំចន្លោះរងកៅ (ស្វាយចន្ទី) ស៊ូនៅចម្ការពិសោធន៍ឥទ្ធិពលនៃដំណាំចន្លោះរលើការលូតលាស់ និងទិន្នផលកៅស៊ូ
- ត្រួតពិនិត្យការលាបប៉េត្រូឡាតូម (ខ្លាញ់គោ) លើផ្ទាំងមុខចៀរជ័របានចៀររយៈពេល១ឆ្នាំកន្លង
- រៀបចំ និងបែងចែកចៀរជ័រថ្មីសម្រាប់អនុវត្តក្នុងឆ្នាំ២០២១
- ត្រួតពិនិត្យការងារកែច្នៃកៅស៊ូសន្លឹកនៅក្នុងរោងចក្រ
- ត្រួតពិនិត្យសម្ភារ និងឧបករណ៍មន្ទីរពិសោធន៍ជាតិយថាប្រភេទ
- ធ្វើតេស្តកៅស៊ូចំនួន ៨សំណាកដើម្បីវាយតម្លៃគុណភាពនៃការកែច្នៃតាមស្តង់ដា CSR។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន ៦៤៩ ៥៣៩ហ.ត ស្មើនឹង១៤១,៤៥% នៃផែនការចំនួន ៤៥៩ ២០០ហ.ត ដោយការប្រមូលផលស្រូវប្រាំងបានចំនួន ៥៣៥ ៣៦៩ហ.ត ដោយទទួលបរិមាណផលសរុបចំនួន ២ ៣៩៦ ៧០៣តោន និងទទួលទិន្នផលគិតជាមធ្យម ៤,៤៧៧តោន/ហ.ត។ ក្រសួងបានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការស្តារការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ការជំរុញឱ្យចុះត្រួតពិនិត្យ និងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើស ចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងបានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្ដាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រឱ្យសម្រេចបាននូវលទ្ធផលល្អប្រសើរតាមផ្នែកនីមួយៗស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្ម។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តវិធានការជំរុញការងារបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០២១
- បន្តធ្វើការជំរុញផលិតកម្មស្បៀងសម្រាប់ឆ្លើយតបទៅនឹងហានិភ័យនៃការឆ្លងរាលដាលជំងឺកូវីដ-១៩
- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេសកសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង
- បន្តជំរុញ និងបណ្ដុះបណ្ដាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាន និងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់នឹងជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- បន្តអង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ។

## ២ ផ្នែកផលិតកម្មសត្វ និងសុខភាពសត្វ

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗ ចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈ និងសញ្ញាណជំងឺជ្រូកគ្រុនៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ ជំងឺឆ្លង(ជំងឺចុងអង្គរ របេងជ្រូក គោ) បន្តតាមដានស្ថានភាពជំងឺស៊ូណូស និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យ កន្លែងផ្ទុះជំងឺ និងកន្លែងដែលរាលដាលជំងឺផ្តាសាយបក្សី (H5N1) និងជំងឺ A(H1N1)

- ជំរុញការអនុវត្តកម្មវិធីផ្សព្វផ្សាយលើកកម្ពស់ការអប់រំយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការប្រើប្រាស់ចំណីសត្វ និងបសុឱសថដល់អាជីវករ និងអ្នកប្រើប្រាស់

- បន្តចុះវាយតម្លៃកសិដ្ឋានចិញ្ចឹមសត្វស្របតាមបច្ចេកទេស និងគោលការណ៍អនុវត្តការចិញ្ចឹមសត្វល្អ តាមខេត្តគោលដៅ

- បន្តរៀបចំឯកសារស្តីពីអត្ថប្រយោជន៍នៃការគ្រប់គ្រងកាកសំណល់សត្វ។

## ៣ ផ្នែកព្រៃឈើ

- ខិតខំបន្តត្រួតពិនិត្យ តាមដាន និងពង្រឹងការគ្រប់គ្រងសកម្មភាពឧស្សាហកម្មឈើ រោងចក្រ សិប្បកម្មកែច្នៃ និងអាជីវកម្មឈើឲ្យបានហ្មត់ចត់ ព្រមទាំងចាត់វិធានការទប់ស្កាត់ និងលុបបំបាត់ការនាំចេញឈើ និងផលិតផលកែច្នៃឈើគ្រប់ប្រភេទដែលគ្មានការអនុញ្ញាតដើម្បីលុបបំបាត់សកម្មភាពដឹកជញ្ជូនឈើខុសច្បាប់ឲ្យមានប្រសិទ្ធភាពខ្ពស់

- បន្តពង្រឹង និងពង្រីកសហគមន៍ព្រៃឈើចូលរួមគ្រប់គ្រងថែរក្សាធនធានព្រៃឈើ តាមដានត្រួតពិនិត្យ ការអនុវត្តផែនការគ្រប់គ្រងព្រៃសហគមន៍ឱ្យបានល្អ ព្រមទាំងបណ្តុះផ្នត់គំនិតបង្កើតមុខរបរថ្មីៗបន្ថែមទៀត ដើម្បីបង្កើនចំណូលតាមរយៈប្រព័ន្ធកសិ-រុក្ខកម្ម ការចិញ្ចឹមសត្វ សំដៅកាត់បន្ថយការពឹងអាស្រ័យលើផល និងអនុផលព្រៃឈើ ជាពិសេសខិតខំជំរុញការផ្សព្វផ្សាយ អប់រំ បណ្តុះបណ្តាល បំពាក់បំប៉នដល់សហគមន៍មូលដ្ឋានយល់ដឹងពីផលប្រយោជន៍ព្រៃឈើ

- បន្តផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ បទប្បញ្ញត្តិ បទបញ្ជា លិខិតបទដ្ឋានគតិយុត្ត ជាពិសេសសេចក្តីជូនដំណឹងលេខ១៣៤៨ សជណ.កជ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រីឱ្យបានជ្រួតជ្រាបដល់មូលដ្ឋានភូមិ ឃុំ សង្កាត់ ស្រុក ខណ្ឌ ក្រុង រាជធានី-ខេត្តទូទាំងប្រទេស ព្រមទាំងមានចំណាត់ការផ្លូវច្បាប់យ៉ាងម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ពាក់ព័ន្ធនឹងការកាប់រាន ដុត ឈូសឆាយ និងហ៊ុមព័ទ្ធដីព្រៃឈើដើម្បីវាតយកដីធ្វើកម្មសិទ្ធិ

- បន្តជំរុញការដាំដុះស្តារព្រៃឈើឡើងវិញដោយសហការជាមួយវិស័យឯកជន ដៃគូអភិវឌ្ឍន៍ ព្រមទាំងបង្កើនការបណ្តុះកូនឈើគ្រប់ប្រភេទនៅតាមស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើសម្រាប់ចែកចាយជូនប្រជាពលរដ្ឋ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

១៣

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"។

### ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់ជី-ថ្នាំកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់ជី-ថ្នាំកសិកម្ម ដើម្បីសុខភាពសាធារណៈ
- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក
- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី
- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្ដែង រួមទាំងការរៀបចំវគ្គបណ្ដុះបណ្ដាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក
- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា អភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាឱ្យមានផលិតភាពខ្ពស់ដោយគិតគូរទៅលើការប្រែប្រួលអាកាសធាតុ និងស្តង់ដារ។

ថ្ងៃច័ន្ទ ៨រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

១៤





ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក ស ក

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សេចក្ដីណែនាំ**
**ស្ដីពី**
**ការចាត់វិធានការបង្ការ និងទប់ស្កាត់ការរាតត្បាតនៃជំងឺកូវីដ ១៩** (Covid-19)

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសូមជម្រាបជូនដល់បណ្ដាក្រុមហ៊ុន សហគ្រាស កសិដ្ឋាន និងសម្បទានដីសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទទាំងអស់ មេត្តាជ្រាបថា ដោយបច្ចុប្បន្នស្ថានភាពនៃជំងឺកូវីដ-១៩មានការរីករាលដាលជាសហគមន៍នោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់ម្ចាស់ក្រុមហ៊ុន សហគ្រាស និងកសិដ្ឋាន ទាំងអស់ត្រូវធ្វើការណែនាំ និងជូនដំណឹងដល់បុគ្គលិក និងអ្នកពាក់ព័ន្ធឱ្យធ្វើការតាមដានសុខភាព ជាប្រចាំដោយមានទំនួលខុសត្រូវខ្ពស់ ព្រមទាំងត្រូវបង្កើនការប្រុងប្រយ័ត្ន រក្សាអនាម័យ ជាពិសេសអនុវត្តវិធានការ **៣ការពារ** ៖ រួមមាន ពាក់ម៉ាស់ លាងដៃជាមួយសាប៊ូ ឬអាល់កុល គម្លាតសុវត្ថិភាពសង្គម គម្លាតសុវត្ថិភាពបុគ្គល (ចាប់ពី១,៥ម៉ែត្រឡើងទៅ) និង**៣កុំ** ៖ រួមមាន កុំចូលទៅកន្លែងបិទជិត គ្មានខ្យល់ចេញចូល និងម៉ាស៊ីនត្រជាក់ច្រើនពេក កុំទៅកន្លែងមានមនុស្សច្រើន និងកុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា កុំឱបគ្នាជាដើម ព្រមទាំងអនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ក្នុងសហគមន៍។ ជាមួយគ្នានេះ បណ្ដាក្រុមហ៊ុន សហគ្រាស កសិដ្ឋានអាចពិនិត្យលទ្ធភាពការងារក្នុងកាត់បន្ថយបុគ្គលិកធ្វើការ ឬរៀបចំឱ្យមានការឆ្លាស់វេនគ្នាមកធ្វើការតាមតម្រូវការការងារ ព្រមទាំងចូលរួមអនុវត្តការស្កេន **QR Code "ទប់ស្កាត់កូវីដ-១៩"** នៅតាមច្រកចេញ-ចូលដោយអនុវត្តតាមជំហានទាំង៣នៃការប្រើប្រាស់ឱ្យបានត្រឹមត្រូវ។ ទន្ទឹមនោះ ត្រូវធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់បុគ្គលិក និងអ្នកពាក់ព័ន្ធពិសេសបុគ្គលិក ឬអ្នកបច្ចេកទេសបរទេសដែលចូលមកបម្រើការងារតាមក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចឱ្យមានការយល់ដឹងអំពីច្បាប់ និងអនុក្រឹត្យ ស្ដីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។

ទទួលបានសេចក្ដីណែនាំនេះ សូម ម្ចាស់ក្រុមហ៊ុន សហគ្រាស កសិដ្ឋាន និងសម្បទានដីសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវចូលរួមសហការអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ អង្គារ ៣កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២១
**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣ ២១៧ ៣២០
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

# សកម្មភាពថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ពិធីចុះហត្ថលេខាលើកិច្ចសន្យាចំនួន១៦ និងអនុស្សរណៈនៃការយោគយល់គ្នា (MoU) ចំនួន ០២ ស្ដីពី "ការផ្គត់ផ្គង់បន្លែសុវត្ថិភាព ដំឡូងមី ផ្លែស្វាយ ផ្លែឪឡឹកសាច់លឿង និងមាន់សាច់" ក្រោមអធិបតីភាពឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញចុះពិនិត្យកសិដ្ឋានចិញ្ចឹមត្រីប្រា ពោ អណ្ដែង និងត្រីឆ្ពោ របស់លោក លក លឿង ស្ថិតនៅភូមិតាកុច ឃុំស្រងែ ស្រុកព្រៃឈរ ខេត្តកំពង់ចាម




ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការី អញ្ជើញចុះពិនិត្យសកម្មភាពសាងសង់ហេដ្ឋារចនាសម្ព័ន្ធគាំទ្រសំខាន់ៗ ដែលកំពុងដំណើរការយ៉ាងមមាញឹករបស់ក្រុមហ៊ុន បាមីន អេហ្គ្រីខលឈ័រ ហាយ-ថេក ឌីវេឡុបមិន ឯ.ក នៅស្រុកកំពង់សិលា ខេត្តព្រះសីហនុ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងសហការីអញ្ជើញចុះពិនិត្យ Ares Organic Farm Products នៅភូមិចម្ការបី ឃុំពងទឹក ស្រុកដំណាក់ចង្អើរ ខេត្តកែប





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញពិនិត្យរោងចក្រប្រព្រឹត្តិកម្មសម្លាប់សមាសភាពសត្វចង្រៃដោយប្រើទឹកក្តៅ (Hot Water Treatment, HWT) របស់ក្រុម ហ៊ុន បឹងកេត ហ្វ្រេស ហ្វ្រូតឯ.ក នៅតាមបណ្តោយផ្លូវជាតិលេខ ៤ គីឡូម៉ែត្រលេខ ៨២ ក្នុងឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ





ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសចូលកាន់តំណែងនាយកវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម ក្នុងពិធីនេះ ក៏មានការអញ្ជើញចូលរួមផងដែរពីឯកឧត្តមរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងនិស្សិត



ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទអញ្ជើញជួបសំណេះសំណាល និងចែកអំណោយជូនប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយសារជំងឺកូវីដ១៩ ចំនួន ១០០គ្រួសារ ខេត្តត្បូងឃ្មុំ



លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងកម្មវិធីទិវានារី ៨ មីនា នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ



ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីបើកកិច្ចប្រជុំបូកសរុបលទ្ធផលការងារអនុវិស័យដំណាំឆ្នាំ២០២០ និងលើកទិសដៅការងារឆ្នាំ២០២១ របស់អគ្គនាយកដ្ឋានកសិកម្ម



ឯកឧត្តម **ឈៅ ធួក** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាផ្សព្វផ្សាយលទ្ធផល ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឆ្នាំ២០២០ និងទិសដៅឆ្នាំ២០២១នៅខេត្តសៀមរាប



ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យស្ថានភាពភូមិសាស្ត្រតំបន់អភិរក្ស ចូលរួមទម្លាក់ប្រអប់ជម្រកត្រី និងពិភាក្សាលើវិធានការគ្រប់គ្រងដីព្រៃលិចទឹកនៅខេត្តកែប



ឯកឧត្តម **ហ៊ាន វណ្ណហាន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញទស្សនកិច្ចវឌ្ឍនភាពនៃការអនុវត្តគម្រោងសាកវប្បកម្មកម្ពុជាដើម្បីបង្កើនប្រាក់ចំណូល នៅខេត្តក្រចេះ



ឯកឧត្តម **ហ៊ួត ប៊ុនណារី** រដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គបណ្ដុះបណ្ដាលមន្ត្រីឱ្យក្លាយជាទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម នៅវិទ្យាស្ថានជាតិកសិកម្មខេត្តកំពង់ចាម



ឯកឧត្តម **អ៊ុំ សំអាត** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យ វិនិច្ឆ័យ សិក្សាស្រាវជ្រាវ និងវាយតម្លៃលើកិរិយាកាន់កាប់ដីរដ្ឋជាក់ស្ដែងពាក់ព័ន្ធនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើអូរថ្ម ស្ថិតនៅស្រុកព្រៃនប់ ខេត្តព្រះសីហនុ



ឯកឧត្តម **ឆេង គឹមស៊ុន** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ស្ដីពីកម្មវិធីសិក្សាថ្នាក់បរិញ្ញាប័ត្រជាន់ខ្ពស់របស់វិទ្យាស្ថានជាតិកសិកម្ម ព្រែកលៀប



ឯកឧត្តម **ចាន់ ចេស្ដា** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងពិធីបើកសិក្ខាសាលាស្ដីពី ផែនការមេវិស័យកសិកម្មឆ្នាំ២០៣០ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្មឆ្ពោះទៅឆ្នាំ២០៣០



ឯកឧត្តម **គុយ ម៉ាឌី** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលាពង្រៀងច្បាប់ស្ដីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា



ឯកឧត្តម **មាស ពិសិទ្ធ** អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អញ្ជើញចុះពិនិត្យឃ្លាំងស្រូវ ឡសម្ងួតស្រូវ ទីលានហាលស្រូវ ផ្ដល់សម្ភារ និងប្រជុំក្រុមកសិកម្មផលិតស្រូវ ដែលគាំទ្រថវិកាដោយរាជរដ្ឋាភិបាល និងប្រជាជនជប៉ុន នៅខេត្តប៉ៃលិន



# នាមព្រៃឈើ

- អាទិត្យនាងផ្អែក ទទឹមព្រៃ តៀ្បង    ឈើទាលនាងដែង បាយ ទឹក ប្រេង ម្សៅ
  ស្រូល ក្រហម ស គគីរ ថ្នូ ម្សៅ    ដែក ស្តី ឈើខ្មៅ កែស បេង នាងនួន។
- បេឡឹយ វល្លិយោង ឆាំឆា ច្រម៉ាស់    ច្រេស ទ្រាល កកោះ ត្រមែង ត្រមូង
  បូសនាគ ត្រយឹង ខ្លឹមរឹង គ្រញូង    ដុះកណ្តាលស្រោង នៅជាជ្រើៗ។
- ដូងថែម អង្កាញ់ ក្រឡាញ់ ផ្កាយ ព្រឹក    សង្កួតត្នោត ផ្ទឹក នឹក ឈ្លើក ស្រគុំ
  ម៉ៃសាក់ ស្នៃ ក្រាស ផ្ដៀក ម្រះព្រៅភ្នំ    ត្រសេក គ្រើល ផ្ដង់ ខ្វាវ ខ្លុង ក្រាយស។
- តាត្រាវ ជើងចាប ធ្លក អង្កត់ខ្មៅ    សុក្រម ស្រឡៅ ហៃសានចាន់ស
  កំញាន ត្រឡាត់ លំបោ សំព័រ    ខ្ទឹង ឈើទាលឆ្វេ រំដួល រាំងភ្នំ។
- ពពេល ពពូល ពង្រ ខ្ទុរព្រៃ    ត្រាច ល្បៀង ស្តួល ជ្រៃ កោងកាង ត្រប់ទុំ
  ចង្អូរត្នោត រង្គ សំពង់ ចេកទុំ    ស្មាក្របី ធំ ព្រួស ចាន់ទំពាំង។
- ប្រាំដំឡឹង ព្រីង បំពេញរាជ ក្តុល    បង្គៅ កណ្តោល ស្មាច់ បាយពូរាំង
  ដើមស្រស់ ត្នួ ផ្នុង ជ័រចុង អាទាំង    ស្វាយចំរៀង ត្រាង ស្វាយព្រៃ ក្របៅ។
- ដើមនី ប្រេងខ្យល់មង្គលរុក្ខា    ដើមអាកាស្បា ដុះឈ្នុះស្បូវស្មៅ
  កំលែង សង្កែ បន្លែ ម្រុំ ស្តៅ    ចន្ទន៍ក្រស្នា នៅថែមទាំង សាលព្រឹក្ស។

រៀបរៀងដោយៈ ជឹម ង្ហួន
អតីតអគ្គនាយករងទី១នៃអគ្គនាយកដ្ឋានចំការកៅស៊ូ







## ការផ្សាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ